ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ ក្រុមគម្រោងតាំងពិព័រណ៍ និង សារមន្ទីរ

◆ ប្រាសាទក្រោមរបបខ្មែរក្រហម

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១០៦ ខែតុលា ឆ្នាំ២០០៨

# ស្វែងរកការពិត

លេខ១០៦ ខែតុលា ឆ្នាំ២០០៨

## ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

### មាតិកា


◆ ក្រុមគម្រោងតាំងពិព័រណ៍ និងសារមន្ទីរ ............ ១

**ផ្នែកឯកសារ**

◆ ត្រឡប់មកស្រុកកំណើតទើបដឹងការពិត ............ ២

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ជួយមិនចង់បានសំណង ............ ៥

◆ កាលប្បវត្តិសំខាន់ៗរបស់តុលាការខ្មែរក្រហម ............ ៨

◆ ដំណើរទស្សនកិច្ចរបស់ខ្ញុំទៅស្រុកអន្លង់វែង ............ ១៣

◆ ការសម្លាប់រង្គាលនៅភូមិភាគបូព៌ា ............ ១៥

◆ ប្រាសាទក្រោមរបបខ្មែរក្រហម ............ ១៨

**ផ្នែកច្បាប់**

◆ ក្រមសីលធម៌ចៅក្រម ............ ២២

◆ នីតិវិធីបំបែកជនជាប់ឃុំបណ្ដោះអាសន្នឲ្យនៅដាច់ពីគ្នា ............ ៣៣

◆ ការពន្យារពេលឃុំខ្លួន នួន ជា ............ ៣៥

◆ អនុស្សរណៈ ............ ៣៧

◆ បណ្ដឹងយុត្តាធិការរបស់ អៀង សារី ............ ៤៣

**វេទិកាពិភាក្សាសាធារណៈ**

◆ សត្រូវខាងក្នុងនិងខាងក្រៅ ............ ៤៧

◆ ការវាយតម្លៃទៅលើដីកាអង្គជំនុំជម្រះវិសាមញ្ញស្ដីពី ............ ៥៥

**ទំព័រស្រាវជ្រាវរកក្រួសារ**

◆ នៅតែស្ដាយ ............ ៦០






**រក្សាសិទ្ធិ**


មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ ០២៩១ពម/៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នាដៃលេខនេះ ៖** សុខ វណ្ណៈ, ចារ៉េត រីតឃីនស៍, ស៊ីរ៉ិ សាវីណា, សេង គន្ធី, អានី ហ្គេល, អាន ហេនដល, រ៉េនដល ដឹហ្វាល់កូ, អ៊ីលីហ្សាបែត ដួ, សេឌ ប៉ែនឆាដ, ទេស ម៉ារ៉ែម **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** គាត លក្ខិណា, សោម ប៊ុនថន **អ្នកបកប្រែ៖** ជា ផល្លា **និពន្ធនាយកទូទៅ៖** ឆាំង យុ **ជំនួយការនិពន្ធនាយក៖** ទេព ម៉េងឃាន **ក្រាហ្វិកកុំព្យូទ័រ៖** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វេង Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ ៖*

# ក្រុមគម្រោងតាំងពិព័រណ៍ និង សារមន្ទីរ

ក្រុមគម្រោងតាំងពិព័រណ៍និងសារមន្ទីរនឹងចាប់ផ្តើមការផ្លាស់តាំងពិព័រណ៍រូបថតថ្មីនៅសារមន្ទីរអំពើប្រល័យពូជសាសន៍ទួលស្លែង ដែលមានចំណងជើងថា «ឋាននរក ៖ កម្ពុជាប្រជាធិបតេយ្យឆ្នាំ ១៩៧៨» ដោយប្រើប្រាស់រូបថតមកពីបណ្ណសារដ្ឋានរក្សាទុករូបថតនៃដំណើរទស្សនកិច្ច១៨ថ្ងៃមកកាន់កម្ពុជាប្រជាធិបតេយ្យរបស់សមាគមមិត្តភាពស៊ុយអែដ-កម្ពុជា នៅខែសីហាឆ្នាំ ១៩៧៨ ។ ក្នុងគណៈប្រតិភូនេះមានប្រតិភូ៤រូបរួមទាំង ហ៊ុនណា បឺយស្ត្រម ។ ប្រតិភូទាំងនោះបានទៅទស្សនាព្រះរាជវាំង មន្ទីរពេទ្យ រោងចក្រ និងសហករណ៍នៅក្នុងភ្នំពេញ ខេត្តកំពត កំពង់សោម (ក្រុងព្រះ-សីហនុ) កំពង់ចាម កំពង់ធំ និងសៀមរាប ហើយក៏បានជួបនិងបរិភោគអាហារពេលល្ងាចជាមួយមេដឹកនាំខ្មែរក្រហមផង រួមមាន ប៉ុល ពត និង អៀង សារី ។ ប្រតិភូទាំងនោះវិលត្រឡប់ទៅប្រទេសស៊ុយអែដវិញដោយនាំយករូបថត ភាពយន្តវគ្គខ្លីៗ ព្រមទាំងការចងចាំដែលបានឃើញផ្ទាល់នឹងភ្នែកក្នុងអំឡុងពេលទស្សនកិច្ចនេះ ។ ប៉ុន្មានឆ្នាំក្រោយមក អ្នកមកធ្វើទស្សនកិច្ចទាំងនោះស្មែងយល់ថា អ្វីដែលគេបានឃើញនៅពេលទស្សនកិច្ចនោះសុទ្ធតែមិនពិត ។

ក្នុងសន្និសីទមួយនៅក្រុងស្តុកខូម ប្រទេសស៊ុយអែដ កាលពីខែវិច្ឆកា ឆ្នាំ២០០៧ ហ៊ុនណា បឺយស្ត្រម បានជួបជាមួយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ហ៊ុនណា បានផ្តល់ឯកសាររបស់គាត់ដែលមានជាប់ពាក់ព័ន្ធនឹងខ្មែរក្រហមមកឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ឯកសារទាំងនោះរួមមានរូបថត ៩៧សន្លឹក ភាពយន្តខ្លាតខ្លីដែលមិនទាន់បានកាត់ត សំបុត្រ ទស្សនាវដ្តី កំណត់ហេតុ និងចម្រៀង ។

គម្រោងនេះរួមមាន៤ផ្នែកសំខាន់ៗ ៖ ការតាំងពិព័រណ៍ (ដែលនឹងចាប់ផ្តើមនៅទួលស្លែង នៅខែវិច្ឆិកា ឆ្នាំ២០០៨ បន្ទាប់មកនឹងបន្តទៅខេត្តតាកែវ កំពត កំពង់សោម កំពង់ចាម សៀមរាប និងបាត់ដំបង មួយកន្លែងបីខែមុនពេលត្រឡប់មកភ្នំពេញវិញ) ។ ការតាំងពិព័រណ៍មានជាភាសាខ្មែរនិងអង់គ្លេស ។ សិក្ខាសាលាបី (នៅភ្នំពេញ កំពង់ចាម និងបាត់ដំបង នៅអំឡុងថ្ងៃ១៨-២៩ ខែវិច្ឆិកា ឆ្នាំ២០០៨) មានជាប់ពាក់ព័ន្ធនឹងដំណើរទស្សនកិច្ចជុំវិញបឹងទន្លេសាប ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបង្កើតគម្រោងនេះដើម្បីសហការជាមួយវេទិកាពិភាក្សាប្រវត្តិសាស្ត្រនៅប្រទេសស៊ុយអែដ ដែលការតាំងពិព័រណ៍ដូចគ្នានេះនឹងត្រូវបានបង្កើតឡើងដែរ ។ ការតាំងពិព័រណ៍ក៏នឹងធ្វើឡើងនៅវិទ្យាស្ថានវ៉ៃយំ ក្រុងភ្នំពេញ ។ ច្បាប់ចម្លងនៃរូបថតទាំងនោះនឹងយកទៅចាក់ផ្សាយនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

មានប្រជាជន៨១៦នាក់ផ្តល់យោបល់ចំពោះការតាំងពិព័រណ៍រូបថតនៅសារមន្ទីរអំពើប្រល័យពូជសាសន៍នៅបីខែនេះថា ៖

***នេះជាសេចក្តីអធិប្បាយដែលបានជ្រើសរើស***

ខ្ញុំគិតថា នេះគឺជាគំនិតល្អក្នុងការបង្កើតឲ្យមានការតាំងពិព័រណ៍នេះ ។ ខ្ញុំមិនដែលដឹងពីភាពឈឺចាប់ដែលប្រជាជនកម្ពុជាបានឆ្លងកាត់នោះទេ ។ ការតាំងពិព័រណ៍នេះផ្តល់នូវទស្សនីយភាពដ៏រស់រវើក ព្រមទាំងបង្ហាញពីហេតុការណ៍ដ៏អាក្រក់ដែលបានកើតឡើង ។ វាគឺជាការតាំងពិព័រណ៍ដ៏មានតម្លៃ ។

***ពី ជេ អឹម ប្រទេសអូស្ត្រាលី***

បេះដូងរបស់ខ្ញុំជ្រួតជ្រាបពីរឿងរ៉ាវរបស់ជនរងគ្រោះនិងគ្រួសាររបស់គេ ។ សុំកុំបំភ្លេចនូវរឿងដ៏ឃោរឃៅនេះ ព្រមទាំងព្យាយាមរារាំងកុំឲ្យនរណាម្នាក់ធ្វើបែបនេះទៀត ។

***ពី លា សហរដ្ឋអាមេរិក***

វាគួរឲ្យភ័យខ្លាចថាតើមនោគមន៍វិជ្ជាអាចនាំទៅរកភាពវឹកវរការស្លាប់នៃប្រជាជនគ្មានកំហុសដែលធ្វើឲ្យមានផលវិបាកជាច្រើនទសវត្សរ៍ដោយរបៀបណា ។ ពេលដែលខ្ញុំដើរទៅបន្ទប់រៀននៅតាមជណ្តើរ ខ្ញុំមានអារម្មណ៍ព្រឺឆ្អឹងខ្នង ជាពិសេសនៅពេលដែលខ្ញុំស្រមៃទៅដល់កន្លែងបែបនេះ ទីក្រុងដែលក្លាយទៅជាកន្លែងស្លាប់របស់ប្រជាជនជាច្រើន ។

***ពី ឈរ ប្រទេសសាំងហ្គាពួរ***

***(តទៅទំព័រ៧)***

# ត្រឡប់មកស្រុកកំណើតទើបដឹងការពិត

នៅពេលរំឭកពីរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនខ្មែរទាំងអស់តែងតែនឹកឃើញពីការសម្លាប់ ការធ្វើទារុណកម្ម និងការបង្ខំឲ្យធ្វើការហួសកម្លាំងរបស់ខ្មែរក្រហមជានិច្ច ។ អ្នកដែលធ្លាប់ឆ្លងកាត់របបនេះសុទ្ធតែដឹងពីអំពើឃោរឃៅរបស់ខ្មែរក្រហមដែលបានធ្វើមកលើប្រជាជន ហើយយល់ថារបបនេះបានសម្លាប់មនុស្សដោយគ្មានការវិនិច្ឆ័យទោសជាមុនទេ ។ ផ្ទុយស្រឡះពីអ្នកទាំងអស់នេះ យ៉ុន ដែលមានស្រុកកំណើតនៅភូមិវត្តភ្នំ ឃុំកំពែង ស្រុកគិរីវង្ស ខេត្តតាកែវ បែរជាមិនបានដឹងពីអំពើរបស់ខ្មែរក្រហមទៅវិញ ហើយក្រោយពេលដែលគាត់ត្រឡប់មកជួបឪពុកម្តាយនៅស្រុកកំណើតឆ្នាំ១៩៧៩ ទើបគាត់បានដឹងពីស្ថានភាពរស់នៅពិតប្រាកដរបស់គ្រួសារនិងប្រជាជននៅក្នុងភូមិ ។

យ៉ុន គឺជាកូនស្រីច្បងគេបង្អស់ក្នុងចំណោមបងប្អូន៩នាក់ ។ កាលពីកុមារភាព យ៉ុន រៀនបានត្រឹមតែថ្នាក់កុមារដ្ឋាន ដោយចេះអានអក្សរបន្តិចបន្តួចប៉ុណ្ណោះ ។ នៅឆ្នាំ១៩៦៨ ដោយសារតែជីវភាពក្រីក្រមិនមានលទ្ធភាពបន្តការសិក្សាតទៅទៀត យ៉ុន បានសម្រេចចិត្តឈប់រៀនមកជួយធ្វើស្រែឪពុកម្តាយនិងដើរទិញស្រូវតាមភូមិឃុំផ្សេងៗយកមកលក់នៅផ្ទះវិញ ។

នៅឆ្នាំ១៩៧០ ស្ថានភាពនៅក្នុងភូមិក៏ចាប់ផ្តើមមានភាពច្របូកច្របល់ខ្លាំងដោយសារមានការវាយប្រយុទ្ធគ្នារវាងកងទ័ពខ្មែរក្រហមនិងទាហាន លន់ នល់ ។ កងទ័ពខ្មែរក្រហមបានយករថក្រោះធំៗមកបញ្ឈរជើងនៅក្នុងភូមិនេះដែលជំរុញឲ្យក្រុមគ្រួសាររបស់ យ៉ុន ក៏ដូចជាប្រជាជននៅក្នុងភូមិទាំងអស់ភ័យខ្លាចនាំគ្នាចាកចេញពីផ្ទះសម្បែងរៀងៗខ្លួន ខ្លះរត់ទៅវាលស្រែ ខ្លះរត់ឡើងភ្នំនិងខ្លះទៀតរត់ទៅខេត្តកំពតដើម្បីគេចខ្លួនមួយរយៈ ។ ក្រោយពីស្ថានភាពបានស្ងប់ស្ងាត់ទើបនាំគ្នាត្រឡប់មកភូមិឋានវិញ ។

នៅឆ្នាំ១៩៧២ ក្រោយពីកងទ័ពខ្មែរក្រហមចូលមកគ្រប់គ្រងទាំងស្រុងនៅស្រុកនេះ រយៈពេលមួយខែម្តង ប្រធាននារីឈ្មោះ គូ និង គណៈឃុំឈ្មោះ ញ៉េប (សព្វថ្ងៃស្លាប់) តែងតែមកជ្រើសរើសយុវជននិងយុវនារីចំនួន២-៣នាក់ក្នុងមួយភូមិឲ្យចូលបម្រើបដិវត្តន៍ ។ ពេលនោះ គូ និង ញ៉េប បានមកផ្ទះរបស់ យ៉ុន ចំនួន៣លើក ប៉ុន្តែ យ៉ុន ក៏បានបដិសេធទាំងបីលើកដែរ ព្រោះគាត់ចង់នៅមើលថែទាំឪពុកម្តាយដែលចាស់ជរា ។

**ចូលបដិវត្តន៍**

ញ៉េប និង គូ មិនដែលបោះបង់គំនិតក្នុងការនាំ យ៉ុន ចូលបដិវត្តន៍ទេ ព្រោះនៅឆ្នាំ១៩៧៥ អ្នកទាំងពីរបានមកផ្ទះរបស់គាត់ម្តងទៀត ។ លើកនេះ យ៉ុន គិតថាមិនអាចប្រកែកបានទៀតទេ ដោយគាត់រៀបរាប់ថា «*កាលណាអង្គការថាទៅលិចត្រូវទៅលិច ទៅកើតត្រូវទៅកើត មិនមែនស្រេចតែយើងទេ បើហ៊ានជំទាស់មុខជាបាត់ខ្លួន*» ។ ពេលនោះ នារីៗត្រូវអង្គការតម្រូវឲ្យស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅនិងកាត់សក់ខ្លីត្រឹមកញ្ចឹងក ។ បន្ទាប់មកអង្គការបានបញ្ជូន យ៉ុន ឲ្យទៅដាំសណ្តែកសៀងនៅមន្ទីរត្រពាំងធំជិតភ្នំជីវីរមៀល ។ ក្រោយពីប្រជាជនមកជួបជុំគ្នាគ្រប់១០០នាក់ហើយ អង្គការក៏បញ្ជាឲ្យទៅធ្វើការនៅអង្គតាសោមខេត្តតាកែវវិញ ។ យ៉ុន ស្ថិតនៅក្នុងកងលេខ៣២ វរសេនាធំលេខ៥៣ មានតួនាទីសម្អាតក្រុង ចុះស្ទូងជាមួយប្រជាជន ដាំដើមដូង ក្រោមការគ្រប់គ្រងរបស់ ញ៉ី ។ ប្រហែលមួយខែក្រោយមក ក៏មានរថយន្តមួយគ្រឿងមកដឹកកម្មករនៅទីនេះទាំងអស់ឲ្យទៅធ្វើស្រែអំបិលនៅខេត្តកំពតវិញ ។ មកដល់ការដ្ឋានស្រែអំបិល យ៉ុន សម្គាល់ឃើញថាមិនសូវមានកម្មករប្រុសប៉ុន្មានទេ ភាគច្រើនជាស្ត្រីភេទ ។ អង្គការបែងចែកជាកងវរសេនាធំលេខ៥៣ និងកងពលទី២ ក្រោមការទទួលខុសត្រូវរបស់ ជឿន ។ យ៉ុន ត្រូវបានចាត់តាំងឲ្យកាន់ផ្នែកសេដ្ឋកិច្ចខាងស្នើសុំបន្លែយកមកផ្គត់ផ្គង់កម្មករ ។ ដំបូង យ៉ុន ត្រូវជិះកង់ទៅឃុំផ្សេងៗដូចជាឃុំក្រាំងស្បូវជាដើម ដោយគ្រាន់តែប្រាប់ថាខាងអង្គភាពស្រែអំបិលត្រូវការស្នើបន្លែ បីថ្ងៃទៀតនឹងយករថយន្តមកដឹកហើយ ។ ពេលកំណត់មកដល់ ទើប យ៉ុន និងកម្មករពីរបីនាក់ទៀតជិះរថយន្តទៅដឹកបន្លែតាមការសន្យា ។ មួយរយៈក្រោយមក យ៉ុន ត្រូវផ្លាស់ទៅរែកអំបិលដាក់ឃ្លាំងវិញ ដែលការងារនេះតម្រូវឲ្យគាត់ត្រូវក្រោកធ្វើការតាំងពីម៉ោង៥

ព្រឹក រហូតដល់ល្ងាចទើបអាចសម្រាកបាន ។

វិធីធ្វើអំបិល គឺដំបូងត្រូវបុកដីឲ្យហាប់ល្អ បន្ទាប់មកបញ្ចូលទឹកសមុទ្រទៅក្នុងស្រែ ។ រយៈពេលប៉ុន្មានថ្ងៃក្រោយមក អំបិលទាំងនោះនឹងដុះរួចនឹងចាប់ផ្តើមថ្លឹង ប្រសិនបើអំបិលនោះមានលេខ៧ ឬលេខ៨ មានន័យថាអំបិលដុះបានល្អ ប្រសិនបើលេខ៩ ឬ១០ ដុះមិនបានល្អទេ ។ បន្ទាប់មកទើបកម្មករទាំងអស់បែងចែកកម្លាំងគ្នាដើម្បីប្រូកអំបិលមួយបាវ៥០គីឡូក្រាមយកទៅទុកក្នុងឃ្លាំង ។ អំបិលទាំងនេះអង្គការប្រាប់ថា «ដឹកយកទៅឲ្យពុកម៉ែយើងដែលគ្មានអំបិលហូប» ។ យ៉ុន រៀបរាប់ថា «ខ្ញុំឃើញរថយន្តប្រហែលជា១០គ្រឿងមកដឹកអំបិលជារៀងរាល់ថ្ងៃយកទៅដាក់នៅវ៉ារទេះភ្លើង ប៉ុន្តែមិនដឹងដឹកទៅណាបន្តទៀតទេ» ។ ពេលធ្វើការ យ៉ុន ព្រួយបារម្ភពីសុវត្ថិភាពរបស់ខ្លួនណាស់ ព្រោះគាត់ខស្សាហ៍ឃើញសមាជិកក្នុងក្រុមរបស់គាត់បាត់ខ្លួនម្តងមួយៗ ដោយដឹងថាម្នាក់ហ្នឹងក្បត់នឹងអង្គការហើយ ។ លើសពីនេះ នៅក្នុងកងរបស់គាត់មានមនុស្សចងកស្លាប់ចំនួនបីនាក់មិនដឹងពីមូលហេតុ ម្នាក់ឈ្មោះ មាស ភេទ ហើយពីរនាក់ទៀតគាត់មិនចាំឈ្មោះ ។ ទោះបីការងាររវល់យ៉ាងណាក៏ដោយ ក៏កិច្ចប្រជុំរយៈពេលបីថ្ងៃម្តងជាមួយប្រធានកងហា កងធំ តែងតែប្រព្រឹត្តទៅដោយទៀងទាត់ដោយតម្រូវឲ្យម្នាក់ៗបញ្ចេញយោបល់ថាតើការងារក្នុងរយៈពេលបីថ្ងៃធ្វើបានអ្វីខ្លះ ដើម្បីពង្រឹងគោលជំហរកសាងខ្លួនបន្ថែមទៀត ប៉ុន្តែពុំមានវត្តមានរបស់ ជឿន ទេ ។

នៅទីនេះ ទោះបីជាធ្វើការមានការលំបាកនិងនឿយហត់បន្តិចក៏ដោយ ក៏កម្មករម្នាក់ៗទទួលបានអាហារគ្រប់គ្រាន់ដែរ ហើយក្នុងរយៈពេលមួយសប្តាហ៍ម្តង អង្គការមានធ្វើបង្អែមនិងនំដើម្បីលើកទឹកចិត្តកម្មករទាំងអស់ឲ្យមានកម្លាំងធ្វើការថែមទៀត ។

នៅខែវស្សា ពេលធ្វើអំបិលមិនកើត អង្គការបានជ្រើសរើសក្នុងមួយក្រុម៤-៥នាក់ ឲ្យធ្វើចម្ការនៅក្រុងកែបវិញ ។ យ៉ុន មិនដែលបានមកលេងផ្ទះទេ ព្រោះសំណើសុំរបស់គាត់ត្រូវបានប្រធានកងបដិសេធ ។ ប៉ុន្តែ យ៉ុន ក៏មិនដែលមានគំនិតលួចរត់មកផ្ទះទេ ព្រោះធ្លាប់ឃើញអ្នកនៅក្នុងកងរបស់គាត់ម្នាក់លួចរត់មកផ្ទះ ហើយពេលអង្គការចាប់បានក៏បញ្ជូនទៅកសាង បន្ទាប់មកត្រូវបាត់ខ្លួនរហូត ។

## ការងារនៅមន្ទីរពេទ្យ

នៅឆ្នាំ១៩៧៧ អង្គការបានជ្រើសរើសអ្នកដែលមានប្រវត្តិរូបល្អឲ្យទៅធ្វើការនៅភ្នំពេញ ដោយក្នុងមួយក្រុមរើសម្នាក់ ក្នុងនោះក៏មានឈ្មោះ យ៉ុន ផងដែរ ។ តាមពិត យ៉ុន មិនចង់ទៅទេ ប៉ុន្តែគាត់មិនអាចប្រកែកបាន ព្រោះខ្លាចអង្គការយកទៅសម្លាប់ ។ មកដល់មន្ទីរពេទ្យ អង្គការចាត់តាំង យ៉ុន ឲ្យសម្រាកនៅក្នុងផ្ទះមួយដែលបែងចែកជាច្រើនផ្នែកដូចជា ផ្នែកលាងរបួស វះកាត់ បោសសម្អាតនិងចុងភៅ ។ យ៉ុន ស្ថិតនៅក្នុងផ្នែកលាងរបួសមានគ្នា១០នាក់សុទ្ធតែស្រី ។ ទោះបីជា យ៉ុន មិនដែលរៀនពេទ្យពីមុនក៏ដោយ ក៏គាត់អាចធ្វើការបានដែរតាមរយៈការជួយបង្រៀនពីបុគ្គលិកចាស់ដែលធ្លាប់មានបទពិសោធន៍ ហើយមិនដែលត្រូវអង្គការស្តីបន្ទោសទេ ។ មិនយូរប៉ុន្មាន អង្គការបានមានវិធានការថ្មីដោយប្រាប់ថាដើម្បីឲ្យស្មើភាពគ្នាត្រូវតែផ្លាស់ យ៉ុន ទៅធ្វើម្ហូបសម្រាប់បុគ្គលិកពេទ្យនិងអ្នកជំងឺទាំងអស់ដែលមកសម្រាកនៅទីនេះវិញ ។ យ៉ុន អាចចេញពីបរិវេណមន្ទីរពេទ្យបាននៅពេលដែលមានបញ្ជាឲ្យទៅដឹកខសនៅផ្សារទួលទំពូង ។ ពេលនោះ យ៉ុន មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ព្រោះឃើញបរិយាកាសនៅក្នុងក្រុងមានសភាពស្ងាត់ជ្រងំ ។

ថ្នាំដែលប្រើប្រាស់ព្យាបាលអ្នកជំងឺជាប្រភេទថ្នាំដប ដោយមានបិទក្រដាសជាអក្សរខ្មែរពីរបៀបប្រើប្រាស់ថ្នាំផងដូចជាថ្នាំចាក់សរសៃនិងថ្នាំចាក់សាច់ដុំជាដើម ។ អ្នករបួសនៅទីនេះមានច្រើនណាស់ ហើយរយៈពេលបីថ្ងៃម្តង យ៉ុន តែងតែឃើញរថយន្តដឹកអ្នករបួសមកមន្ទីរពេទ្យនៅវេលាម៉ោង៩ ឬ១០យប់ជានិច្ច ដែលភាគច្រើនជាប្រភេទអ្នករបួសធ្ងន់ដូចជាត្រូវគ្រាប់កាំភ្លើងចំភ្លៅជាដើម ។

នៅទីនេះ យ៉ុន ធ្លាប់ចូលរួមប្រជុំម្តងជាមួយបុគ្គលិកមកពីគ្រប់ក្រសួងទាំងអស់នៅស្តាតអូឡាំពិករយៈពេលមួយថ្ងៃ ដើម្បីពង្រឹងគោលជំហរកម្មករទាំងអស់មិនឲ្យងាករេ ហើយតាំងចិត្តធ្វើការជូនអង្គការ ដែលមាន តាម៉ុក ជាអធិបតីកិច្ចប្រជុំនេះ ។

## រត់ទៅបាត់ដំបង

នៅថ្ងៃដែលវៀតណាមចូលរំដោះ អ្នកជំងឺនិង យ៉ុន បាននាំគ្នារត់ទៅវ៉ារទេះភ្លើងនៅវេលាម៉ោង៥ល្ងាច ។ ប៉ុន្មានម៉ោង

ក្រោយមក រថភ្លើងក៏មកដល់បាត់ដំបង ។ យ៉ុន ចង់ត្រឡប់មកផ្ទះវិញដែរ ប៉ុន្តែដោយសារតែឮពាក្យចចាមអារ៉ាមថា "កាលណាត្រឡប់ទៅវិញ យួននឹងបាញ់ចោលហើយ" ។ ដូច្នេះ ទើប យ៉ុន ចេះតែបន្តដំណើរទៅមុខជានិច្ចរហូតដល់ស្រុកសំឡូត ។ ម្យ៉ាងទៀតដោយសារតែ យ៉ុន មិនស្គាល់ផ្លូវត្រឡប់មកផ្ទះវិញផង ។ នៅទីនេះ យ៉ុន ធ្វើជាពេទ្យព្យាបាលរបួសដូចកាលពីមុន ។

ដោយសារមានការលំបាកក្នុងការរស់នៅខ្ទង់ពេក នៅខែមិថុនា ឆ្នាំ១៩៧៩ យ៉ុន បានសម្រេចចិត្តត្រឡប់មកស្រុកកំណើតវិញ ។ នៅឆ្នាំ១៩៨០ យ៉ុន បានរៀបការជាមួយនឹងបុរសម្នាក់ជាអ្នកស្រុកនៅភូមិជាមួយគ្នា ។ សព្វថ្ងៃនេះ យ៉ុន មានកូន៥នាក់ (ប្រុស ៤, ស្រី១) ។ ដោយមមាញឹកនឹងការរកស៊ីជាខ្លាំង យ៉ុន មិនសូវបានដឹងអំពីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមឡើយ ។ ប៉ុន្តែគាត់យល់ថាការបង្កើតតុលាការនេះគឺជាការត្រឹមត្រូវនិងមានប្រយោជន៍សម្រាប់សង្គមជាតិ ដើម្បីរកយុត្តិធម៌ជូនគាត់ ក៏ដូចជាប្រជាជននៅទូទាំងប្រទេសដែរ ។

**គាត លក្ខិណា**

# ការិយាល័យព័ត៌មានសាធារណៈ

"ការិយាល័យព័ត៌មានសាធារណៈ" នៃមជ្ឈមណ្ឌលឯកសារកម្ពុជាឥឡូវនេះបានចាប់ផ្តើមបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបស់របបកម្ពុជាប្រជាធិបតេយ្យនិងព្រឹត្តិការណ៍វិវត្តនៃអង្គជំនុំជម្រះវិសាមញ្ញដែលនឹងត្រូវបង្កើតឡើងនៅពេលខាងមុខឆាប់ៗនេះ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំនិងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារទាំងនេះរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

"ការិយាល័យព័ត៌មានសាធារណៈ" មានផ្តល់ជូននូវសេវា៣យ៉ាង ៖

**១) បណ្ណាល័យ** ៖ នៅក្នុងបណ្ណាល័យរបស់យើង សាធារណជនអាចអានឯកសារ សៀវភៅ និងទស្សនាវដ្តី ស្តាប់កាសែតសំឡេង ទស្សនាខ្សែភាពយន្តឯកសារ និងមើលរូបថតដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង បណ្ណសារដ្ឋានជាតិកម្ពុជា និងពីប្រភពផ្សេងៗទៀត ។

**២) មជ្ឈមណ្ឌលអប់រំ** ៖ មជ្ឈមណ្ឌលមានបញ្ចាំងជូននូវខ្សែភាពយន្តឯកសារ និងបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ប្រធានបទទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញ និងប្រធានបទដទៃៗទៀត ។ ភាពយន្តឯកសារអំពីខ្មែរក្រហមមានបញ្ចាំងជូនទស្សនារៀងរាល់ថ្ងៃអង្គារនិងថ្ងៃព្រហស្បតិ៍ នៅវេលាម៉ោង៩ព្រឹកនិង៣រសៀល ។

**៣) ក្រុមការងារផ្នែកតុលាការ** ៖ ទីប្រឹក្សាផ្នែកឯកសារនិងផ្នែកច្បាប់របស់យើងនឹងផ្តល់ជំនួយផ្នែកស្រាវជ្រាវដល់អ្នកជំនាញផ្នែកច្បាប់កម្ពុជានិងអង្គការសហប្រជាជាតិដែលធ្វើការងារផ្នែកតុលាការ ក៏ដូចជាដល់សាធារណជនទូទៅដែរ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ីវ សាវីណា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# ជួយមិនចង់បានសំណង

មនោគមន៍វិជ្ជានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានធ្វើឲ្យកម្មាភិបាលខ្មែរក្រហមមួយចំនួនដែលកាន់អំណាចតាមភូមិ ឃុំ ស្រុកមានទឹកចិត្តសាហាវព្រៃផ្សៃនិងបណ្ដុះគំនិតបុគ្គលម្នាក់ៗឲ្យកាត់ផ្ដាច់មនោសញ្ចេតនាពីឪពុកម្ដាយ សាច់ញាតិ និងបងប្អូន ដូចពាក្យស្លោករបស់ខ្មែរក្រហមមួយឃ្លាថា «សក់អ្នកណាក្បាលអ្នកហ្នឹង» ។ ទោះជាយ៉ាងណាក៏ដោយ ក៏មានកម្មាភិបាលមួយចំនួនតូចនៅតែមានសន្ដានចិត្តល្អ ចេះសន្ដោសប្រណីចំពោះប្រជាជនខ្លះដែរ ដូចជា គង់ ស៊ីម អាយុ៥២ឆ្នាំ មានស្រុកកំណើតនៅភូមិដំណាក់ត្រាច ឃុំទួលអម្ពិល ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ជាដើម ។

កាលពីកុមារភាព ស៊ីម រៀនបានត្រឹមតែថ្នាក់ទី៩ (សង្គម-ចាស់ប៉ុណ្ណោះ) ។ ក្រោយមក ដោយសារតែរដ្ឋប្រហារទម្លាក់សម្ដេច សីហនុ នៅឆ្នាំ១៩៧០ ហើយជីវភាពគ្រួសារជួបការលំបាក ស៊ីម បានសម្រេចចិត្តឈប់រៀនមកជួយធ្វើស្រែចម្ការជាមួយឪពុកម្ដាយនៅផ្ទះវិញ ។ នៅឆ្នាំ១៩៧២ ក្រោយពីកងទ័ពខ្មែរក្រហមចូលមកកាន់កាប់នៅក្នុងភូមិ ស៊ីម បានស្ម័គ្រចិត្តចូលបម្រើបដិវត្តន៍ជាមួយនឹងក្មេងដទៃជាច្រើន ដោយធ្វើជាកងឈ្លបប្រចាំភូមិដំណាក់ត្រាច ឃុំទួលអម្ពិល ។ នៅឆ្នាំ១៩៧៣ ស៊ីម បានចូលព្រៃម៉ាគីបម្រើចលនាខ្មែររំដោះច្បាំងជាមួយនឹងទាហានលន់ នល់ ។ ទោះបីជាទាហានលន់ នល់ មានសម្ភារៈនិងអាវុធយុទ្ធភណ្ឌទំនើបៗក៏ដោយ ក៏ទឹកចិត្តក្លាហាននិងភាពស្មោះស្ម័គ្ររបស់កងទ័ពខ្មែរក្រហមចំពោះអង្គការបានធ្វើឲ្យការប្រយុទ្ធទទួលបានជ័យជម្នះទាំងស្រុងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ប៉ុន្តែជ័យជម្នះនេះបានធ្វើឲ្យកងទ័ពបាត់បង់ជីវិតជាច្រើនពាន់នាក់ រួមទាំងប្រជាជនស៊ីវិលផង ។

បន្ទាប់មក មេដឹកនាំខ្មែរក្រហមបានកែប្រែរចនាសម្ព័ន្ធនិងរបៀបគ្រប់គ្រងតាមគោលនយោបាយថ្មីមួយខុសពីមុនទាំងស្រុង ដោយបានលើកស្ទួយវណ្ណៈកសិករនិងកម្មករ រួចចាប់ផ្ដើមបោសសម្អាតវណ្ណៈនាយទុននិងសក្ដិភូមិ បំបាត់ទីផ្សារនិងកាត់ផ្ដាច់ប្រព័ន្ធផ្សព្វផ្សាយមិនឲ្យប្រជាជនដឹងព័ត៌មានអ្វីទាំងអស់ ។ ជាងនេះទៅទៀត ទោះបីជាថ្នាក់លើពុំបានកំណត់មុខសញ្ញាឲ្យបានច្បាស់លាស់ថាអ្នកណាជាសត្រូវរបស់ខ្លួនពិតប្រាកដក៏ដោយ ក៏កងទ័ពខ្មែរក្រហមដែលធ្លាប់ជួយបដិវត្តន៍ត្រូវអង្គការចាត់ទុកថាខ្មាំងដែរ ហើយនៅតែបន្តស្រាវជ្រាវរកប្រវត្តិរូបថែមទៀតដើម្បីជាលេសចាប់ខ្លួន ដែលនេះធ្វើឲ្យប៉ះពាល់ដល់កម្លាំងទ័ពមួយចំនួនរហូតដល់មានអ្នកខ្លះត្រូវយកទៅសម្លាប់ ហើយមួយចំនួនទៀតត្រូវដកចេញពីតួនាទី ប្រសិនបើរកឃើញថាមានបងប្អូនឬឪពុកម្ដាយជាប់និន្នាការជាមួយរបបលន់ នល់ ។ ពេលនោះ ស៊ីម ត្រូវអង្គការស៊ើបដឹងថាគាត់ជាប់និន្នាការ ព្រោះគាត់មានបងប្អូនធ្លាប់បម្រើការងារជាមន្ត្រីរដ្ឋការនៅក្នុងរបបសាធារណរដ្ឋខ្មែរ ។ ដូច្នេះ អង្គការចាត់តាំង ស៊ីម ឲ្យត្រឡប់មកមូលដ្ឋានវិញ ។ ស៊ីម មានតួនាទីដឹកនាំកុមារប្រហែលជា៤០នាក់ ដែលភាគច្រើនមានអាយុប្រហែល ១០ឆ្នាំ ឲ្យដើរកាប់ទន្រ្ទានខេត្តដើម្បីយកមកធ្វើជីដាក់ស្រែនិងបញ្ចូលទឹកក្នុងស្រែ ។ ក្នុងការដឹកនាំនេះ អង្គការមិនសូវតឹងតែងប៉ុន្មានទេ ។



បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងសម្ភាសន៍ជាមួយ គង់ ស៊ីម

នៅខែកក្កដា ឆ្នាំ១៩៧៧ ស៊ីម ត្រូវអង្គការរៀបចំឲ្យមានគ្រួសារ ។ ប៉ុន្តែ អាពាហ៍ពិពាហ៍នេះ ស៊ីម គ្មានសិទ្ធិ

ជ្រើសរើសនារីដែលខ្លួនស្រឡាញ់ឡើយ ព្រោះគាត់មិនដែលបានស្គាល់នារីនោះពីមុនមកសោះ ចំណែកឪពុកម្តាយនិងបងប្អូនក៏មិនបានដឹងព្ទនិងចូលរួមដែរ ។ ពិធីរៀបការពេលនោះមានចំនួនពី៣០ទៅ៤០គូ ហើយតម្រូវឲ្យយុវជននិងយុវនារីយើងឡើងប្តេជ្ញាចិត្តចំពោះមុខកម្មាភិបាលថ្នាក់ឃុំនិងស្រុកជាតំណាង ។ បន្ទាប់ពីរៀបការរួច នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ១៩៧៧ អង្គការបានបញ្ជូនអ្នកដែលទើបរៀបការចំនួន៣៦គូនេះទៅខេត្តតាកែវទាំងអស់ ដែលមានមនុស្សជាច្រើននាក់ទៀតមកពីខេត្តចំនួនបី គឺខេត្តកំពត កំពង់ស្ពឺ និងខេត្តតាកែវឲ្យមកជួបជុំគ្នានៅទីនេះ ។ ស៊ឹម មិនបានដឹងពីគោលបំណងរបស់អង្គការថ្នាក់លើទេ ព្រឹកឡើងស្រាប់តែមានកម្មាភិបាលខ្មែរក្រហមម្នាក់មកប្រាប់ថា ថ្ងៃនេះមានបើកអង្គប្រជុំធំមួយក្រោមអធិបតីភាពរបស់មេដឹកនាំខ្មែរក្រហមម្នាក់ ។ ក្រោយពីជួបជុំគ្នាមួយសន្ទុះមក ស្រាប់តែ ស៊ឹម បានឃើញ តាម៉ុក ជិះរថយន្តមកដល់ រួចបានឡើងប្រកាសថា «ពិនិត្យតាមសភាពការណ៍នៅខេត្តបាត់ដំបងគឺមានជួរកម្មាភិបាលយើងមួយចំនួនមានផែនការក្បត់ ដូច្នេះមានតែមិត្តដែលទើបរៀបចំគ្រួសារថ្មីទេដែលអាចជួយកសាងប្រទេសជាតិបាន» ។ ស្អែកឡើងថ្ងៃទី១០ វេលាម៉ោង៨ព្រឹក ស៊ឹម និងប្រពន្ធក៏នាំគ្នាជិះរថភ្លើងទៅខេត្តបាត់ដំបង ។ នៅទីនោះ ស៊ឹម ត្រូវអង្គការចាត់តាំងឲ្យធ្វើការខាងមន្ទីរពេទ្យស្រុក ។ ថ្ងៃទី១១ ខែកក្កដា តាម៉ុក ក៏ជិះយន្តហោះទៅបើកកិច្ចប្រជុំនៅទីនោះទៀត ។ តាម៉ុក បាននិយាយថា «នៅខេត្តបាត់ដំបងមិត្តយើងទាំងអស់គ្នាត្រូវខំប្រឹងធ្វើការផារជូនអង្គការ ហើយបានណែនាំ រស់ ញឹម ឲ្យដឹងថាជាមិត្តភក្តិរបស់គាត់តាំងពីនៅក្នុងព្រៃជាមួយគ្នាយូរមកហើយ ។ បន្ទាប់មកអ្នកទាំងពីរបានចាប់ដៃគ្នា ហើយសើចសប្បាយរីករាយជាធម្មតា ។ ក្រោយមក អង្គប្រជុំបានបញ្ចប់ទៅក្នុងសភាពស្ងៀមស្ងាត់ ។ រយៈពេលជាងកន្លះខែក្រោយពីកិច្ចប្រជុំនេះ សភាពការណ៍នៅទីនោះបានផ្លាស់ប្តូរទាំងស្រុង ព្រោះមានការចាប់ខ្លួន រស់ ញឹម, តា ស៊ូ, តា វង្ស និងថ្នាក់កម្មាភិបាលមូលដ្ឋានចាស់ៗមួយចំនួនធ្វើឲ្យមានភាពប្របូកប្រូបល់ពេញខេត្តបាត់ដំបង ជាពិសេសនៅតំបន់៤ប្រជាជនត្រូវស្លាប់ដោយសារការបង្អត់អាហារ និងការយកមនុស្សទៅសម្លាប់យ៉ាងច្រើន ។

នៅឆ្នាំ១៩៧៨ ម៉ាន ដែលជាប្រពន្ធរបស់ ណុល មានតួនាទីជាប្រធានសហករណ៍នៅព្រៃទទឹង តំបន់៤ បានសម្រេចចិត្តយកក្មេងប្រុសម្នាក់ ឈ្មោះ ភឿន មកឲ្យ ស៊ឹម ។ ពេលនោះ ស៊ឹម បានសួរទៅ ម៉ាន វិញថា «កូនក្មេងនេះយកមកពីណា?» ទោះបីជា ម៉ាន ជាប្រពន្ធរបស់ ណុល ក៏ដោយ ប៉ុន្តែគាត់មិនពេញចិត្តនឹងទង្វើរបស់ប្តីគាត់ឡើយ ហើយក៏ឆ្លើយប្រាប់តាមត្រង់ថា «ឪពុកក្មេងនេះជាអ្នកមូលដ្ឋានមិនដឹងជាស្លាប់ពេលណាទេ នៅសល់តែម្តាយក្លាយជាស្ត្រីមេម៉ាយ ក្រោយមកត្រូវប្តីគាត់យកទៅសម្លាប់ចោលទៀត ដោយចោទថាខុសសីលធម៌» ។ ដោយសារតែមានចិត្តអាណិតកូនក្មេងដែលគ្មានកំហុសទើប ម៉ាន លួចមកជួប ស៊ឹម ដើម្បីឲ្យទទួលយកទៅចិញ្ចឹមផង» ។ ក្រោយពីពាក្យសម្តីនេះ ស៊ឹម បានយល់ព្រមឲ្យរស់នៅជាមួយគាត់ដោយគ្មានយល់ទាស់ទេ ។

នៅឆ្នាំ១៩៧៩ ពេលដែលកងទ័ពវៀតណាមវាយចូលដល់ប្រទេសកម្ពុជា ទាំងកម្មាភិបាលខ្មែរក្រហមទាំងប្រជាជនបាននាំគ្នាត្រឡប់មកផ្ទះរៀងៗខ្លួនវិញ ។ ស៊ឹម បាននាំប្រពន្ធនិងកូនរត់គៀសខ្លួនរហូតដល់ព្រំដែនថៃ ។ តាមផ្លូវ ស៊ឹម បានឃើញក្មេងស្រីម្នាក់កំពុងតែឈរយំសម្លឹងរកមើលអ្នកណាម្នាក់ ។ ស៊ឹម បានសួរថា «ក្មួយឈ្មោះអ្វី?» ពេលនោះ ក្មេងឆ្លើយថា «ខ្ញុំឈ្មោះ រី» ។ ស៊ឹម បានសួរបន្តថា «ឪពុកម្តាយរបស់ក្មួយនៅឯណា?» ក្មេងឆ្លើយថា «ឪពុកម្តាយរបស់ខ្ញុំប្រហែលជាស្លាប់អស់ហើយ ព្រោះ



ពិធីរៀបការរបស់ខ្មែរក្រហម

ពេលខ្ញុំត្រឡប់មកពីអន្តរភាពកុមារវិញ ខ្ញុំមិនឃើញគាត់នៅក្នុងភូមិទេ ហើយឥឡូវខ្ញុំមិនដឹងថាគាត់ទៅរស់នៅទីណាឡើយ» ។ ព្រោះដូច្នេះ ស៊ឹម ក៏ហៅក្មេងស្រីនោះរត់ទៅជាមួយទៀត ។ ទោះបីជាមានការលំបាកខ្លាំងនិងត្រូវជួបប្រទះការខ្វះខាតអាហារនៅតាមផ្លូវក៏ដោយក៏ ស៊ឹម មិនបានបោះបង់កូនក្មេងទាំងពីរនេះដែរ ដោយគាត់បាននាំរត់ទៅជាមួយនឹងប្រពន្ធរហូតដល់ជំរំស្រះកែវ ។

នៅក្នុងជំរំនេះ ដោយសារមិនទាន់មានអង្គការណាមកជួយឧបត្ថម្ភ ស៊ឹម បានសម្រេចចិត្តចូលទៅប្រទេសថៃដើម្បីស៊ីឈ្នួលកាច់ពោតក្នុងមួយបាវទទួលបានកម្រៃ៥បាត ។ ស៊ឹម ព្យាយាមធ្វើការណាស់ដើម្បីរកលុយមកផ្គត់ផ្គង់ជីវភាព ដោយមួយថ្ងៃគាត់អាចរកប្រាក់បានពី២៥ទៅ៣០បាត ។ មួយរយៈក្រោយមក មានជនជាតិបារាំងម្នាក់បានបង្កើតកន្លែងមួយដើម្បីទទួលក្មេងកំព្រាឲ្យរស់នៅ ពេលនោះក្មេងដែល ស៊ឹម រើសមកចិញ្ចឹមក៏បានសុំចាកចេញពីគាត់ទៅរស់នៅជាមួយក្មេងកំព្រាដទៃទៀតវិញ ព្រោះគិតថាកុំដាក់បន្ទុកទៅលើគាត់ខ្លាំងពេក ។ ស៊ឹម មិនបដិសេធចំពោះការស្នើនេះទេ ។ ប៉ុន្តែប្រពន្ធរបស់ ស៊ឹម មិនចង់ឲ្យក្មេងកំព្រាទាំងពីរនេះចាកចេញពីគាត់ឡើយព្រោះគាត់ចាត់ទុកដូចជាកូនបង្កើតគាត់ទៅហើយ ។ ដោយសារអាណិតប្រពន្ធពេក ស៊ឹម ក៏និយាយលួងលោមប្រពន្ធថា «ឯងអើយកុំគិតច្រើន ក្មេងទាំងពីរទៅបានសុខហើយ យើងនៅទីនេះមិនដឹងរស់នៅបានសុខទុក្ខយ៉ាងណាទេ ព្រោះកងទ័ពខ្មែរក្រហមបានប្រមូលផ្តុំគ្នាធ្វើសង្គ្រាមជាថ្មីជាមួយជាមួយនឹងទាហានរដ្ឋាភិបាលកម្ពុជា» ។ ស៊ឹម រៀបរាប់ថា គាត់ធ្វើនេះសម្រាប់អនាគតក្មេងទាំងពីរ ហើយអ្វីដែលគាត់ធ្វើពីមុនគាត់មិនចង់បានសំណងមកវិញទេ តែជាការអាណិតនិងស្រឡាញ់ ព្រោះក្មេងទាំងពីរនេះជាកូនកំព្រា ឪពុកម្តាយស្លាប់ដោយសារតែរបបដ៏ឃោរឃៅប៉ុល ពត» ។

នៅឆ្នាំ១៩៩៦ កងកម្លាំងខ្មែរក្រហមទាំងអស់បានធ្វើសមាហរណកម្មជាមួយរដ្ឋាភិបាលកម្ពុជា ដែលធ្វើឲ្យប្រទេសជាតិបានសុខសន្តិភាពជាថ្មី ។ ដូច្នេះ ស៊ឹម ក៏ត្រឡប់មករស់នៅភូមិបឹងរាំង ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបងវិញ ។ នៅទីនោះ ស៊ឹម មានតួនាទីជាជំទប់ឃុំទី១ ។ សព្វថ្ងៃនេះ ទោះបីជា ស៊ឹម និងប្រពន្ធមានកូនចំនួន៧នាក់ (ស្រី៣,ប្រុស៤)ក៏ដោយ ក៏គាត់និងប្រពន្ធនៅតែនឹកគិតដល់ក្មេងទាំងពីរជានិច្ច (សព្វថ្ងៃអ្នកទាំងពីរអាយុប្រហែល៣០ឆ្នាំជាង) ។ «ខ្ញុំមិនចង់បានសំណងអ្វីមកវិញទេ គ្រាន់តែចង់ដឹងថាក្មេងទាំងពីរនេះរស់នៅសុខសប្បាយប៉ុណ្ណោះ» ។ ចុងក្រោយ ស៊ឹម សំណូមពរថា ប្រសិនក្មេងទាំងពីរបានឃើញអត្ថបទនេះ សូមផ្តល់ដំណឹងឲ្យគាត់ទាំងពីរបានដឹងផង ។

**សុខ ខណ្ណៈ**

***(តមកពីទំព័រ១)***

ដំណើរទស្សនកិច្ចនេះគឺជាការរំឭកនូវស្ថានភាពស្រដៀងគ្នានឹងប្រទេសបង់ក្លាដេសអំឡុងសង្គ្រាមនៃការរំដោះឆ្នាំ១៩៧១ នៅពេលដែលប្រទេសនេះក្លាយទៅជាប្រទេសឯករាជ្យមួយដែរ ។ សុំយើងទាំងអស់គ្នាបន់ស្រន់ ព្រមទាំងបួងសួងឲ្យមានពិភពលោកដ៏រីករាយនិងសន្តិភាពមួយសម្រាប់យើងទាំងអស់គ្នា ។

***ពីខ្ញុំ សាហ៊ុគីល មេបញ្ជាការកងអាកាសប្រទេសបង់ក្លាដេស***

យើងទាំងអស់គ្នានិយាយថា «នឹងមិនកើតឡើងម្តងទៀត» ជាច្រើនលើកច្រើនសា ប៉ុន្តែយើងនៅតែប្រព្រឹត្តអំពើដ៏ឃោរឃៅទាំងនេះ ។ នៅពេលដែលយើងចេះស្រឡាញ់រាប់អានគ្នា នោះវានឹងមិនមានការកាប់សម្លាប់គ្នានោះទេ ។ «អ្វីដែលយើងជឿថាត្រូវអាចនាំយើងទៅរកការស្លាប់» ។ វាប្រាកដជាមានមធ្យោបាយល្អសម្រាប់ដោះស្រាយ ។ យើងទាំអស់គ្នាសុទ្ធតែអាចប្រព្រឹត្តអំពើទាំងនេះ ។ តើអ្នកណានឹងប្រឆាំងពួកគេ?

***ពីខ្ញុំ វីនហ្វ្រាយ ប្រទេសហូឡង់***

ទោះបីជាអក្សរមិនអាចបង្ហាញពីចំណែកមួយនៃសេចក្តីរន្ធត់របស់ប្រវត្តិសាស្ត្រក៏ដោយ ប៉ុន្តែការតាំងពិព័រណ៍ថ្មីនេះគឺជាការប្រឹងប្រែងដ៏សំខាន់និងល្អមួយនៅក្នុងទិសដៅនេះ ។ សុំឲ្យយុត្តិធម៌បម្រើឲ្យដំណើរការរបស់តុលាការនៅពេលខាងមុខនេះនិងសុំឲ្យវិញ្ញាណរបស់អ្នកស្លាប់ទៅកាន់សុគតិភព ។

***ពីខ្ញុំ ម៉ាក ប្រទេសអ៊ីរ៉ង់***

សុំអរគុណដែលបានផ្តល់ឱកាសឲ្យខ្ញុំដឹងពីប្រវត្តិសាស្ត្រដ៏ឃោរឃៅនៃប្រទេសរបស់អ្នក ។ ការរស់នៅប្រទេសកម្ពុជាគឺជាពេលវេលាដ៏ល្អបំផុតរបស់ខ្ញុំ ហើយប្រជាជននៅទីនេះក៏បែបនោះដែរ ។

***សុំឲ្យមានសំណាងល្អ ពីខ្ញុំ សានុន ប្រទេសកាណាដា***

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

# កាលប្បវត្តិសំខាន់ៗរបស់តុលាការខ្មែរក្រហម

◆ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៦ សមាគមមេធាវីកម្ពុជាប្រកាសថា សេចក្តីព្រាងច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលបំពានលើច្បាប់កម្ពុជានឹងទាមទារតួនាទីក្នុងការការពារជនសង្ស័យខ្មែរក្រហមច្រើនជាងមុនៗ លោក គី តិច ប្រធានសមាគមនេះបានគំរាមប្តឹងមេធាវីបរទេសដែលធ្វើការនៅសាលាក្តីប្រសិនបើគេមិនបំពេញតាមការទាមទាររបស់សមាគមនេះទេ ។

◆ នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៦ មន្ត្រីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជជែកពិភាក្សាគ្នាស្តីពីវិធានផ្ទៃក្នុងរបស់សាលាក្តី ។ មតិយោបល់ខាងក្រៅជាង២០ច្បាប់ស្តីពីសេចក្តីព្រាងបទបញ្ជាផ្ទៃក្នុងត្រូវបានប្រគល់ឲ្យសាលាក្តី ។

លោក អៀង សារី អាយុ៧៧ឆ្នាំ បងធំទីបីខ្មែរក្រហមមានជំងឺបេះដូង ហើយបានធ្វើដំណើរទៅទីក្រុងបាងកកដើម្បីព្យាបាលជំងឺអស់រយៈពេលជាង១សប្តាហ៍ ។

◆ នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៦ លោក គី តិច ប្រធានសមាគមមេធាវីកម្ពុជាគំរាមកំហែងប្តឹងអ្នកដែលចូលរួមក្នុងវគ្គបណ្តុះបណ្តាលរយៈពេល៥ថ្ងៃស្តីពីច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិដែលរៀបចំឡើងដោយការិយាល័យការពារក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញនិងសមាគមមេធាវីអន្តរជាតិ ។ គាត់បាននិយាយថា វគ្គបណ្តុះបណ្តាលនេះបំពានទៅលើច្បាប់ប្រទេសកម្ពុជា ហើយចាត់ទុកអ្នកដែលចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះថាជាអ្នកជ្រុលនិយម ។

◆ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៦ សមាគមមេធាវីកម្ពុជាបានបញ្ជាមិនឲ្យសមាជិកខ្លួនចូលរួមវគ្គបណ្តុះបណ្តាលដែលរៀបចំឡើងដោយការិយាល័យការពារក្តីនិងសមាគមមេធាវីអន្តរជាតិទេ ។ សមាគមមេធាវីកម្ពុជាហៅវគ្គបណ្តុះបណ្តាលនេះថា «មិនស្របច្បាប់» ។

◆ នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៦ សមាគមមេធាវីអន្តរជាតិប្រកាសពីការលុបចោលកម្មវិធីបណ្តុះបណ្តាលរបស់ខ្លួនសម្រាប់មេធាវីកម្ពុជាដោយសារការរារាំងពីសមាគមមេធាវីកម្ពុជា ។

◆ នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៦ មន្ត្រីតុលាការជាតិនិងអន្តរជាតិរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រកាសពីបរាជ័យនៃការកែសម្រួលវិធានផ្ទៃក្នុងសម្រាប់អង្គជំនុំជម្រះដោយសារការមិនឯកភាពគ្នាលើបញ្ហាសំខាន់ៗមួយចំនួន ៖
១) ការបញ្ចូលគ្នានៃច្បាប់កម្ពុជានិងស្តង់ដារអន្តរជាតិ
២) តួនាទីរបស់អង្គភាពគាំពារការការពារក្តីដែលរួមមានបញ្ហាលក្ខណៈសម្បត្តិរបស់មេធាវីការពារក្តី
៣) តួនាទីរបស់សហព្រះរាជអាជ្ញានិងផលប៉ះពាល់ទៅលើនីតិវិធីបោះឆ្នោត
៤) ប្រតិបត្តិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជា ។

◆ នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៦ លោក ប្រាដ អាដាម (Brad Adams) ប្រធានអង្គការឃ្លាំមើលសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីរិះគន់ពីការជ្រៀតជ្រែករបស់រដ្ឋាភិបាលក្នុងការបង្កើតបទបញ្ជាផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយនិយាយថាវានឹងពន្យារដំណើរការនេះ ។

លោករដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី សុខ អាន សរសេរលិខិតមួយច្បាប់ទៅអង្គការសហប្រជាជាតិសុំការពិភាក្សាដើម្បីដោះស្រាយជម្លោះដ៏ជូរចត់ស្តីពីតួនាទីរបស់អង្គភាពគាំពារការការពារក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ លិខិតមួយច្បាប់ផ្ញើទៅកាន់ នីកូឡាស មីសែល (Nicolas Michel) អគ្គលេខាធិការរងផ្នែកប្រឹក្សារបស់អង្គការសហប្រជាជាតិនៅទីក្រុងញូវយ៉ក លោក សុខ អាន និយាយថា «រដ្ឋបាល តួនាទីនិងមុខងាររបស់ផ្នែកគាំពារការការពារក្តីនៃអង្គជំនុំជម្រះវិសាមញ្ញក៏ដូចជាទំនាក់ទំនងរបស់វាជាមួយនឹងសមាគមមេធាវីកម្ពុជាមិនត្រូវបានបង្ហាញក្នុងកិច្ចព្រមព្រៀងរវាងកម្ពុជានិងអង្គការសហប្រជាជាតិទេ ។

◆ នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០០៦ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាមទារភ័ស្តុតាងនៃការចោទប្រកាន់របស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស ។ លោក ហួត វុទ្ធី ចៅក្រមនៃអង្គបុរេជំនុំជម្រះក្នុងតុលាការកម្ពុជាបានរិះគន់អង្គការឃ្លាំមើលសិទ្ធិមនុស្ស និងទាមទារភ័ស្តុតាងនៃការជ្រៀតជ្រែករបស់រដ្ឋាភិបាលកម្ពុជា ដែលត្រូវបានចោទប្រកាន់ដោយអង្គការសិទ្ធិមនុស្សអន្តរជាតិមួយនេះ ។

លោក ប្រាដ អាដាម (Brad Adams) ប្រធានអង្គការឃ្លាំមើលសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីសរសេរអ៊ីមែលមួយអះអាងថាការចោទប្រកាន់នេះត្រឹមត្រូវ ។

◆ នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៦ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាស្វាគមន៍ចំពោះបណ្តឹងរបស់ជនរងគ្រោះ ។ សហព្រះរាជអាជ្ញា រ៉ូប៊ែ ពេទីត (Robert Petit) បាននិយាយថា ជនរងគ្រោះនៃរបបខ្មែរក្រហមអាចប្តឹងសងការខូចខាតបាន ។ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារ កម្ពុជាមានប្រសាសន៍ថា អង្គភាពរបស់គាត់នឹងជួយដល់ជនរងគ្រោះដែលចាប់អារម្មណ៍ក្នុងការដាក់ពាក្យបណ្តឹងទៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

◆ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៦ លោក គាត ឈន់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសារភាពពីការពាក់ព័ន្ធរបស់គាត់ក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩) ។ គាត់បានឆ្លើយតបបែបនេះ បន្ទាប់ពីគណបក្សប្រឆាំងលោក សម រង្ស៊ី បានចោទប្រកាន់គាត់ពីបទមានតួនាទីសំខាន់ក្នុងសម័យខ្មែរក្រហម ជាទីប្រឹក្សារបស់ ប៉ុល ពត ដែលជាមេខ្លោងរបបវាលពិឃាដ ។ លោក គាត ឈន់ បាន និយាយថាគាត់ស្ម័គ្រចិត្តធ្វើជាសាក្សីនៅពេលជំនុំជម្រះក្តី ។

លោក គាត ឈន់ បានប្រាប់រដ្ឋសភាជាតិថា «ប្រសិនបើខ្ញុំត្រូវគេកោះហៅទៅឆ្លើយចំពោះមុខប្រជាជនស្តីពីអតីតកាលរបស់ខ្ញុំ ខ្ញុំនឹងឆ្លើយ» ។

◆ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៦ អ្នកច្បាប់គណបក្សប្រជាជនកម្ពុជាលោក ជាម យៀប មានប្រសាសន៍ថា មេដឹកនាំគណបក្សប្រជាជនកម្ពុជាមិនខ្លាចនឹងធ្វើជាសាក្សីនៅសាលាក្តីខ្មែរក្រហមទេពីព្រោះពួកគាត់មិនមែនជាមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហមឬអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតនៃឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅរវាងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ទេ ។

◆ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៦ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារៀបចំការពិភាក្សាតុមូលស្តីពីតួនាទីរបស់ប្រព័ន្ធផ្សព្វផ្សាយនិងសាលាក្តី ។ ការពិភាក្សានេះមានគោលបំណងធានាថា ការផ្សព្វផ្សាយព័ត៌មានរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានលក្ខណៈត្រឹមត្រូវនិងយុត្តិធម៌ ។ លោក ក្រាញ់ តូនី ប្រធានផ្នែកគ្រប់គ្រងការងារសាលាក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានប្រាប់ដល់សិក្ខាកាមថា «តំណាងឲ្យប្រទេសយើង និងជាម្ចាស់នៃអង្គជំនុំជម្រះវិសាមញ្ញ យើងចង់សរសេរដោយគោរពតាមក្រមសីលធម៌និងសីលធម៌បុគ្គលនៅពេលសរសេរពីសាលាក្តីនេះ» ។ គាត់បានបន្ថែមថា ពួកគេត្រូវតែគោរពបីចំណុច សន្តិភាព ការផ្សះផ្សាជាតិ និងយុត្តិធម៌សម្រាប់ជនរងគ្រោះ ។

អង្គការសហប្រជាជាតិឆ្លើយតបនឹងសំណូមពររបស់រាជរដ្ឋាភិបាលបើកការពិភាក្សាដើម្បីដោះស្រាយជម្លោះដ៏ជូរចត់ស្តីពីតួនាទីរបស់អង្គភាពគាំពារការការពារក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញនិងប្រធានមេធាវីការពារក្តី លោក រូបឺត ស្កីលបិច ។

នៅក្នុងការស្រង់អត្ថបទឆ្លើយតបជាផ្លូវការរបស់អង្គការសហប្រជាជាតិដែលផ្តល់ដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកាលពីថ្ងៃអង្គារ នីកូឡាស មីសែល (Nicolas Michel) អគ្គលេខាធិការរងទទួលបន្ទុកផ្នែកច្បាប់របស់អង្គការសហប្រជាជាតិនៅទីក្រុងញូវយ៉កនិយាយថា អង្គការអន្តរជាតិចូលរួមរំលែកការព្រួយបារម្ភរបស់រាជរដ្ឋាភិបាលកម្ពុជា ហើយមានទំនុកចិត្តថាបញ្ហាទាំងនេះនឹងអាចដោះស្រាយបាន ។ លោក មីសែល បាននិយាយសំដៅដល់របាយការណ៍មួយរបស់អង្គការសហប្រជាជាតិកាលពីខែធ្នូ ឆ្នាំ២០០៣ ថា អង្គការនឹងផ្តល់ជំនួយនិងការគាំទ្រជាមូលដ្ឋានផ្នែកច្បាប់ ។

◆ នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០០៧ ក្រុមហ៊ុនមៃក្រូសហ្សិន្ធបុរី បោះជំហានដំបូងក្នុងនាមជាផ្នែកឯកជនជួយបំពេញកង្វះថវិការបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែល

បានបរិច្ចាគប្រាក់១សែនដុល្លារអាមេរិកដល់ភាគីអង្គការសហប្រជាជាតិដោយគ្មានលក្ខខណ្ឌ ។

◆ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៧ សេវាអភិវឌ្ឍរបស់ប្រទេសអាល្លឺម៉ង់ផ្តល់ជំនួយ៣សែនដុល្លារអាមេរិកដល់កម្មវិធីសហគមន៍សម្រាប់ការគាំទ្រសាលាក្តីខ្មែរក្រហម ។ ប្រាក់ជំនួយនេះមិនមែនបរិច្ចាគទៅក្នុងថវិកាសាលាក្តីដោយផ្ទាល់នោះទេ ប៉ុន្តែផ្តល់តាមរយៈដៃគូក្នុងស្រុករបស់ខ្លួនគឺមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ។

◆ នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៧ មជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលឯកសារទាក់ទងនឹងសម័យខ្មែរក្រហមចំនួនជាង ៤០០គីឡូក្រាម ដែលបានរក្សាទុកជិត៣ទសវត្សរ៍នៅប្រទេសស៊ុយអ៊ែដ ។ ឯកសារទាំងនោះមានជាភាសាខ្មែរអង់គ្លេស បារាំង និងស៊ុយអ៊ែត ។

◆ នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៧ អង្គការដែលមានទីតាំងនៅទីក្រុងញូវយ៉ក ឈ្មោះ Open Society Justice Initiative (OSJI) បានចេញសេចក្តីថ្លែងការណ៍មួយចោទប្រកាន់ថាចៅក្រមនិងមន្ត្រីតុលាការកម្ពុជានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រព្រឹត្តអំពើពុករលួយ ។ អង្គការនេះបានអះអាងថា ភាគីកម្ពុជាត្រូវកាត់ប្រាក់បៀវត្សរ៍មួយចំណែកទៅឲ្យមន្ត្រីរដ្ឋាភិបាលដើម្បីបានកាន់តំណែង ។ អង្គការ (OSJI) ក៏បានអំពាវនាវដល់ម្ចាស់ជំនួយនិងសហគមន៍អន្តរជាតិឲ្យស៊ើបអង្កេតការចោទប្រកាន់ពីអំពើពុករលួយដោយម៉ត់ចត់ ។

◆ នៅថ្ងៃទី៨ ខែមីនា ឆ្នាំ២០០៧ ចៅក្រមកម្ពុជារបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានសំណូមពរឲ្យអង្គការ (OSJI) កែតម្រូវសេចក្តីថ្លែងការណ៍ដែលចេញកាលពីថ្ងៃទី១៤



មជ្ឈមណ្ឌលឯកសារកម្ពុជាចាក់ផ្សាយឡើងវិញពីសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហមជូនប្រជាជនទស្សនា

ខែកុម្ភៈ ឆ្នាំ២០០៧ ដែលចោទប្រកាន់ថា ភាគីកម្ពុជាពុករលួយ ។ ចៅក្រមកម្ពុជាដែលតែងតាំងដោយអង្គជំនុំជម្រះបានអះអាងថា ការចោទប្រកាន់ដែលគ្មានភស្តុតាងបានផ្សព្វផ្សាយយ៉ាងទូលំទូលាយនៅក្នុងប្រទេសនិងអន្តរជាតិដែលបង្កឲ្យមានការយល់ច្រឡំជាសាធារណៈ និងបង្ខូចកិត្តិយស និងភាពស្មោះត្រង់របស់ពួកគាត់ ។

◆ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៧ បន្ទាប់ពីការប្រជុំរយៈពេល១០ថ្ងៃស្តីពីវិធានផ្ទៃក្នុងគណៈកម្មាធិការត្រួតពិនិត្យបានសន្និដ្ឋានថា ចំណុចមិនឯកភាពដែលនៅសេសសល់ទាំងអស់ត្រូវបានដោះស្រាយរួចហើយ ទោះបីការកែតម្រូវតិចតួចមិនទាន់បានធ្វើនៅឡើយក៏ដោយ ។

បញ្ហាចម្បងមួយទៀតដែលមិនទាន់បានចែងក្នុងវិធានផ្ទៃក្នុងគឺមេធាវីបរទេសត្រូវបង់ថ្លៃចុះឈ្មោះដល់ទៅ៥.០០០ដុល្លារ



អាមេរិកឲ្យសមាគមមេធាវីព្រះរាជាណាចក្រកម្ពុជាដើម្បីចូលរួមក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ចៅក្រមអន្តរជាតិបានបដិសេធសំណើនិងបានអះអាងថា រឿងនេះគឺមិនអាចទទួលយកបានទេ ហើយវាប៉ះពាល់ដល់សិទ្ធិជនជាប់ចោទនិងជនរងគ្រោះក្នុងការជ្រើសរើសមេធាវីរបស់ខ្លួន ។ សមាគមមេធាវីព្រះរាជាណាចក្រកម្ពុជាត្រូវបានសុំឲ្យពិចារណាការសម្រេចចិត្តឡើងវិញឲ្យបានឆាប់ដើម្បីឲ្យអង្គជំនុំជម្រះវិសាមញ្ញធ្វើការប្រជុំពេញអង្គស្តីពីការកែតម្រូវវិធានផ្ទៃក្នុងនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៧ ។

◆ នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០០៧ ចៅក្រមជាតិចំនួន១៥រូបរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសរសេរលិខិតមួយច្បាប់ឆ្លើយតបទៅភាគីអន្តរជាតិនៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០០៧ ។ លិខិតនេះមានគោលបំណងជំរុញឲ្យចៅក្រមអន្តរជាតិពិចារណាឡើងវិញពីពហិការនៃការប្រជុំពេញអង្គដែលគ្រោងធ្វើនៅថ្ងៃទី៣០ ខែមេសា ដើម្បីកែតម្រូវសេចក្តីព្រាងវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងក្នុងគោលបំណងឆ្លើយតបទៅនឹងសំណើដែលសុំដកសមាគមមេធាវីកម្ពុជាចេញពីការងារអង្គជំនុំជម្រះវិសាមញ្ញ ។ ចៅក្រមជាតិយល់ឃើញថា ទង្វើនេះមិនស្របទៅតាមចំណុចសំខាន់និងការអនុវត្តកិច្ចព្រមព្រៀងនិងច្បាប់នៃការបង្កើតអង្គជំនុំជម្រះវិសាមញ្ញទេ ។ ចៅក្រមជាតិក៏បានចង្អុលបង្ហាញផងដែរថាថ្លៃចុះឈ្មោះដែលកំណត់ដោយសមាគមមេធាវីកម្ពុជាមិនមានចែងនៅក្នុងវិធានផ្ទៃក្នុងទេ ដូច្នេះរឿងនេះមិនមែនជាហេតុផលដើម្បីពន្យារការកែតម្រូវនោះឡើយ ។

◆ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៧ សមាគមមេធាវីកម្ពុជាបន្ទាបថ្លៃចុះឈ្មោះពី៥.០០០ដុល្លារអាមេរិកក្នុងមួយឆ្នាំមកត្រឹម៥០០ដុល្លារសម្រាប់រយៈពេលនៃដំណើរការសាលាក្តីខ្មែរក្រហមទាំងស្រុងតែម្តង ។

◆ នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៧ អ្នកស្រី ជា លាង សហព្រះរាជអាជ្ញាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានប្រសាសន៍ថា សាលាក្តីខ្មែរក្រហមអាចនឹងត្រួតពិនិត្យញត្តិជនរងគ្រោះជាង១លានញត្តិ ដែលបានដាក់ប្តឹងនៅដើមទសវត្សរ៍ឆ្នាំ១៩៨០ ដោយបន្ថែមថា ពុំមានច្បាប់ណាហាមឃាត់សាលាក្តីមិនឲ្យទទួលញត្តិទាំងនោះទេ ។

◆ នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧ វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញត្រូវបានកែតម្រូវជាឯកច្ឆន្ទបន្ទាប់ពីការចរចាអស់រយៈពេលជិតមួយឆ្នាំ ។ បញ្ហាដែលមិនអាចដោះស្រាយក្នុងអង្គប្រជុំលើកមុនឥឡូវត្រូវបានដោះស្រាយ ដោយរួមមានការធានាស្តីពីសិទ្ធិនិងការចូលរួមរបស់ជនរងគ្រោះដែលមានសិទ្ធិធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែអាចទទួលបានតែសំណងសមូហភាព និងសំណងមិនមែនជាសាច់ប្រាក់ ។

◆ នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៧ កិច្ចប្រជុំមួយរវាងមន្ត្រីមកពីអង្គការកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិនិងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានធ្វើឡើងដើម្បីពិភាក្សាពីអនុសាសន៍របស់អង្គការកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ

*បន្ទាប់ពីធ្វើសវនកម្មផ្នែកធនធានមនុស្សរបស់កម្ពុជា ។ អនុសាសន៍មួយចែងថា «ប្រាក់បៀវត្សរ៍របស់បុគ្គលិកកម្ពុជាត្រូវកាត់បន្ថយជិតពាក់កណ្តាល ដោយសារកង្វះថវិកា» ។*

◆ *នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៧ ភាគីកម្ពុជានៃអង្គជំនុំជម្រះវិសាមញ្ញបានទទួលយកអនុសាសន៍ទាំងអស់នោះ ហើយបានចាប់ផ្តើមអនុវត្តរួចហើយ ។*

◆ *នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ សហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រគល់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដំបូងរបស់ខ្លួនទៅចៅក្រមស៊ើបអង្កេត ។ វាបង្ហាញពីហេតុការណ៍ដែលបង្កឧក្រិដ្ឋកម្ម អ្នកដែលត្រូវសង្ស័យថាជាអ្នកទទួលខុសត្រូវឧក្រិដ្ឋកម្មទាំងនោះ ហើយសំណូមពរឲ្យសហចៅក្រមស៊ើបអង្កេតធ្វើការស៊ើបអង្កេតឧក្រិដ្ឋកម្មនិងជនសង្ស័យទាំងនោះ ។ ដីកាសន្និដ្ឋាននេះថ្លែងថា «ស្របតាមការស៊ើបអង្កេតជាបឋម សហព្រះរាជអាជ្ញាបានកំណត់អត្តសញ្ញាណនិងប្រគល់ឯកសារស៊ើបអង្កេតអង្គហេតុចំនួន២៥ផ្សេងគ្នាស្តីពីការសម្លាប់ ធ្វើទារុណកម្ម បង្ខំឲ្យផ្លាស់ទីលំនៅ ឃុំឃាំងមិនស្របច្បាប់ បង្ខំឲ្យធ្វើពលកម្ម និងបំបាត់សាសនា នយោបាយ និងជនជាតិដើម្បីធ្វើជាភស្តុតាងនៃឧក្រិដ្ឋកម្មដែលធ្វើឡើងក្នុងការអនុវត្តផែនការឧក្រិដ្ឋកម្មនេះ ។ ការចោទប្រកាន់ជាក់ស្តែងមានឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ ការបំពានដ៏ធ្ងន់ធ្ងរលើសន្ធិសញ្ញាទីក្រុងហ្សឺណែវ មនុស្សឃាត ការធ្វើទារុណកម្ម និងការបំបាត់សាសនា ។ សហព្រះរាជអាជ្ញាបានកំណត់អត្តសញ្ញាណជនសង្ស័យ៥រូបដែលបានប្រព្រឹត្ត ជួយសមគំនិត ឬដែលទទួលខុសត្រូវខ្ពស់ក្នុងឧក្រិដ្ឋកម្មនេះ ។ ដើម្បីគាំទ្រការចោទប្រកាន់នេះ សហព្រះរាជអាជ្ញាបានប្រគល់ឯកសារជាង១.០០០ច្បាប់ (ស្មើ១៤.០០០ទំព័រ) ទៅកាន់សហចៅក្រមស៊ើបអង្កេត ដោយរួមមានសេចក្តីថ្លែងរបស់ភាគីទីបី និងកំណត់ត្រាសាក្សីជាង៣៥០រូប បញ្ជីនៃសាក្សីសំខាន់ៗចំនួន៤០រូប ឯកសារសម័យកម្ពុជាប្រជាធិបតេយ្យរាប់ពាន់ទំព័រនិងទីតាំងរណ្តៅសាកសពជាង៤០កន្លែង ។*

◆ *នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ លោក នួន ជា ទាយថាគាត់ប្រាកដជាមនុស្សម្នាក់ក្នុងចំណោមបេក្ខភាព៥នាក់ដែលកំណត់ដោយសហព្រះរាជអាជ្ញាទៅកាន់សាលាក្តីខ្មែរក្រហម ។ លោកប្រាប់កាសែតខេមបូឌាដែលីថា សាលាក្តីនឹងក្លាយជាសមរភូមិរបស់គាត់ ។ គាត់បានអះអាងថា ពុំមានគោលនយោបាយសម្លាប់ប្រជាជននោះទេ និងបានបន្ថែមថា «កុំព្រួយបារម្ភ ខ្ញុំនឹងទៅកាន់តុលាការនៅពេលគេត្រូវការខ្ញុំ ហើយខ្ញុំនឹងបញ្ជាក់ប្រាប់អ្វីៗឲ្យបានច្បាស់នៅតុលាការ និងបញ្ឈប់ការចោទប្រកាន់ និងឈប់ឲ្យប្រជាជននិយាយថាខ្មែរក្រហមជាបិសាច» ។*

◆ *នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៧ លោក អៀង វុធ អភិបាលរងក្រុងប៉ៃលិន និងជាកូនប្រុសរបស់លោក អៀង សារី និងអ្នកស្រី អៀង ធីរិទ្ធ រិះគន់កាសែតរស្មីកម្ពុជាដែលបានទាយថា ឪពុកម្តាយរបស់គាត់ជាមនុស្សពីរនាក់ក្នុងចំណោមមនុស្សប្រាំនាក់នៅក្នុងបញ្ជីសម្ងាត់របស់សហព្រះរាជអាជ្ញាដែលត្រូវចោទប្រកាន់នៅមុខសាលាក្តីខ្មែរក្រហម ។ គាត់រំពឹងថាសាលាក្តីនេះមិនមែនជាយុត្តិធម៌សម្រាប់តែអ្នកឈ្នះនោះទេ ។ គាត់បានថ្លែងថា «យុត្តិធម៌គឺនៅជាមួយអ្នកដែលខ្លាំងតែប៉ុណ្ណោះ» ។*

◆ *នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ ឌុច ត្រូវបានបញ្ជូនជាផ្លូវការទៅកាន់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងជាជនសង្ស័យដំបូងដែលត្រូវឃុំខ្លួនដោយសាលាក្តី ។*

◆ *នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ ឌុច ត្រូវបានចោទប្រកាន់ជាផ្លូវការពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយសហចៅក្រមស៊ើបអង្កេតនៅមុខអង្គជំនុំជម្រះវិសាមញ្ញ ។*

*ឈ្មោះៈ កាំង ហ្កេកអ៊ាវ*

*ថ្ងៃខែឆ្នាំកំណើតៈ ១៥ កុម្ភៈ ១៩៤៥*

*មុខរបរៈ គ្រូបង្រៀនគណិតវិទ្យា ខេត្តកំពង់ធំ*

◆ *នៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៧ មេធាវីរបស់ ឌុច ហ្វ្រង់ស័រ រូស មេធាវីជនជាតិបារាំង ដែលធ្លាប់ការពារក្តីភេរវករនៃការវាយប្រហារថ្ងៃទី១១ ខែកញ្ញា ត្រូវបានតែងតាំងឲ្យធ្វើជាមេធាវីបរទេសធ្វើការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។*

**(នៅមានត)**

**គាត លក្ខិណា**

# ដំណើរទស្សនកិច្ចរបស់ខ្ញុំទៅស្រុកអន្លង់វែង

ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ខ្ញុំមានសំណាងដែលបានរួមដំណើរជាមួយក្រុមគម្រោងជំរុញឲ្យមានការទទួលខុសត្រូវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទៅកាន់ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ ក្រុមការងាររួមមាន ឡុង ដានី, ឃិន ឆាយ, សុខ វណ្ណៈ, និង ហ៊ុន សុធានី ។ ក្រុមមានភាពវៃឆ្លាតនេះបានអនុញ្ញាតឲ្យ រ៉េនដល ឌីហ្វាល់កូ និងខ្ញុំរួមដំណើរជាមួយដោយមិនមានតវ៉ាឬបដិសេធរំខានទាល់តែសោះ ហើយ ធុញថប់ឡើយ ដោយជិះពេញកៅអីខាងក្រោយធ្វើដំណើររយៈពេល៨ម៉ោងទៅជាយដែននៃប្រទេសកម្ពុជា ។ គោលបំណងនៃទស្សនកិច្ចនេះគឺដើម្បីស្រាវជ្រាវរកអតីតកម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមដែលបានប្រព្រឹត្តអំពើល្អនៅចន្លោះឆ្នាំ១៩៧៥ដល់១៩៧៩ និងក្រោយមកទៀត ។

សម្រាប់ខ្ញុំនិង រ៉េនដល ទស្សនកិច្ចនេះគឺជាឱកាសពិសេសមួយដែលធ្វើឲ្យយើងបានសន្ទនាជាមួយកម្មាភិបាលខ្មែរក្រហមផ្ទាល់អំពីបទពិសោធន៍របស់គាត់ ។ ការពិភាក្សាមិនគ្រាន់តែដើម្បីជួបមុខផ្ទាល់ជាមួយអ្នកដែលយើងដឹងថាជាជនដៃដល់នោះទេ ប៉ុន្តែវាក៏ផ្តោតទៅលើអំពីល្អរបស់ខ្មែរក្រហមជាជាងភាពសាហាវឃោរឃៅដែលគេបានដឹងឮគ្រប់គ្នានៅក្នុងរបបខ្មែរក្រហមដែរ ។ ជាងនេះទៅទៀត ឥទ្ធិពលទាំងអស់នេះបានកើតឡើងនៅក្នុងស្រុកអន្លង់វែង នាតំបន់ភ្នំ ទិសពាយ័ព្យប្រទេសជាប់ព្រំប្រទល់ប្រទេសថៃ ជាកន្លែងដែលខ្មែរក្រហមរត់ទៅរស់នៅបន្ទាប់ពីរបបនេះបានដួលរលំក្នុងឆ្នាំ១៩៧៩ ហើយជាកន្លែងដែលហៅថា «មូលដ្ឋានចុងក្រោយរបស់ខ្មែរក្រហម» ។

រយៈពេលជាងមួយសប្តាហ៍ ក្រុមការងារបានសម្ភាសជាផ្លូវការជាមួយមនុស្ស៨នាក់ ហើយបានធ្វើការសន្ទនាធម្មតាជាច្រើនជាមួយអតីតកម្មាភិបាលខ្មែរក្រហមដែលជាធម្មតាមានការមមាញឹក ឬមានការមន្ទិលសង្ស័យពេលដែលយើងថតសំឡេងគាត់ ។ បទសម្ភាសបានធ្វើនៅកន្លែងផ្សេងៗគ្នាដូចជានៅសាលាភាសាអង់គ្លេស សាលាឃុំនិងនៅគេហដ្ឋាន ។ ប៉ុន្តែទិដ្ឋភាពទាំងអស់នេះជាកន្លែងមួយដែលជាញឹកញាប់ធ្វើឲ្យកម្មាភិបាលខ្មែរក្រហមពិបាកធ្វើការសម្រេចចិត្ត លាក់បាំងនូវអារម្មណ៍របស់គាត់និងគំនិតរបស់គាត់ផងដែរ ។

ម្នាក់ក្នុងចំណោមមនុស្សដែលយើងបានសម្ភាសដំបូងគឺ លោក ក ។ លោក ក ជាបុរសដែលមានសំឡេងស្រទន់ អាយុ៥៣ ឆ្នាំ បានចូលបដិវត្តន៍ខ្មែរក្រហមក្នុងឆ្នាំ១៩៧០ តាមការស្នើសុំ



កម្មាភិបាលខ្មែរក្រហមនៅវាលស្រែ

របស់ប្រធានភូមិ ។ ពេលនោះ គាត់មានអាយុ១៥ឆ្នាំ ។ នៅក្នុងឆ្នាំ ១៩៧៣ គាត់ត្រូវបានបញ្ជូនឲ្យទៅធ្វើជាកងឈ្លបនៅភ្នំប្រុស ភ្នំស្រី ខេត្តកំពង់ចាម ហើយមួយឆ្នាំក្រោយមកត្រូវបានដំឡើងតំណែងជាប្រធានកងអនុសេនាតូច ។ នៅពេលដែលកងកម្លាំងខ្មែរក្រហមដណ្តើមបានទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ ក បានចំណាយពេល២សប្តាហ៍នៅក្នុងទីក្រុងម៉ុំវត្តភ្នំ ។ ក្រោយមក គាត់ត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅកំពង់ផែកំពង់សោម ដែលជាកន្លែងគាត់មើលការខុសត្រូវកម្មករ ផ្ទុកទំនិញនិងជញ្ជូនទំនិញចេញពីនាវារបស់ចិន ។

អំពើល្អដែលគាត់បានធ្វើដំបូង គឺការផ្តល់អាហារទៅឲ្យអ្នកភូមិដែលមានការអត់ឃ្លានទាំងនៅមុននិងក្រោយឆ្នាំ១៩៧៩ ។ យ៉ាងណាក៏ដោយ ក្នុងនាមជាសមាជិកពីមុននៃអង្គការបដិវត្តន៍និងជាកម្មាភិបាលខ្មែរក្រហម បទពិសោធន៍របស់គាត់មិនឃើញថាមានស្ថានភាពរស់នៅស្រួលជាងអ្នកធម្មតានោះទេ ។ នៅឆ្នាំ ១៩៧៧ កងរបស់គាត់ត្រូវបានបញ្ជាឲ្យត្រឡប់មកភ្នំពេញវិញ នៅខណៈដែលគាត់កំពុងលក់ទំនិញនៅតាមបណ្តោយព្រំដែនខ្មែរ-ថៃ ពីព្រោះកងរបស់គាត់ជាផ្នែកសំខាន់មួយក្នុងរបបនេះ ដើម្បីកម្ចាត់សត្រូវខាងក្នុងនៅភូមិភាគឧត្តរដែលក្បត់នឹងអង្គការ ក៏ដូចជាបក្ស ។ បន្ទាប់ពីនោះ គាត់ត្រូវបានបង្ខំឲ្យទៅធ្វើស្រែចម្ការរហូតដល់ខែមករា ឆ្នាំ១៩៧៩ ។ ក្រោយមកទៀត គាត់បានភៀសខ្លួនទៅរស់នៅក្នុងព្រៃជិតស្រុកអន្លង់វែង ពេលដែលកងទ័ពវៀតណាមបានផ្តួលរំលំរបបខ្មែរក្រហម ។ ពេលដែលខ្ញុំបានសួរគាត់ថាហេតុអ្វីបានជាគាត់រត់ចូលព្រៃ គាត់បានប្រាប់ថា ទោះជាខ្មែរក្រហមបានប្រព្រឹត្តអាក្រក់មកលើប្រជាជនក៏ដោយ ក៏គាត់មិនបានទទួលយកការរស់នៅក្រោមការគ្រប់គ្រងរបស់ខ្មាំងបរទេសដែរ ។ ផ្ទុយមកវិញ គាត់បានបន្តរស់នៅក្នុងព្រៃរហូតដល់ទសវត្សរ៍ ៩០ បើទោះបីវាផ្ទុយនឹងបំណងរបស់ម្តាយដែលសុំឲ្យគាត់ដាក់កាំភ្លើងចុះ ហើយត្រឡប់មកភូមិវិញក៏ដោយ ។ នៅពេលភ្លៀងធ្លាក់មកលើដំបូលស័ង្កសីនៃថ្នាក់រៀនដែលមានភាពងងឹតមិនសូវច្បាស់ ហើយដែលយើងកំពុងអង្គុយក្នុងនោះវាធ្វើឲ្យខ្ញុំដឹងថាគាត់បានចំណាយពេលជាងពាក់កណ្តាលជីវិតរបស់គាត់នៅក្នុងសង្គ្រាម ។

ប្រជាជន៧នាក់ទៀតដែលយើងបានសម្ភាសន៍ ហើយដែលមានតួនាទីផ្សេងៗគ្នានៅក្នុងនិងក្រោយរបបខ្មែរក្រហម រួមមានយោធាខ្មែរក្រហម គណៈស្រុក ប្រធានពេទ្យ បុគ្គលិកពេទ្យ ប្រធានរោងចក្រ ។ សមត្ថភាពរបស់គាត់ក្នុងការធ្វើអំពើល្អក្នុងរបបនោះហាក់ដូចជាអាស្រ័យទៅលើកម្រិតនៃអំណាច ។ ស្ទើរតែទាំងអស់ក្នុងចំណោមអ្នកទាំងនេះបានរៀបរាប់ពីការចែករំលែកអាហារជាមួយនឹងប្រជាជនដែលអត់មានអាហារហូប ។ ចំណែកអ្នកដែលមានឋានៈខ្ពស់ៗដូចជាគណៈស្រុកអាចមានលទ្ធភាពជួយប្រជាជនច្រើនជាង ។ ឧទាហរណ៍ ស្ត្រីម្នាក់ អាយុ៦៥ឆ្នាំ ដែលធ្វើជាគណៈស្រុកបាននិយាយប្រឆាំងទៅនឹងបញ្ជារបស់គណៈកម្មាធិការមជ្ឈិមបក្សកម្ពុជាប្រជាធិបតេយ្យ ដើម្បីផ្គង់ផ្គង់កូតាស្បៀងអាហារក្នុងគោលបំណងបង្កើនរបបអាហារសម្រាប់ប្រជាជនអត់ឃ្លាននៅក្នុងស្រុករបស់គាត់ ។ គាត់ក៏បានបដិសេធចំពោះការស្នើសុំពីរយ៉ាងរបស់គណៈតំបន់ផងដែរ ដើម្បីចាប់ខ្លួននិងបញ្ជូនបុរសពីរនាក់នៅក្នុងឃុំរបស់គាត់ដែលគាត់ជឿថា ពីរនាក់នេះជាមនុស្សស្លូតត្រង់មិនបានប្រព្រឹត្តឧក្រិដ្ឋកម្មដូចដែលត្រូវបានចោទប្រកាន់ទេ ហើយអ្នកទាំងពីរស្ទើរតែត្រូវបានយកទៅសម្លាប់ទៀតផង ។ ទោះបីជាគាត់បានអះអាងថាមានប្រជាជនតិចបំផុតស្លាប់នៅក្រោមការគ្រប់គ្រងរបស់គាត់ ហើយប្រជាជនលែងមានការឈឺចាប់ទៀតក៏ដោយ ប៉ុន្តែបុគ្គលិកម្នាក់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលរស់នៅស្រុករបស់គាត់បានបដិសេធយ៉ាងដាច់អហង្ការចំពោះអត្ត-ចរិតដ៏សុទិដ្ឋិនិយមរបស់គាត់នេះ ។

នៅដើមដំបូងនៃដំណើរទស្សនកិច្ចនេះ ខ្ញុំរំពឹងថានឹងចំណាយពេលមួយសប្តាហ៍និយាយជាមួយកម្មាភិបាលខ្មែរក្រហម ។ ខ្ញុំក៏បានរំពឹងថានឹងស្តាប់ការនិយាយកុហករបស់កម្មាភិបាលខ្មែរក្រហមដែលបានប្រាប់ដើម្បីសម្រាលនូវទោសកំហុសចំពោះតួនាទីរបស់ពួកគេនៅក្នុងប្រវត្តិសាស្ត្រកម្ពុជាដ៏ខ្មៅងងឹតនេះ ។ ខណៈពេលដែលខ្ញុំកំពុងតែស្វែងយល់ពីការពិតរបស់កម្មាភិបាលខ្មែរក្រហម ខ្ញុំស្ទើរតែភាន់ភាំងជាមួយនឹងការមិនទទួលកំហុសនៅពេលដែលអ្នកទាំងនេះនិយាយពីរឿងរ៉ាវរបស់ពួកគេ ។ ក្រោយពីបានយល់អំពីអំពើសាហាវព្រៃផ្សៃ បទសម្ភាសន៍នេះធ្វើឲ្យខ្ញុំមានភាពច្របូកច្របល់ចំពោះការពិតនៃប្រវត្តិសាស្ត្រដ៏ស្មុគស្មាញរបស់ជនដៃដល់និងជនរងគ្រោះ ។ **ចារ៉េត ឌ័តឃីនស៍**

# ការសម្លាប់រង្គាលនៅភូមិភាគបូព៌ា

## របាយការណ៍ការងារនៅខេត្តព្រៃវែងរបស់ក្រុមការិយាល័យព័ត៌មានសាធារណៈ

ចាប់ពីថ្ងៃទី៨ដល់ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៨ ក្រុមការងារការិយាល័យព័ត៌មានសាធារណៈរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានចុះទៅធ្វើការនៅឃុំក្អឿងរាយ ស្រុកកញ្ជៀច ខេត្តព្រៃវែង ។ ក្រុមការងារបានយកភាពយន្តឯកសារចំនួនពីរមានចំណងជើងថា «នៅក្រោយជញ្ជាំងមន្ទីរស-២១» និង «ដំណើរទៅកាន់យុត្តិធម៌» ដើម្បីបញ្ចាំងឲ្យអ្នកភូមិទស្សនា ។ ព្រះសង្ឃ យាយជី អ្នកភូមិ ព្រមទាំងក្មេងតូចៗបានចូលរួមទស្សនាខ្សែភាពយន្តនេះហើយ យើងក៏បានចែកទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅការណែនាំបំភ្លឺអំពីអង្គជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមចំនួន៧០ក្បាលទៅដល់អ្នកភូមិដើម្បីអានដែរ ។ គោលបំណងនៃការបញ្ចាំងខ្សែភាពយន្តនេះគឺដើម្បីឲ្យប្រជាជននៅជនបទដឹងអំពីដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងលើកទឹកចិត្តឲ្យអ្នកភូមិនិយាយអំពីបទពិសោធន៍របស់គាត់នៅក្នុងរបបប៉ុល ពត ព្រមទាំងស៊ើបសួរអំពីការរំលោភផ្លូវភេទនៅក្នុងរបបនេះផង ។

### ប្រវត្តិតំបន់

នៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ខេត្តព្រៃវែង ស្វាយរៀង ភាគខាងកើតខេត្តកំពង់ចាម និងស្រុកឆ្លូងក្នុង ខេត្តក្រចេះគឺស្ថិតនៅក្នុងភូមិភាគបូព៌ា ។ ព្រៃវែងមានឈ្មោះថា តំបន់២២ ហើយដោយតំបន់នេះស្ថិតនៅជាប់ព្រំដែនប្រទេសវៀតណាមក៏ក្លាយទៅជាគោលដៅនៃការសម្លាប់យ៉ាងរង្គាលនៅពេលដែលរបបខ្មែរក្រហមជិតដួលរលំ ។ ព្រំដែនជាប់ភ្នំដើងអណ្តែង និងត្រពាំងផ្លុងគឺជាសមរភូមិមួយ ។ ក្រុមការងារបាននិយាយជាមួយអ្នកភូមិខ្លះដែលធ្លាប់បានប្រយុទ្ធជាមួយវៀតណាមនៅក្នុងឃុំនេះ ។ អ្នកភូមិម្នាក់មកពីភូមិក្អឿងរាយបានរៀបរាប់ពីទិដ្ឋភាពដែលទ័ពខ្មែរក្រហមត្រូវបានបញ្ជូនពីភូមិភាគនិរតីនិងភូមិភាគបូព៌ាដើម្បីការពារតំបន់ព្រំដែន ។ នោះគឺជាលើកដំបូងដែលកម្មាភិបាលភូមិភាគនិរតីលេចមុខនៅតំបន់នោះ ។

ក្រោមការដឹកនាំរបស់ខ្មែរក្រហម តំបន់ដែលធ្លាប់តែមានសន្តិភាពបានក្លាយទៅជាច្របូកច្របល់ ។ ការផ្លាស់ប្តូរកម្មាភិបាលភូមិភាគបូព៌ាដោយកម្មាភិបាលភូមិភាគនិរតី និងការសម្លាប់រង្គាលបានកើតឡើងនិងបន្តរហូតដល់ការចូលមកដល់របស់កងទ័ពវៀតណាមនៅឆ្នាំ១៩៧៩ ។ នៅចុងឆ្នាំ១៩៧៧ និង១៩៧៨ កម្មាភិបាលជាន់ខ្ពស់ភូមិភាគបូព៌ាជាច្រើនត្រូវបានផ្លាស់ប្តូរពីសមរភូមិនិងសហករណ៍ បន្ទាប់មកត្រូវបានសម្លាប់ចោល ។ កម្មាភិបាលភូមិភាគណាដែលមានជាប់ពាក់ព័ន្ធនឹងកម្មាភិបាលជាន់ខ្ពស់ឬក៏ធ្លាប់មានសកម្មភាពមុនពេលមានការបោសសម្អាតនៅភូមិភាគបូព៌ាគឺជាទិសដៅនៃការសម្លាប់ ។

### ការតស៊ូបដិវត្តន៍

បន្ទាប់ពីទម្លាក់សម្តេច សីហនុ នៅឆ្នាំ១៩៧០ ជនកុម្មុយនីស្តកម្ពុជាបានប្រើប្រាស់ឱកាសនេះដើម្បីពង្រឹងអំណាច ហើយជំរុញឲ្យព្រះអង្គអំពាវនាវប្រជាជនកសិករកម្ពុជាឲ្យក្រោកឡើងដណ្តើមអំណាចពីលន់ នល់ មកវិញ ។ ដោយសង្ឃឹមថាព្រះអង្គនឹងត្រឡប់មកដឹកនាំប្រទេសវិញ ប្រជាជនកម្ពុជាដែលនៅជនបទបានចាកចេញពីផ្ទះនិងគ្រួសារដើម្បីចូលបម្រើបដិវត្តន៍និងកងទ័ព ។ ជាងនេះទៅទៀត ការវាយប្រហាររបស់អាមេរិកនៅអំឡុងពេលនោះបានបង្ខំឲ្យប្រជាជនជាច្រើនចាកចេញពីភូមិហើយរត់ចូលព្រៃ ។ ជាឧទាហរណ៍ ដោយរងសម្ពាធពីការទម្លាក់គ្រាប់បែកនិងការអំពាវនាវជាច្រើនលើកច្រើនសារបស់ខ្មែរក្រហមឲ្យចូលបម្រើបដិវត្តន៍ ជួ ដេង អាយុ៦២ឆ្នាំ និងអ្នកជិតខាងរបស់គាត់នៅឃុំក្អឿងរាយបានរត់ចូលព្រៃ ហើយចូលរួមជាមួយខ្មែរក្រហម ។

បន្ទាប់ពីខ្មែរក្រហមទទួលបានជ័យជម្នះទៅលើរដ្ឋាភិបាលលន់ នល់ ប្រទេសទាំងមូលមានការផ្លាស់ប្តូរ ។ ក្តីសង្ឃឹមថាសម្តេចសីហនុ នឹងឡើងកាន់អំណាចវិញបានសាបរលាបខណៈពេលដែលរដ្ឋាភិបាលថ្មីប្រកាសលុបបំបាត់ក្រដាសប្រាក់ មេដឹកនាំបដិវត្តន៍ ហ៊ូ នឹម និង ហ៊ូ យន់ ត្រូវបានសម្លាប់ ហើយមាន ប៉ុល ពត ដែលជាអ្នកដឹកនាំប្រទេសថ្មី ។ ជួ ដេង និយាយពីស្ថានភាពធ្លាក់

ដុនដាប នៅក្នុងតំបន់ដែលគាត់គ្រប់គ្រងថា ការរស់នៅរបស់អ្នកភូមិត្រូវបានផ្លាស់ប្តូរទៅជាហូបរួមនិងធ្វើការជាលក្ខណៈសហករណ៍ ដែលធ្វើឲ្យជីវិតរបស់គាត់ជួបនឹងការលំបាកជាខ្លាំង ។ នៅពេលនោះ ជួ ផេង ត្រូវបានចាត់តាំងឲ្យធ្វើជាប្រធានសហករណ៍ទទួលបន្ទុកត្រួតពិនិត្យការងារ ។ ស្ថានភាពប្រែក្លាយទៅជាកាន់តែអាក្រក់ នៅពេលដែល សោ ភឹម ប្រធានភូមិភាគបូព៌ាត្រូវបានចាប់ខ្លួន ដោយចោទប្រកាន់ថាជាជនក្បត់ ។

## សង្គ្រាមប្រឆាំងនឹងវៀតណាមនិងការចាប់ខ្លួនកម្មាភិបាលភូមិភាគបូព៌ា

ស្ថានភាពនៅព្រៃវែងកាន់តែធ្លាក់ដុនដាបខណៈពេលដែលកម្មាភិបាលភូមិភាគនិរតីចូលមកបំផុសសង្គ្រាមប្រឆាំងនឹងវៀតណាម ។ វ៉ាន់ ផល អាយុ៥៧ឆ្នាំ អតីតយុទ្ធជនខ្មែរក្រហមនៅតំបន់២០ បាននិយាយត្អូញត្អែរថា កងទ័ពភូមិភាគនិរតីត្រូវបានបញ្ជូនទៅកាន់ភូមិភាគបូព៌ាដោយឥតប្រយោជន៍ ព្រោះថាកងទ័ពនៅទីនោះបានគ្រប់គ្រងស្ថានភាពល្អរួចទៅហើយ ។ វត្តមានរបស់កម្មាភិបាលភូមិភាគនិរតីបានបង្កើនភាពច្របូកច្របល់នៅភូមិភាគបូព៌ា បន្ទាប់ពី សោ ភឹម ត្រូវបានសម្លាប់ ។

រហូតមកដល់ចុងឆ្នាំ១៩៧៧ សង្គ្រាមរវាងខ្មែរក្រហម និងវៀតណាមនៅតាមព្រំដែនកាន់តែកើនឡើង ហើយយុទ្ធជនជាច្រើនត្រូវបានបញ្ជូនទៅខ្សែត្រៀម ។ នៅពេលនោះ កម្មាភិបាលជាន់ខ្ពស់នៅក្នុងជួរកងទ័ពនិងសហករណ៍ត្រូវបានដកចេញពីតំណែង ហើយជំនួសដោយកម្មាភិបាលថ្មីមកពីភូមិភាគនិរតីវិញ ដែលព្រឹត្តិការណ៍ទាំងនោះនៅតែដិតជាប់ក្នុងការចងចាំរបស់ប្រជាជនភាគច្រើន ។ ប្រជាជនមួយចំនួនដែលក្រុមការងារបានសម្ភាសន៍និយាយថា ពេលនោះគឺជាព្រឹត្តិការណ៍ដ៏អាក្រក់បំផុត ។ កម្មាភិបាលដែលត្រូវបានដកចេញពីតំណែងភាគច្រើនត្រូវខ្មែរក្រហមបញ្ជូនទៅអប់រំ ហើយស្ទើរតែគ្មាននរណាម្នាក់វិលត្រឡប់មកវិញទាល់តែសោះ ។

សំ គឹមសាន អាយុ៧០ឆ្នាំ រំឭកថានៅចុងឆ្នាំ១៩៧៧ កម្មាភិបាលមកពីភូមិភាគបស្ចិមដែលមានទម្លាប់ខុសពីអ្នកនៅក្នុងភូមិបានមកគ្រប់គ្រងក្នុងភូមិរបស់គាត់ ហើយកម្មាភិបាលថ្មីបានផ្លាស់ប្តូរកម្មាភិបាលចាស់ស្ទើរតែទាំងអស់ ។ គាត់បានឃើញកម្មាភិបាលទាំងនោះត្រូវពួកមកពីបស្ចិមបានចងជាជួរនិងដើរកាត់ភូមិរបស់គាត់តម្រង់ទៅកន្លែងដែលគាត់គិតថាជាវាលពិឃាត ។

វ៉ាន់ ផល និងអ្នកនៅក្នុងជួរកងទ័ពជាមួយគាត់ឆ្ងល់ពីការបាត់ខ្លួនរបស់ តាខឹម ដែលជាមេបញ្ជាការកងទ័ពរបស់គាត់ ។ បន្ទាប់មក ផល បានឃើញ សារុន មេបញ្ជាការរងរបស់ តាខឹម ត្រូវបានដកចេញបន្ទាប់ពីកាន់តំណែងជាមេបញ្ជាការបានមួយរយៈ ។ ផល ដឹងថាអ្នកទាំងពីរនោះច្បាស់ជាត្រូវយកទៅសម្លាប់ចោលហើយ ។ ផល និងអ្នកនៅក្នុងជួរកងទ័ពជាមួយគាត់ព្រួយបារម្ភពីវាសនារបស់អ្នកទាំងនោះនៅពេលដែលកម្មាភិបាលថ្នាក់ខ្ពស់ថ្មីមកពីភូមិភាគនិរតីចូលមកជំនួសតំណែងមេបញ្ជាការចាស់របស់ខ្លួន ។

## រត់គេចពីការចាប់ខ្លួន

វ៉ាន់ ផល និងទាហានផ្សេងទៀតមកពីតំបន់ព្រំដែនដូចជាត្រពាំងផ្លុងនិងភ្នំដើងអណ្តែង មានការភ័យខ្លាចយ៉ាងខ្លាំងដោយឃើញកម្មាភិបាលជាន់ខ្ពស់ជាច្រើនបាត់ខ្លួនពីអង្គភាពទ័ពជាបន្តបន្ទាប់ ។ កម្មាភិបាលខ្លះបានរត់គេចពីអង្គភាពដើម្បីទៅលាក់ខ្លួននៅក្នុងភូមិ ។ ផល រំឭកថា គាត់បានសុំឲ្យអ្នកជិតខាងជួយលាក់ខ្លួនគាត់កុំឲ្យកម្មាភិបាលភូមិភាគនិរតីរកឃើញ បើពុំដូច្នោះទេគាត់ច្បាស់ជារត់ចូលព្រៃដើម្បីចូលរួមជាមួយកងកម្លាំងដែលគាំទ្រដោយវៀតណាមជាមិនខាន ។ ដោយមានការគាំទ្រពីគ្រួសារនិងអ្នកភូមិ គាត់នៅមានជីវិតរហូតដល់ការចូលមកដល់របស់វៀតណាម ។

ផល មិនមែនជាមនុស្សដែលមានវាសនាអាក្រក់ជាងគេទេ ពីព្រោះអ្នកភូមិជាច្រើនដែលមានតួនាទីគ្រប់គ្រងនៅក្នុងសហករណ៍ត្រូវបានចាប់ខ្លួន ហើយបញ្ជូនទៅសម្លាប់ ។ ជួ ផេង អាយុ៦២ឆ្នាំ ធ្វើការនៅក្នុងសហករណ៍ត្រូវបានខ្មែរក្រហមចាប់ខ្លួននិងបង្ខំឲ្យធ្វើការធ្ងន់រយៈពេល៣ខែនៅក្នុងតំបន់តឹងតែងដែលស្ថិតនៅក្រោមការតាមដានពីកម្មាភិបាលភូមិភាគនិរតី ។ ផេង និយាយថាគាត់ត្រូវបានចាប់ខ្លួនពីព្រោះគាត់គឺជាប្រធានភូមិដែលគ្រប់គ្រងដោយកម្មាភិបាលភូមិភាគបូព៌ា ។ អ្នកដែលមិនព្រមទៅតំបន់តឹងតែងត្រូវបានសម្លាប់ភ្លាមៗ ។ ផេង បានឃើញអ្នកទោសជាច្រើនបាត់ខ្លួន ហើយក្រោយមកគាត់ដឹងថា អ្នកទាំងនោះត្រូវបានសម្លាប់នៅស្វាយរមៀតអតីតវិទ្យាល័យនិងកន្លែងមួយចំនួនទៀត

នៅក្រៅស្រុក ។

នៅចុងឆ្នាំ១៩៧៨ ប្រជាជនជាច្រើននៅក្នុងសហករណ៍ត្រូវបានកម្មាភិបាលភូមិភាគនិរតីជម្លៀសទៅខេត្តកំពង់ចាមនិងតំបន់ផ្សេងទៀតដើម្បីឲ្យផុតពីការវាយប្រហាររបស់វៀតណាម ។ បន្ទាប់មកពួកគេចូលរួមជាមួយខ្មែរក្រហមដើម្បីប្រយុទ្ធជាមួយកងទ័ពវៀតណាម ។ ការផ្ទុះអាវុធនិងគ្រាប់បែកធ្វើឲ្យប្រជាជនស្លូតត្រង់ស្លាប់អស់ជាច្រើន ។ អ្នកដែលនៅរស់ត្រូវតែប្រឈមមុខនឹងភាពអត់ឃ្លាន ហើយភាពអត់ឃ្លាននេះធ្វើឲ្យមានប្រជាជនស្លាប់ច្រើនដែរ ។ ផេង បាននិយាយត្អូញត្អែរពីទុក្ខវេទនាដែលគាត់បានជួបប្រទះនៅពេលជម្លៀស ។ គាត់បន្ថែមទៀតថា ស្លឹកឈើនិងមើមឈើគឺជាអាហារតែមួយគត់របស់គាត់ ។ ប្រជាជនជាច្រើនដែលមានវ័យចំណាស់ត្រូវស្លាប់ដោយភាពអត់ឃ្លាន ។ មួយខែក្រោយមក គាត់និងអ្នកភូមិអាចត្រឡប់មកភូមិវិញ ដោយសារមានគេចែកអង្ករឲ្យគាត់ ។

## សារសំខាន់នៃការអប់រំក្មេងជំនាន់ក្រោយអំពីរបបខ្មែរក្រហម

បន្ទាប់ពីសម្ភាសរួច អ្នកដែលត្រូវបានសម្ភាសចង់ឲ្យក្មេងជំនាន់ក្រោយសិក្សានិងចងចាំពីប្រវត្តិសាស្ត្រដ៏អាក្រក់នេះដើម្បីការពារកុំឲ្យរបបនេះកើតឡើងម្តងទៀត ។ ជួ ផេង និយាយថា ទោះបីក្មេងៗជាច្រើនដឹងពីរបបនេះតាមរយៈឪពុកម្តាយរបស់គេ ប៉ុន្តែគេហាក់ដូចជាមិនចាប់អារម្មណ៍ចង់ដឹងនិងសិក្សាអំពីប្រវត្តិ-សាស្ត្រនេះទេ ។ គាត់ស្នើថា ដើម្បីពង្រីងចំណេះដឹងរបស់ក្មេងៗជំនាន់ក្រោយ ពួកគេគួរតែទទួលបានការអប់រំជាផ្លូវការអំពីរបបកម្ពុជាប្រជាធិបតេយ្យនៅសាលារៀន ។ ការធ្វើបែបនេះអាចជួយឲ្យក្មេងៗសិក្សាដោយផ្ទាល់តាមរយៈគ្រូបង្រៀននិងអ្នកអប់រំ ។

ធី ផល្លី អាយុ៣០ឆ្នាំ ដែលកើតក្រោយរបបខ្មែរក្រហមដួលរលំមួយឆ្នាំបានអះអាងថា គាត់បានឃើញប្រជាជនរស់នៅវិទ្យាល័យស្វាយរមៀតដែលស្ថិតនៅក្នុងឃុំរបស់គាត់ ហើយធ្លាប់បានដឹងពីការសម្លាប់រង្គាលនៅអំឡុងរបបខ្មែរក្រហមពីឪពុកម្តាយរបស់គាត់ ។ គាត់ជឿនូវអ្វីដែលឪពុកម្តាយគាត់បានប្រាប់ ប៉ុន្តែគាត់បារម្ភពីក្មេងជំនាន់ក្រោយដែលមិនបានចាប់អារម្មណ៍នឹងរឿងរ៉ាវប្រវត្តិសាស្ត្រនេះ ។ គាត់បន្ថែមថា អប់រំក្មេងៗតាមរយៈប្រព័ន្ធផ្សព្វផ្សាយសាធារណៈដូចជា ការចាក់ផ្សាយខ្សែភាពយន្តអំពីរបបនេះគឺជាមធ្យោបាយល្អបំផុតដើម្បីជួយឲ្យក្មេងៗយល់ដឹងនិងចងចាំប្រវត្តិសាស្ត្រនេះ ។

វ៉ាន់ ផល ក៏ដូចជា ផេង ដែរ គាត់បានស្នើឲ្យបញ្ចូលប្រវត្តិ-សាស្ត្រខ្មែរក្រហមទៅក្នុងកម្មវិធីសិក្សាដើម្បីឲ្យក្មេងៗបានយល់ដឹង បើទោះបីជាឪពុកម្តាយរបស់គេមិនមានពេលវេលានិយាយប្រាប់ពីអ្វីដែលបានកើតឡើងនៅអតីតកាលក៏ដោយ ។ ថេង ប៉េន អាយុ៨៣ឆ្នាំ មានទស្សនៈថា គាត់ចង់ឲ្យក្មេងៗសិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហមដើម្បីឲ្យចងចាំនិងទប់ស្កាត់កុំឲ្យរបបនេះកើតឡើងម្តងទៀត ។ គាត់បន្ថែមទៀតថា ការបញ្ចាំងខ្សែភាពយន្តរបបខ្មែរក្រហមនឹងជំរុញឲ្យក្មេងជំនាន់ក្រោយកាន់តែជឿទៅលើអំពើឃោរឃៅរបស់ពួកនោះ ។



អ្នកភូមិ ដូនជី និងព្រះសង្ឃកំពុងមើលភាពយន្តឯកសារ ខេត្តព្រៃវែង

នៅពេលដែលនិយាយអំពីយុត្តិធម៌និងដំណើរការកាត់ទោស អ្នកចូលរួមជាច្រើនបាននិយាយថាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានបង្កើតឡើងដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតក្នុងគោលបំណងផ្តល់យុត្តិធម៌ដល់ជនរងគ្រោះនៅរបបខ្មែរក្រហម ការធ្វើបែបនេះនឹងមិនអាចសងចំពោះអ្វីដែលប្រជាជនកម្ពុជាបានបាត់បង់ទេ ។

**ស៊ិរ សាទីណា**

# ប្រាសាទក្រោមរបបខ្មែរក្រហម

ប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ប្រាសាទបុរាណខ្មែរបាន ក្លាយជាសម្បត្តិវប្បធម៌ពុំអាចកាត់ថ្លៃសម្រាប់មជ្ឈដ្ឋានអ្នកសិក្សាស្រាវជ្រាវ វិស័យទេសចរណ៍ ពិសេសបង្ហាញអំពីអត្តសញ្ញាណជាតិខ្មែរ ។ ប៉ុន្តែប្រមាណជា៣០ឆ្នាំមុននេះ ប្រទេសកម្ពុជាបានប្រឈមមុខនឹងសង្គ្រាមរវាងជាតិសាសន៍ឯងដែលមិនគ្រាន់តែសម្លាប់ជីវិតប្រជាជនខ្មែររាប់លាននាក់ប៉ុណ្ណោះទេ ថែមទាំងគំរាមកំហែងទៅលើសំណង់ប្រវត្តិសាស្ត្រនានា ហេដ្ឋារចនាសម្ព័ន្ធនៅគ្រប់តំបន់ ក្នុងនោះរួមមានសំណង់ប្រាសាទបុរាណដែលមានអាយុរាប់ពាន់ឆ្នាំទៀតផង ។ ដោយមិនលើកពីការខូចខាតដោយកត្តាធម្មជាតិទៅតាមពេលវេលា សំណង់ប្រាសាទទាំងនោះបានឆ្លងកាត់គ្រប់សម័យកាលដែលអាចរក្សាបាននូវក្បូរក្បាច់ដ៏ប្រណីតព្រមទាំងទម្រង់សិល្បៈរបស់ខ្លួន ប៉ុន្តែក្រោមការដឹកនាំរបបខ្មែរក្រហម ប្រាសាទមួយចំនួនត្រូវបានបំផ្លាញទាំងស្រុង ។

មិនខុសគ្នានឹងសម័យបច្ចុប្បន្នទេ បើយើងពិនិត្យមើលសំបកក្រៅនៃទិដ្ឋភាពជុំវិញប្រទេសកម្ពុជាក្រោមឈ្មោះកម្ពុជាប្រជាធិបតេយ្យ គឺថាមានហេតុផលពីរដែលបញ្ជាក់ថាខ្មែរក្រហមបានយកប្រាសាទបុរាណដើម្បីបង្ហាញពីអត្តសញ្ញាណរបស់ខ្មែរលើឆាកអន្តរជាតិ ។ ទី១តាមរយៈទង់ជាតិក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រើប្រាស់ទង់ជាតិមានច្រើនសណ្ឋានច្រើនរូបភាព មានជាទង់បដិវត្តន៍នៅលើគម្របទស្សនាវដ្តីលេខ៤ ខែមេសា ឆ្នាំ១៩៧៨ បច្ចុប្បន្ននៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ទង់ជាតិកម្ពុជាប្រជាធិបតេយ្យដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញថារូបភាពនិងខ្លឹមសាររបស់ទង់ជាតិដែលបង្ហាញនូវផ្ទៃពណ៌ក្រហមរំលេចដោយរូបប្រាសាទកំពូលបីពណ៌លឿងនៅចំកណ្តាលជានិមិត្តរូបនៃចលនាបដិវត្តន៍ ការប្រយុទ្ធមោះមុត អង់អាចក្លាហាន ក្នុងការរំដោះជាតិ ការពារជាតិ និងកសាងជាតិរបស់ប្រជាជនកម្ពុជា ។ ម្យ៉ាងទៀត បើយោងទៅលើការពិភាក្សារបស់លោក ស៊ីហ្វ្រេដ អ៊ីមាន់ ថាខ្មែរក្រហមបានប្រើតែមប្រៃសណីយ៍ដែលបង្ហាញពីទង់ជាតិមានរូបអង្គរវត្តកំពូលបីដែលតាមរយៈអង្គការសហប្រជាជាតិបញ្ជាក់ថា មានទង់ជាតិដូចគ្នាធ្លាប់មានវត្តមាននៅទីក្រុងញូវយ៉កដែរ ។ ទីពីរ រាល់ដំណើរទស្សនកិច្ចរបស់ភ្ញៀវបរទេសនៅកម្ពុជាក្នុងរបបខ្មែរក្រហម យើងអាចដឹងថាត្រូវធ្វើឡើងទៅតាមតំបន់នានាក្នុងប្រទេសកម្ពុជា ប៉ុន្តែចំពោះតំបន់មួយដែលភ្ញៀវមកទស្សនាពុំដែលរំលងនោះ គឺទឹកដីខេត្តសៀមរាបដែលជាអតីតរាជធានីខ្មែរបុរាណជាច្រើនតំណមកហើយ ។ តាមបទសម្ភាសន៍ជាមួយលោក ប៊ុត សំអាន ដែលរស់នៅស្រុកត្រាំកក់ ខេត្តតាកែវ ជាអតីតអ្នកបើកបរនៅក្នុងក្រសួងការបរទេសនៅអំឡុងឆ្នាំ១៩៧៧-១៩៧៩ បានរៀបរាប់ថាភាគច្រើនភ្ញៀវតែងតែទៅទស្សនានៅតាមប្រាសាទនានានៅតំបន់អង្គរ មានប្រាសាទអង្គរវត្ត អង្គរធំ ប្រាសាទបន្ទាយស្រី បារាយណ៍ខាងលិច(បារាយណ៍ទឹកថ្លា) ជាដើម ។ ច្បាស់ជាងនេះទៅទៀតតាមរយៈរូបថតមួយចំនួនបានបង្ហាញយ៉ាងប្រត្យក្សថាមេដឹកនាំក្នុងរបបខ្មែរក្រហមដែលយើងអាចស្គាល់មាន អៀង


ប្រាសាទភ្នំជីសូ នៅក្នុងតាកែវ

សារី និង ខៀវ សំផន ជាមួយនឹងអ្នកហែហមសំខាន់ៗមួយចំនួនទៀតបានដូនដំណើរគណៈប្រតិភូទៅទស្សនាប្រាសាទអង្គរវត្ត ។ មួយវិញទៀត យើងក៏ឃើញមានក្រុមសិល្បៈខ្មែរក្រហមថតរូបនៅប្រាសាទបន្ទាយស្រីដើម្បីបង្ហាញអំពីវប្បធម៌ប្រពៃណីរបស់ខ្លួន ប្រកបដោយមោទនភាពចំពោះស្នាដៃសាងសង់ដែលជាស្ថាបត្យកម្មកំពូលរបស់ខ្មែរដែរ ។

ខ្មែរក្រហមបានបង្ហាញវីរភាពរបស់ខ្លួនថាជាអ្នកមានស្នាដៃប្រៀបដូចជាដូនតាកសាងប្រាសាទអង្គរវត្ត ប៉ុន្តែខ្មែរក្រហមពុំបានចាត់ទុកប្រាសាទដទៃទៀតមានតម្លៃដូចប្រាសាអង្គររវត្តទេ តួយ៉ាងយើងអាចឃើញថាថ្នាក់ដឹកនាំនៅក្នុងរបបនេះបានបើកឱកាសឲ្យអ្នកដែលក្រោមបញ្ជារបស់ខ្លួន កម្មាភិបាលនៅគ្រប់តំបន់ធ្វើទង្វើតាមអំពើចិត្ត ដែលនៅក្នុងនោះបុរាណស្ថាននៅតាមខេត្តនានាក្នុងប្រទេសកម្ពុជាត្រូវបានក្លាយជាកម្មវត្ថុនៃការបំផ្លាញរបស់ខ្មែរក្រហមដោយការយកទីនោះទៅធ្វើឃ្លាំងផ្ទុកសម្ភារៈ និងធ្វើការរុះរើប្រាសាទទាំងស្រុង ឬក៏ការវាយកម្ទេចចោលតែម្តង ។

ដោយហេតុថាបារាំងបានដាក់អាណានិគមមកលើកម្ពុជារយៈពេលជិតមួយសតវត្សរ៍ និងធ្វើការស្រាវជ្រាវអំពីខ្មែរច្រើនជាងជាតិសាសន៍ណាៗទាំងអស់ ដូចនេះការស្រាវជ្រាវអំពីប្រទេសកម្ពុជា ពិសេសការផ្តោតទៅលើសំណង់ប្រាសាទបុរាណខ្មែរយើងពុំអាចរំលងអំពីប្រវត្តិនៃការស្រាវជ្រាវឯកសាររបស់បារាំងបានឡើយ ។ ការចុះបញ្ជីសារពើភណ្ឌរបស់លោក **Lunet de Lajonquière** អំពីសំណង់ប្រាសាទខ្មែរមួយភាគធំនៅក្នុងប្រទេសត្រូវធ្វើឡើងនៅដើមសតវត្សរ៍ទី២០ដែលកត់ត្រាអំពីទម្រង់សិល្បៈសម្ភារៈសំណង់ស្ថាបត្យកម្ម ឬធ ទីតាំងប្រាសាទយ៉ាងលម្អិតនិងចុងក្រោយនាឆ្នាំ២០០៧ ការចុះបញ្ជីប្រាសាទធ្វើឡើងដោយសាលាបារាំងចុងបូព៌ា ***(EFEO: Ecole Française d'Extrême-Orient)*** ហេតុនេះនៅក្នុងអត្ថបទដែលលើកយកមកបង្ហាញគឺគ្រាន់តែជាព័ត៌មានបន្ថែមនៅក្រោយពេលសង្រ្គាមប៉ុណ្ណោះ បើទោះជាមានការចុះបញ្ជីរួចហើយក៏ដោយ ។

នៅក្នុងអត្ថបទនេះចង់បង្ហាញអំពីការបំផ្លាញប្រាសាទនិងបុរាណស្ថានមួយចំនួននៅក្នុងរបបខ្មែរក្រហមតាមរយៈការសម្ភាសប្រជាជនដោយក្រុមការងារក្នុងគម្រោងចូលរួមរបស់ជនរងគ្រោះរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានជួយប្រជាជនដែលនៅរស់រានមានជីវិតក្រោយពីរបបខ្មែរក្រហមដួលរំលំទៅបានបំពេញពាក្យបណ្តឹងទៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្វីដ្បិតតែប្រាសាទដែលបាត់បង់នោះមានទម្រង់ស្ថាបត្យកម្មក្នុងទំហំតូច ឬពុំមានផ្តល់សារសំខាន់ដូចប្រាសាទធំៗដទៃទៀតក៏ដោយ ក៏ប្រាសាទទាំងនោះបានបង្ហាញនូវការគោរពប្រណិបត៍ន៍សាសនា បច្ចេកទេសសំណង់ សង្គមប្រវត្តិសាស្ត្ររបស់តំបន់មួយនាសម័យបុរាណដែរ ។

យ៉ាងហោចណាស់ មានប្រាសាទចំនួនពីរត្រូវបានរុះរើយកទៅបម្រើជាផលប្រយោជន៍ផ្សេងទៀត ដោយស្នាដៃកម្មាភិបាលខ្មែរក្រហមនៅក្នុងខេត្តកំពង់ធំ ។ តាមការរៀបរាប់របស់ អ៊ាន់ ជាប្រជាជនរស់នៅស្រុកស្ទោងអំពីស្ថានភាពប្រាសាទព្រះនាងមុនរបបខ្មែរក្រហមថា ប្រាសាទព្រះនាងមានទីតាំងស្ថិតនៅភូមិធ្វើពីថ្មបាយក្រៀមមានទំហំប្រមាណ២០ម៉ែត្រ បួនជ្រុង ពុំមានក្បាច់លម្អទេ ប៉ុន្តែស្ថានភាពប្រាសាទពុំមានការខូតខាតនៅឡើយ ។ អំឡុងឆ្នាំ១៩៧៧-១៩៧៨ អ៊ាន់ នៅធ្វើការនៅការដ្ឋានទំនប់ទឹក៣០កញ្ញា បានឃើញប្រធានសំណង់ស្រុក (មិនស្គាល់ឈ្មោះ) បញ្ជាឲ្យប្រជាជនផ្នែកខាងធ្វើសំណង់ទៅរុះរើថ្មរបស់ប្រាសាទដើម្បីយកទៅទប់ដីដែលទឹកនៅហូរច្រោះ ហើយថ្មប្រាសាទមួយចំនួនទៀតត្រូវដឹកដាក់រថយន្តជាច្រើនគ្រឿងទៅធ្វើទំនប់ទឹក៦មករានិងទំនប់ទឹក៣០កញ្ញា ។ ជាមួយគ្នានោះ ព្រះវិហារនៅវត្តស្ពឺជើងស្ថិតនៅភូមិម្សាក្រង ឃុំម្សាក្រង ស្រុកស្ទោង និងវត្តស្វាយរមៀត នៅឃុំកំពង់ចិនត្បូង ព្រះវិហារនៅវត្តហប់ក្នុងភូមិទ្រា ឃុំទ្រា ក៏ត្រូវប្រធានសំណង់បញ្ជាឲ្យប្រជាជនវាយកម្ទេចដើម្បីយកដែកទៅធ្វើសំណង់៣០កញ្ញា ធ្វើជាស្ពាន ប្រឡាយទឹក ទ្វារទឹកដែរ ។

នៅខេត្តកំពង់ធំដដែល លាត មានប្រសាសន៍ថា ប្រាសាទព្រះធាតុ ស្ថិតនៅភូមិក្បិល ឃុំសានគរ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ និងមានចម្ងាយប្រមាណ៨គីឡូម៉ែត្រពីវត្តព្រះពុទ្ធជិនរាជនៅជាប់ផ្លូវជាតិត្រូវបានរុះរើទាំងស្រុងនៅក្នុងរបបខ្មែរក្រហម ។ ប្រាសាទបែរមុខទៅទិសខាងកើតធ្វើអំពីថ្មបាយក្រៀមមានទំហំប្រហែល១០ម៉ែត្របួនជ្រុងទ្រវែងរាងចតុកោណកែង ហើយនៅ

ពីមុខប្រាសាទមានដីទួលលើកខ្ពស់ផុតពីទឹកនៅរដូវវស្សា ដែលមានកម្ពស់ប្រមាណ៣-៤ម៉ែត្របួនជ្រុង ដោយមានប្រវែងប្រហែលមួយគីឡូម៉ែត្រប្រៀបដូចជាកំពែងពទ្ធ័អ្វីមួយ ។ កន្លែងនោះត្រូវបានអ្នកស្រុកហៅថាបន្ទាយចាម ។ គាត់បន្តថាគាត់ក៏បានចូលរួមរុះរើសំណង់ប្រាសាទព្រះធាតុដោយផ្ទាល់ ។ អំឡុងឆ្នាំ១៩៧៧ គាត់ធ្វើការនៅកងចល័តនៅស្រុកកំពង់ស្វាយត្រូវប្រធានឃុំឈ្មោះ ចក់ (បច្ចុប្បន្នស្លាប់) បញ្ជាឲ្យក្រុមចល័តរបស់គាត់ដែលមានចំនួនសរុបប្រហែល១០០នាក់ទៅគាស់យកថ្មប្រាសាទធ្វើពីថ្មបាយក្រៀម ។ ក្នុងការរុះរើគាស់យកថ្មប្រាសាទនេះមានរយៈពេលប្រហែលមួយខែ ដោយដឹកថ្មដាក់រថយន្តយកទៅធ្វើសំណង់ទឹក៣០កញ្ញា ។ គាត់ពុំដឹងថាតើថ្មប្រាសាទនីមួយៗត្រូវគេវាយកម្ទេចឲ្យម៉ត់ឬក៏យកទៅធ្វើសំណង់ទាំងមូលទេ ពីព្រោះគាត់នៅធ្វើការតែកន្លែងគាស់យកថ្មប្រាសាទប៉ុណ្ណោះ ។ គាត់នៅចាំបានថា ប្រាសាទព្រះធាតុនៅមានគ្រឿងលម្អស្ថាបត្យកម្មមួយចំនួនដូចជា ផ្តែរ ហោជាង សសរពេជ្រ ថ្មអឡ្លូចន្ទ (កាំជណ្តើរ) ធ្វើអំពីថ្មភក់ និងនៅខាងលើប្រាសាទមានចម្លាក់នៅល្អៗច្រើន (ចម្លាក់នៅខ្លោងទ្វារ) ប៉ុន្តែចាប់តាំងពីរុះរើគាស់យកថ្មប្រាសាទសព្វថ្ងៃនៅសល់តែគ្រឹះក្នុងដីប៉ុណ្ណោះ ។ គាត់បញ្ជាក់ថាគាត់ពុំដឹងថាតើមានថ្នាក់លើបញ្ជាឲ្យ តាចក់ រុះរើគាស់យកថ្មប្រាសាទឬមួយតាចក់ ខ្លួនឯងជាអ្នកទទួលខុសត្រូវឲ្យរុះរើឬយ៉ាងណាទេ ។ ទោះជាយ៉ាងណា ចំពោះការរុះរើប្រាសាទទាំងពីរខាង លើ លោកពូ អ៊ាន់ និង លាត ពិតជាមានការសោកស្តាយជាខ្លាំងចំពោះការបាត់បង់សម្បត្តិវប្បធម៌ទាំងនេះ ពីព្រោះថ្វីដ្បិតតែបច្ចុប្បន្នប្រជាជនខ្មែរគោរពព្រះពុទ្ធសាសនាជាចម្បងក៏ដោយ ប៉ុន្តែសំណង់ប្រាសាទសម្រាប់ព្រហ្មញ្ញសាសនាទាំងនោះនៅតែមានប្រជាជនគោរពនិងចាត់ទុកជាសម្បត្តិវប្បធម៌ជាតិដើម្បីទុកសម្រាប់ឲ្យក្មេងជំនាន់ក្រោយបានសិក្សានិងជាប្រវត្តិសាស្ត្រដែរ ។ ក្នុងករណីនេះបញ្ជាក់ថាការរុះរើសម្បត្តិវប្បធម៌ដែលមានសំណង់ប្រាសាទនេះអាចមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើការប្រឆាំងនឹងច្បាប់បំផ្លិចបំផ្លាញសម្បត្តិវប្បធម៌នៅពេលមានសង្គ្រាម ។

នៅខេត្តព្រៃវែងវិញ បើតាមរយៈលោកពូម្នាក់អាយុ៤៥ឆ្នាំដែលរស់នៅភូមិដូនដោកបានមានប្រសាសន៍ពីទីទួលមួយមានដីពូនកម្ពស់ប្រហែល២ម៉ែត្រ ស្ថិតនៅភូមិដូនដោក ឃុំជាច ស្រុកកំចាយមារ ខេត្តព្រៃវែងថា ទីទួលនោះត្រូវបានអ្នកស្រុកហៅថាទួលបឹងកាសែត ហើយនៅទិសខាងជើងចម្ងាយប្រហែល៦៥០ម៉ែត្រមានត្រពាំងធំមួយឈ្មោះត្រពាំងរំសែន ។ ដំបូងពុំមាននរណាដឹងថានៅទីទួលនេះជាទីទួលបុរាណទេ គ្រាន់តែដឹងថាមានរាងស្រួចដូចជាភ្នំ ទួលតូច សុទ្ធសឹងតែជាដីនិងខ្សាច់ ហើយដោយពិនិត្យឃើញស្ថានភាពនៅជុំវិញទីទួលមានភូមិសាស្ត្រល្អនៅជុំវិញមានទឹក មានដីស្រែ មានទីធ្លាស្រឡះ នៅខាងលិច មានរោងសិប្បកម្ម មានដីកព្រែក រោងសន្ធមកិច្ចស្មោររម្ងាស់ថ្នាំ ខាងត្បូងភូមិមានរោងស្ករ ខាងជើងជាស្រែដែលរឹបអូសពីប្រជាជនរាប់រយហិកតាបញ្ចូលជាមួយកសិដ្ឋានទាំងអស់ សោ ភឹម ក៏បានបញ្ជាឲ្យយកគ្រឿងចក្រមកឈូសឆាយទីទួលនោះធ្វើជារោងសិប្បកម្មកន្លែងចិញ្ចឹមមាន់ ចិញ្ចឹមទាទៅវិញ ។ គាត់បានបញ្ជាក់ថា «ជំនាន់តាភឹម គាត់មានឧបករណ៍ទំនើបដូចជា ត្រាក់ទ័រ គោយន្ត ម៉ាស៊ីនឈូស ហើយគាត់ឈូសនេះគឺគ្រាន់តែមានគំនិតពង្រាបដីដើម្បីធ្វើជារោងសប្បិកម្មប៉ុណ្ណោះដោយពុំបានគិតថាប៉ះប្រាសាទទេ ហើយកាលណោះពុំទាន់មានប៉ះប្រាសាទឡើយ» ។ ការពង្រាបដីនៅលើទីទួលនេះ ទោះជាពុំមានការខូចខាតទៅដល់ថ្មប្រាសាទប៉ុន្មានក៏ដោយ ក៏អាចប៉ះពាល់ដល់ស្រទាប់ដីវប្បធម៌របស់ប្រាសាទតាមសម័យកាលនីមួយៗដែរ ដូច្នេះទាមទារឲ្យមានការសិក្សាបែប



គំនូរដើមរបស់ប្រាសាទព្រះធាតុ

បុរាណវត្ថុវិទ្យា តាមរយៈការធ្វើកំណាយបែបវិទ្យាសាស្ត្រដើម្បីស្រាវជ្រាវពីសង្គមបរិយាកាស រចនាសម្ពន្ធ័របស់ប្រាសាទ។ បើយើងពិនិត្យទៅលើតំបន់របស់ទីទួលប្រាសាទដែលមានត្រពាំងដ៏ធំមួយនៅទិសខាងជើងអាចជាតំបន់ទីប្រជុំសំខាន់ ក្រៅពីអំណោយផលពីកត្តាភូមិសាស្ត្រ ទីកន្លែងនោះអាចជាកន្លែងសម្រាប់គោរពបូជាពិធីសាសនាយ៉ាងសំខាន់ ដ្បិតលទ្ធផលនៃការពង្រាបដីរបស់សោ ភឹម នៅកន្លែងទីទួលប្រាសាទនេះមានព្រះសង្ឃ និងលោកអាចារ្យបានគាស់ថ្មប្រាសាទទៅធ្វើជាខឿននៅវត្តកោះខ្លាយក្នុងអំឡុងឆ្នាំ១៩៩៧-១៩៩៨។ បើយោងតាមប្រសាសន៍របស់លោកពូប្រធានភូមិជាច មកពាត់នៅចាំបានថាក្នុងជម្រៅប្រមាណ២ម៉ែត្រ ជីកលុងទៅក្រោមមានឥដ្ឋ និងថ្មបាយក្រៀម គឺអ្នកភូមិជីកបានវត្ថុសិល្បៈមួយចំនួនដូចជាមាសស្លឹកស្រូវមានរាងសំប៉ែត និងខ្វះរាងវែង មាសសន្លឹកមានរាងដូចជាសន្លឹកសីមា ជាប្រភេទមាសស្រួយ ស្លឹកស្រូវរាងតូចនិងស្តើង មានប្រភេទកុលាភាជន៍ជាពួចពណ៌ខៀវ ដូចចានរលោងមានគម្របនៅល្អ។ ដូចនេះយើងអាចគិតថា ទីទួលប្រាសាទនោះអាចជាទីកន្លែងសំខាន់នៅក្នុងតំបន់មួយសម្រាប់វិស័យសាសនា។

នៅឯខេត្តពោធិ៍សាត់វិញ សុផារី រស់នៅស្រុកបាកាន ខេត្តពោធិ៍សាត់ ជាជនរងគ្រោះដែលត្រូវខ្មែរក្រហមព្យាយាមសម្លាប់ទាំងក្រុមគ្រួសារដោយសារគ្រួសារគាត់ជាជនជាតិខ្មែរក្រោមមាននិន្នាការជាក្បាលយួនខ្លួនខ្មែរ។ គាត់បានរៀបរាប់អំពីការបំផ្លាញប្រាសាទដូនអនដែលធ្វើពីថ្មភក់ ទំហំប្រហែល១២ម៉ែត្របួនជ្រុង មានផ្តេរ ហោជាង សសរពេជ្រ ស្ថិតនៅភូមិប្រាសាទ ឃុំរំលេច (បច្ចុប្បន្នស្វាយដូនកែវ) ស្រុកបាកាន ខេត្តពោធិ៍សាត់ ត្រូវប្រធានកង ប្រធានសហករណ៍ (ពុំស្គាល់ឈ្មោះ) បញ្ជាឲ្យប្រជាជនក្នុងភូមិធ្វើការរុះរើសំណង់ប្រាសាទទាំងអស់យកទៅធ្វើទ្វារប្រឡាយ១៧មេសា ស្ថិតនៅភូមិស្តុកខ្លា ឃុំរំលេច និងភូមិគោករំល ឃុំតាលោ ស្រុកបាកាន ខេត្តពោធិ៍សាត់។ ក្នុងការរើរុះប្រាសាទគឺប្រធានសហករណ៍តម្រូវឲ្យកាប់គាស់និងវាយកម្ទេចថ្មជាបំណែកតូចៗបន្តទៀតដើម្បីយកទៅចាក់ធ្វើទ្វារទឹករយៈពេលជាងមួយខែទើបរួចរាល់។ គាត់គិតថា នេះគឺជាការកម្ទេចដើម្បីបំបាត់ភ័ស្តុតាង ហើយក៏ជាការបំផ្លាញវត្ថុអារាមដែរព្រោះគាត់និងប្រជាជនក្នុងភូមិបានឃើញច្បាស់ថាពួកខ្មែរក្រហម (ពុំស្គាល់ឈ្មោះ) បានយកសាស្ត្រាស្លឹករឹតទៅដេរធ្វើមួកពាក់។

ថ្វីដ្បិតតែព័ត៌មានអំពីការប៉ះពាល់ប្រាសាទបុរាណដែលមានអាយុរាប់ពាន់ឆ្នាំមានចំនួនតិចតួចក្តី ក៏វាធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់សម្បត្តិវប្បធម៌របស់ជាតិកម្ពុជាដែរ ព្រោះថាប្រាសាទទាំងនេះគឺជាអត្តសញ្ញាណមួយសម្រាប់បង្ហាញពីអរិយធម៌និងវប្បធម៌របស់ប្រទេសយើង។

**សេង គន្ធី**



ទីទួលគ្រឹះប្រាសាទបឹងកាសែត

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# ក្រមសីលធម៌ចៅក្រម

**បុព្វកថា**

ចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា៖

**បានឃើញ**កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាស្តីពីការកាត់ក្តីក្រោមច្បាប់កម្ពុជា ចំពោះឧក្រិដ្ឋកម្មទាំងឡាយ ដែលបានប្រព្រឹត្តិឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣។

**បានឃើញ**ច្បាប់ និង ខ្លឹមសារវិសោធនកម្ម ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលបានប្រកាសឱ្យប្រើជាផ្លូវការកាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។

**បានឃើញ**ក្រមសីលធម៌ចៅក្រម ដែលបានអនុម័តដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០៧។

**បានគិតគូរ**ដល់គោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីឯករាជ្យភាពរបស់តុលាការ ឆ្នាំ ១៩៨៥។

**បានយល់ដឹង**ពីចរិតលក្ខណៈកូនកាត់នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងភាពចាំបាច់ត្រូវអនុម័តនូវក្រមសីលធម៌ ដែលចៅក្រមជាតិ និងអន្តរជាតិត្រូវអនុវត្តតាម និង ដោយបញ្ចូលនូវនិយាមជាតិ និងអន្តរជាតិ។

**បានព្រមព្រៀងគ្នា**ដូចខាងក្រោម៖

**មាត្រា ១**

**គោលការណ៍ឯករាជ្យភាពរបស់តុលាការ**

១. ចៅក្រមត្រូវរក្សានូវឯករាជ្យភាពនៃការិយាល័យរបស់ខ្លួន និងសិទ្ធិអំណាចរបស់ខ្លួនក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ហៅកាត់ថា អ.វ.ត.ក) ហើយត្រូវប្រតិបត្តិតាមសិទ្ធិអំណាច និងឯករាជ្យភាពក្នុងការបំពេញតួនាទីរបស់ខ្លួន។

២. ចៅក្រមមិនត្រូវចូលរួមក្នុងសកម្មភាពណាមួយ ដែលទំនងជាជ្រៀតជ្រែកចូលក្នុងការបំពេញមុខនាទីរបស់ខ្លួន ឬអាចប៉ះពាល់ដល់ជំនឿទុកចិត្តលើឯករាជ្យភាពរបស់ខ្លួន។

## មាត្រា ២

## គោលការណ៍អនាគតិ

១. ចៅក្រមត្រូវរក្សានូវភាពមិនលំអៀង និង ត្រូវធានាពីការបង្ហាញពីភាពមិនលំអៀងនោះក្នុងការបំពេញមុខនាទីរបស់ខ្លួន។

២. ចៅក្រមត្រូវចៀសវាងនូវរាល់ជម្លោះផលប្រយោជន៍ ឬ ស្ថិតក្នុងស្ថានភាពណាមួយដែលគេអាចយល់ឃើញថាមានជម្លោះផលប្រយោជន៍កើតឡើង។

## មាត្រា ៣

## គោលការណ៍សុចរិតភាព

(វិសោធនកម្មថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០០៨)

១. ចៅក្រមត្រូវប្រតិបត្តិខ្លួនដោយភាពថ្លៃថ្នូរ ដោយសីលធម៌ និង ដោយសេចក្តីសុចរិតទៀងត្រង់តាមការិយាល័យរបស់ខ្លួន ដើម្បីលើកកម្ពស់ជំនឿទុកចិត្តពីសាធារណជនលើតុលាការ។

២. ចៅក្រមមិនត្រូវទទួលយក ឬ សំណើផ្តល់ ឬ ផ្តល់នូវអំណោយ (កាដូ) ផលប្រយោជន៍ បុព្វសិទ្ធិ ឬ រង្វាន់ទោះដោយផ្ទាល់ក្តី ឬ ដោយប្រយោលក្តី ដែលគេអាចយល់បានថា កំពុងតែមានចេតនាជះឥទ្ធិពលលើការបំពេញមុខនាទី ឬ ឯករាជ្យភាពនៃការងាររបស់ខ្លួន។

## មាត្រា ៤

## គោលការណ៍ភាពសម្ងាត់

ចៅក្រមត្រូវគោរពនូវសារសំខាន់នៃការរក្សាភាពសម្ងាត់ ចំពោះពត៌មានដែលទទួលបានក្នុងការបំពេញមុខនាទីរបស់ខ្លួន និង ភាពសម្ងាត់នៃការពិភាក្សាសម្រេច។

## មាត្រា ៥

## គោលការណ៍វីរិយភាព

១. ចៅក្រមត្រូវបំពេញតួនាទីភារកិច្ចរបស់ខ្លួនដោយសេចក្តីសង្វាតព្យាយាម និងប្រើសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួនដើម្បីបំពេញភារកិច្ចទាំងនោះ។

២. ចៅក្រមត្រូវចាត់វិធានការសមស្របដើម្បីរក្សា និងលើកកម្ពស់ចំណេះដឹង ជំនាញ និងសមត្ថភាពផ្ទាល់ខ្លួន ដែលចាំបាច់សម្រាប់បំពេញតួនាទីរបស់ខ្លួន។

៣. ចៅក្រមត្រូវបំពេញគ្រប់តួនាទីភារកិច្ចតុលាការឱ្យបានឆាប់រហ័ស និងត្រឹមត្រូវ។

៤. ចៅក្រមត្រូវចេញសេចក្តីសម្រេចរបស់ខ្លួន ដោយគ្មានការពន្យាពេល ដែលមិនសមរម្យ។

## មាត្រា ៦

## គោលការណ៍អាកប្បកិរិយាក្នុងដំណើរការក្តី

១. នៅក្នុងកិច្ចដឹកនាំដំណើរការក្តី ចៅក្រមត្រូវរក្សានូវសណ្តាប់ធ្នាប់ របៀបរៀបរយ រៀបចំអាកប្បកិរិយាគួរជាទីគោរព រក្សាភាពអត់ធ្មត់ និងការគួរសមចំពោះអ្នកចូលរួមទាំងអស់ ក៏ដូចជាសាធារណជនដែលមានវត្តមាន ហើយត្រូវតម្រូវឱ្យអ្នកទាំងនោះអនុវត្តដូចគ្នាដែរ។

២. ចៅក្រមត្រូវយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងលើឥរិយាបទក្នុងការសួរសំណួរលើសាក្សី ឬជនរងគ្រោះ និងផ្តល់ការយកចិត្តទុកដាក់ជាពិសេសលើសិទ្ធិរបស់អ្នកចូលរួមក្នុងដំណើរការក្តីក្នុងការទទួលបានការការពារ និងអត្ថប្រយោជន៍តាមផ្លូវច្បាប់។

៣. ចៅក្រមត្រូវចៀសវាងនូវការដឹកនាំ ឬការជូនយោបល់ណាមួយដែលមានភាពរើសអើងពូជសាសន៍ភេទ ឬបន្ទាបបន្ថោក។ បើអាចធ្វើទៅបាន ចៅក្រមត្រូវធ្វើយ៉ាងណាឱ្យអ្នកចូលរួមក្នុងដំណើរការក្តីចៀសវាងពីការផ្តល់នូវយោបល់ ឬប្រព្រឹត្តិអំពើបែបនោះ។

## មាត្រា ៧

## គោលការណ៍សម្តែងមតិជាសាធារណៈ និងទំនាក់ទំនងជាមួយសាធារណៈ

១. ចៅក្រមត្រូវអនុវត្តសិទ្ធិក្នុងការបញ្ចេញមតិ និងចូលរួមក្នុងកិច្ចការសាធារណៈណាដែលសមស្របជាមួយនឹងមុខនាទីនៃការិយាល័យរបស់ខ្លួន ហើយដែលមិនជះឥទ្ធិពល ឬទំនងជាអាចជះឥទ្ធិពលដល់ឯករាជ្យភាព និងភាពមិនលំអៀងរបស់តុលាការ។

២. ទោះបីចៅក្រមអាចចូលរួមដោយសេរីក្នុងការពិភាក្សាវែកញែកជាសាធារណៈលើបញ្ហាទាំងឡាយទាក់ទងនឹងបញ្ហាច្បាប់ តុលាការ ឬរដ្ឋបាលតុលាការ ចៅក្រមមិនត្រូវជូនយោបល់ណាមួយទាក់ទងនឹងសំណុំរឿងដែលរង់ចាំការកាត់សេចក្តី ហើយចៅក្រមត្រូវចៀសវាងការបញ្ចេញទស្សនៈទាំងឡាយណាដែលអាចធ្វើឱ្យប៉ះពាល់ជាអវិជ្ជមានដល់កេរ្តិ៍ឈ្មោះ និងសុចរិតភាពរបស់អ.វ.ត.ក។

**មាត្រា ៨**

**គោលការណ៍សកម្មភាពក្រៅកិច្ចការតុលាការ**

១. ចៅក្រមមិនត្រូវចូលរួមក្នុងសកម្មភាពក្រៅកិច្ចការតុលាការណាមួយដែលមិនត្រូវជាមួយនឹងមុខងារតុលាការរបស់ខ្លួន ឬការប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលារបស់អ.វ.ត.ក ឬដែលអាចជះឥទ្ធិពល ឬទំនងជាអាចជះឥទ្ធិពលដល់ឯករាជ្យភាព និងភាពមិនលំអៀងរបស់ខ្លួន។
២. ចៅក្រមមិនត្រូវកាន់តួនាទីនយោបាយឡើយ។

**មាត្រា ៩**

**ការអនុវត្តក្រម**

១. គោលការណ៍ទាំងឡាយដែលមានចែងក្នុងក្រមនេះត្រូវចាត់ទុកជាសេចក្តីណែនាំស្តីពីបទដ្ឋានសីលធម៌ជាសារវ័ន្ត ដែលចៅក្រមត្រូវប្រកាន់ខ្ជាប់ក្នុងការបំពេញតួនាទីនិងភារកិច្ចរបស់ខ្លួន។

២. មិនមានអ្វីមួយក្នុងខ្លឹមសារនៃក្រមនេះដែលសំដៅកំណត់ ឬដាក់កំហិតតាមមធ្យោបាយណាមួយទៅលើឯករាជ្យភាពរបស់ចៅក្រមឡើយ។

អនុម័តដោយកិច្ចប្រជុំពេញអង្គ នៅថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ ២០០៨ និង វិសោធនកម្មដោយកិច្ចប្រជុំពេញអង្គ នាថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០០៨ ។

00231975

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

C 26/I/31

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌ លេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៤)

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម នីយ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ១៥ តុលា ២០០៨

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 16 / 10 / 2008
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fry

---

សាធារណៈ:

សេចក្តីសម្រេចពាក់ព័ន្ធនឹងសេចក្តីជូនដំណឹងអំពីការដកបណ្តឹងឧទ្ធរណ៍

---

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 16 / 10 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fry

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT
ពេជ្រ សម្បត្តិ
Alex BATES

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ធី
គង់ ពិសី
Silke STUZINSKY
យុង ផានិត
គឹម ម៉េងឃី
Martine JACQUIN

**ជនត្រូវចោទ**

ខៀវ សំផន

**សហមេធាវីការពារក្តី**

សា សុវ៉ាន
Jacques VERGÈS

ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខ័ណ្ឌ ដង្កោ ក្រុងភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១
ទូរស័ព្ទ: (៨៥៥)-២៣-២១៩-៨១៤ ទូរសារ: (៨៥៥)-២៣-២១៩-៨៤១ គេហទំព័រ: www.eccc.gov.kh

00231976

០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៤)

C26/I/31

១. **អង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** (**"អវតក"**) កត់សម្គាល់ឃើញមាន "សេចក្តីជូនដំណឹងអំពីការដកបណ្តឹងឧទ្ធរណ៍" ដែលសហមេធាវីការពារក្តីរបស់ជនត្រូវចោទបានដាក់ នៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨ ("សេចក្តីជូនដំណឹងអំពីការដកបណ្តឹងឧទ្ធរណ៍")។ តាមរយៈសេចក្តីជូនដំណឹងនេះ សហមេធាវីការពារក្តីបានប្រកាសដក "បណ្តឹងឧទ្ធរណ៍របស់ខ្លួន ដែលបានធ្វើឡើងប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧" ដែលបណ្តឹងឧទ្ធរណ៍នេះ បានដាក់ប្តឹង កាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៧ ("បណ្តឹងឧទ្ធរណ៍")។

២. សហមេធាវីការពារក្តីអះអាងថា ភាគីដែលដាក់បណ្តឹងឧទ្ធរណ៍ជូនអង្គបុរេជំនុំជម្រះ មានសេរីភាពក្នុងការសម្រេចបន្តប្តឹងឧទ្ធរណ៍ ឬឈប់ប្តឹងឧទ្ធរណ៍ នៅពេលណាមួយក៏បាន អាស្រ័យតាមផលប្រយោជន៍នៃសិទ្ធិរបស់ខ្លួន ក្នុងការប្តឹងឧទ្ធរណ៍ និងការដកចេញបណ្តឹងឧទ្ធរណ៍។[១] ទោះបីជាសហមេធាវីការពារក្តីសន្និដ្ឋានថា ខ្លួនមានសិទ្ធិដកបណ្តឹងឧទ្ធរណ៍ ដោយមិនចាំបាច់ពន្យល់ហេតុផលអ្វីឡើយក៏ដោយ[២] សហមេធាវីការពារក្តីបានពន្យល់ថា ខ្លួនបានសម្រេចធ្វើដូច្នេះ ដោយសារអង្គបុរេជំនុំជម្រះមិនទាន់បានចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍នេះនៅឡើយ ដែលមកទល់ពេលនេះវាមានរយៈពេលជិតដប់(១០)ខែទៅហើយ គិតចាប់តាំងពីថ្ងៃដាក់បណ្តឹងឧទ្ធរណ៍នេះ។[៣] សហមេធាវីការពារក្តីលើកឡើងថា អង្គបុរេជំនុំជម្រះមិនទាន់បានផ្តល់ហេតុផលណាមួយ ចំពោះការពន្យារពេលនេះនៅឡើយ។ សហមេធាវីការពារក្តីបានបន្ថែមទៀតថា អង្គបុរេជំនុំជម្រះមិនអើពើនឹងសិទ្ធិរបស់មេធាវីការពារក្តី នៅពេលអង្គបុរេជំនុំជម្រះសម្រេចថា នឹងចេញសេចក្តីសម្រេច ដោយផ្អែកលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ តែប៉ុណ្ណោះ។[៤]

៣. អង្គបុរេជំនុំជម្រះរំលឹកឡើងវិញថា សវនាការលើបណ្តឹងឧទ្ធរណ៍នេះបានចាប់ផ្តើមដំណើរការនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៨ ប៉ុន្តែជនត្រូវចោទបានស្នើសុំការលើកពេលសវនាការ ដោយសម្អាងថា សហមេធាវីការពារក្តីអន្តរជាតិរបស់ខ្លួន បានបដិសេធបន្តធ្វើជាតំណាងរបស់ខ្លួន ដោយសារឯកសារទាំងអស់នៅក្នុងសំណុំរឿងមិនមានជាភាសាបារាំង។ ជនត្រូវចោទបានលើកឡើងថា ខ្លួនត្រូវបានដកហូតមេធាវីការពារក្តីមួយរូប ហេតុដូច្នេះហើយ មិនមានជំនឿទុកចិត្តនៅក្នុងសវនាការបណ្តឹងឧទ្ធរណ៍នេះឡើយ។

---

[១] សេក្តីជូនដំណឹងអំពីការដកបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨ C26/I/30 វាក្យខណ្ឌទី ១។

[២] សេក្តីជូនដំណឹងអំពីការដកបណ្តឹងឧទ្ធរណ៍ វាក្យខណ្ឌទី ២១។

[៣] សេក្តីជូនដំណឹងអំពីការដកបណ្តឹងឧទ្ធរណ៍ វាក្យខណ្ឌទី ២៦។

[៤] សេក្តីជូនដំណឹងអំពីការដកបណ្តឹងឧទ្ធរណ៍ វាក្យខណ្ឌទី ២៥។

សេចក្តីសម្រេចពាក់ព័ន្ធនឹងសេចក្តីជូនដំណឹងអំពីការដកបណ្តឹងឧទ្ធរណ៍ ២

00231977

០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៩)
C26/I/31

អង្គបុរេជំនុំជម្រះ យល់ព្រមតាមសំណើសុំលើកពេលសវនាការ ដើម្បីការពារសិទ្ធិរបស់ជនត្រូវចោទ ក្នុងការទទួលបានមេធាវីតំណាងត្រឹមត្រូវ នៅចំពោះមុខអង្គបុរេជំនុំជម្រះ។[៥]

៤. នៅពេលពិចារណាកាលៈទេសៈនានា នៅពេលដែលជនត្រូវចោទស្នើសុំលើកពេលសវនាការ អង្គបុរេជំនុំជម្រះមិនមានជំហរណាមួយ ដើម្បីសម្រេចថានឹងបើកសវនាការឡើងវិញនៅពេលណាឡើយ ប្រសិនបើមិនមានការចង្អុលបញ្ជាក់ពីមេធាវីការពារក្តី។ អង្គបុរេជំនុំជម្រះបានលើកពេលសវនាការ "ទៅថ្ងៃក្រោយ ដោយអង្គបុរេជំនុំជម្រះនឹងជូនដំណឹងតាមក្រោយ"[៦] ដើម្បីទុកពេលឱ្យសហមេធាវីការពារក្តីរៀបចំខ្លួន សម្រាប់ជាប្រយោជន៍ល្អបំផុតចំពោះកូនក្តី និងដើម្បីទុកពេលឱ្យសហមេធាវីការពារក្តី ជូនដំណឹងដល់អង្គជំនុំជម្រះថា គាត់ត្រៀមខ្លួនរួចរាល់ហើយសម្រាប់បន្តកិច្ចដំណើរការនីតិវិធី។

៥. គ្មានព័ត៌មានណាមួយ ដែលជនត្រូវចោទ ឬសហមេធាវីការពារក្តីរបស់ខ្លួន ("មេធាវីការពារក្តី") បានផ្តល់ជូនអង្គបុរេជំនុំជម្រះ ក្នុងរយៈពេលបួន(៤)ខែ បន្ទាប់ពីថ្ងៃលើកពេលសវនាការ។ ដោយព្រួយបារម្ភអំពីភាពអកម្មរបស់មេធាវីការពារក្តី និងដើម្បីជៀសវាងការប៉ះពាល់ដល់ផលប្រយោជន៍របស់ជនត្រូវចោទ នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានចេញសេចក្តីបង្គាប់ដល់មេធាវីការពារក្តី ឱ្យបង្ហាញពីជំហររបស់ខ្លួនចំពោះបណ្តឹងឧទ្ធរណ៍នេះ។[៧]

៦. នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៨ សហមេធាវីការពារក្តីបានដាក់ "សេចក្តីជូនដំណឹងអំពីគោលជំហររបស់ក្រុមការពារក្តីទៅអង្គបុរេជំនុំជម្រះ ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន" ដែលនៅក្នុងសេចក្តីជូនដំណឹងនេះ សហមេធាវីការពារក្តីបានជម្រាបអង្គបុរេជំនុំជម្រះថា ខ្លួន "ទាមទារឱ្យមានការបកប្រែទាំងស្រុងនូវឯកសារសំណុំរឿងព្រហ្មទណ្ឌរបស់លោក ខៀវ សំផន។ សហមេធាវីការពារក្តីបានលើកឡើងទៀតថា "ដរាបណាការបកប្រែ មិនត្រូវបានគេធ្វើទេនោះ សហមេធាវីការពារក្តីនឹងពុំអាចធ្វើកិច្ចសហប្រតិបត្តិការជាមួយតុលាការ បានឡើយ។"[៨]

---

[៥] សេចក្តីសម្រេចលើសំណើសុំពន្យារពេលសវនាការលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៨ C26/I/25 កថាខណ្ឌទី ២។

[៦] សេចក្តីសម្រេចលើសំណើសុំពន្យារពេលសវនាការលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌទី ៥។

[៧] សេចក្តីបង្គាប់ដល់មេធាវីការពារក្តីពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ចំពោះដីកាបង្គាប់ការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៨ C26/I/27។

[៨] សេចក្តីជូនដំណឹងអំពីគោលជំហររបស់ក្រុមការពារក្តីទៅអង្គបុរេជំនុំជម្រះ ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៨ C26/I/28 កថាខណ្ឌទី៩ និងកថាខណ្ឌទី១០។

00231978

002/19-09-2007-ECCC-OCIJ (PTC05)
C26/I/31

៧. នៅថ្ងៃទី២ ខែតុលា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានចេញ "សេចក្ដីបង្គាប់ស្ដីពីការបន្តកិច្ចដំណើរការនីតិវិធីនៃបណ្ដឹងឧទ្ធរណ៍ចំពោះការឃុំខ្លួនបណ្ដោះអាសន្ន" ដោយអង្គបុរេជំនុំជម្រះវិនិច្ឆ័យថា ដោយសារ "សារណាបណ្ដឹងឧទ្ធរណ៍មិនបានលើកបញ្ហាបកប្រែ ឬពុំមានលទ្ធភាពក្នុងការតវ៉ា "បទចោទដែលត្រូវបានយកមកធ្វើជាមូលដ្ឋាននៃការឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្ន" អនុលោមតាមវិធាន៧៥(៤) នៃវិធានផ្ទៃក្នុង សហមេធាវីការពារក្ដី ត្រូវបានរារាំងចំពោះការលើកឡើងបញ្ហានេះនៅក្នុងដំណាក់កាលនេះ។[9]

៨. អង្គបុរេជំនុំជម្រះបានពិចារណាឃើញថា សេចក្ដីប្រកាសរបស់សហមេធាវីការពារក្ដី ត្រូវបានយល់ឃើញថា ជាការបដិសេធបន្តចូលរួមនៅក្នុងសវនាការដេញដោល។[10] នៅក្នុងកាលៈទេសៈទាំងនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា គ្មានហេតុផលណាមួយដែលត្រូវពន្យារពេលចេញសេចក្ដីសម្រេចទៀតឡើយ ហើយអង្គបុរេជំនុំជម្រះសម្រេចថា នឹងចេញសេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍នេះ ដោយផ្អែកលើមូលដ្ឋាននៃសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគីតែប៉ុណ្ណោះ។ អនុលោមតាមមាត្រា ៨(៤) នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារនៅ អ.វ.ត.ក អង្គបុរេជំនុំជម្រះអនុញ្ញាតឱ្យសហមេធាវីការពារក្ដីដាក់សារណាតប ក្នុងរយៈពេលប្រាំពីរ(៧)ថ្ងៃ។

៩. សហមេធាវីការពារក្ដីមិនបានដាក់សារណាតបឡើយ។ ផ្ទុយទៅវិញ សហមេធាវីការពារក្ដីបានដាក់សេចក្ដីជូនដំណឹងអំពីការដកបណ្ដឹងឧទ្ធរណ៍ នៅក្នុងចន្លោះពេលនៃកាលបរិច្ឆេទកំណត់ដាក់សារណាតប។

១០. អង្គបុរេជំនុំជម្រះសង្កេតឃើញថា វិធានផ្ទៃក្នុងមិនមានចែងបញ្ហានៃការដកបណ្ដឹងឧទ្ធរណ៍ ឬការលុបចោលនីតិវិធី ដែលធ្វើឡើងដោយភាគី។ ដូចគ្នានេះដែរ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាមិនមានចែងអំពីបទដ្ឋានណែនាំដោយផ្ទាល់ចំពោះបញ្ហានេះ។ ប៉ុន្តែ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា នៅក្នុងការអនុវត្ត តុលាការកម្ពុជាទទួលស្គាល់ថា ម្ចាស់បណ្ដឹងឧទ្ធរណ៍មានសិទ្ធិដកបណ្ដឹងឧទ្ធរណ៍របស់ខ្លួន នៅមុនពេលការបិទការដេញដោលរវាងភាគី។ ចំនុចនេះ ក៏ហាក់ដូចគ្នាទៅនឹងការអនុវត្តរបស់សាលាក្ដីអន្តរជាតិ និងអន្តរជាតូបនីយកម្មផងដែរ។[11]

---

[9] សេចក្ដីបង្គាប់ស្ដីពីការបន្តកិច្ចដំណើរការនីតិវិធីនៃបណ្ដឹងឧទ្ធរណ៍ចំពោះការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០០៨ C26/I/29 វាក្យខណ្ឌទី ៧ និង វាក្យខណ្ឌទី៨។

[10] សេចក្ដីបង្គាប់ស្ដីពីការបន្តកិច្ចដំណើរការនីតិវិធីនៃបណ្ដឹងឧទ្ធរណ៍ចំពោះការឃុំខ្លួនបណ្ដោះអាសន្ន វាក្យខណ្ឌទី ១១។

[11] *ព្រះរាជអាជ្ញា ទល់នឹង Strugar* IT-01-42-A "សេចក្ដីសម្រេចចុងក្រោយលើ"សេចក្ដីជូនដំណឹងរបស់មេធាវីការពារក្ដីអំពីការដកបណ្ដឹងឧទ្ធរណ៍" និង"ការដកបណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ដែលប្ដឹងចំពោះសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងទី ២ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៥" អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៦។ *ព្រះរាជអាជ្ញា ទល់នឹង Cermak* IT-06-90-AR65.2 "សេចក្ដីសម្រេចលើ"សេចក្ដីជូនដំណឹងអំពីការដកបណ្ដឹងឧទ្ធរណ៍" អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៨។ *ព្រះរាជអាជ្ញា ទល់នឹង Karamera* ICTR-98-44-AR72.7 "សេចក្ដីសម្រេចលើ"សំណើរបស់ការដកបណ្ដឹងឧទ្ធរណ៍ពាក់ព័ន្ធនឹង"

សេចក្ដីសម្រេចពាក់ព័ន្ធនឹងសេចក្ដីជូនដំណឹងអំពីការដកបណ្ដឹងឧទ្ធរណ៍

00231979

០០២/១៩-០៩-២០០៧-អវតក-កសចស (អវជ០៤)

C26/I/31

១១. អង្គបុរេជំនុំជម្រះយល់ឃើញថា ភាគីមានសិទ្ធិដកបណ្តឹងឧទ្ធរណ៍ រហូតដល់ពេលបិទការដេញដោលរវាងភាគី ដោយមិនចាំបាច់សុំការអនុញ្ញាត។

## ហេតុដូច្នេះអង្គបុរេជំនុំជម្រះ÷

**យល់ព្រម** ឱ្យដកបណ្តឹងឧទ្ធរណ៍ ប្រឆាំងចំពោះដីកាបង្គាប់ការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧។

ភ្នំពេញ ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

ប្រាក់ គីមសាន

---

សេចក្តីថ្លែងសម្អាងនៃសហាកម្មខក្រិដ្ឋកម្មរួម នៅក្នុងបទចោទផ្សំគំនិតក្នុងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍" អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៦។
*ព្រះរាជអាជ្ញា ទល់នឹង Sesay* SCSL-04-15-T "សេចក្តីសម្រេចលើសំណើសុំដកចៅក្រម ដែលប្តឹងជំទាស់ចៅក្រម Robertson ចំពោះកិច្ចដំណើរការទាំងអស់ នៅក្នុងរឿង RUF" អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០៤។"

សេចក្តីសម្រេចពាក់ព័ន្ធនឹងសេចក្តីជូនដំណឹងអំពីការដកបណ្តឹងឧទ្ធរណ៍ ៥

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
## វឌ្ឍនភាពអំពីការជំនុំជម្រះក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)

ដោយតុលាការយកចិត្តទុកដាក់ដល់ផលប្រយោជន៍សាធារណៈទាក់ទងនឹងការចាប់ផ្តើមជំនុំជម្រះក្តីលើកដំបូង របស់ អ.វ.ត.ក ហេតុដូចនេះ អង្គជំនុំជម្រះសូមធ្វើការបំភ្លឺអោយបានច្បាស់នូវដំណាក់កាលនានានៃនីតិវិធីដែលនៅសេសសល់ត្រូវចាត់ការបន្ត និងសូមផ្តល់ជាព័ត៌មានខ្លះៗទាក់ទងនឹងកាលបរិច្ឆេទចាប់ផ្តើមសវនាការលើរឿងក្តីឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច នេះ។

នៅថ្ងៃទី ២១ ខែ សីហា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយដែលចេញដោយសហចៅក្រមស៊ើបអង្កេត។ សហព្រះរាជអាជ្ញាបានដាក់សារណារបស់ខ្លួននៅថ្ងៃទី ០៥ ខែ កញ្ញា ហើយមេធាវីការពារក្តីបានឆ្លើយតបនឹងសារណានោះនៅថ្ងៃទី ២២ ខែ កញ្ញា។ ដើមបណ្តឹងរដ្ឋប្បវេណីក៏ត្រូវមានសិទ្ធិឆ្លើយតបផងដែរ។

អង្គបុរេជំនុំជម្រះបានស្នើសុំឲ្យអ្នកដែលមិនមែនជាភាគីនៃរឿងក្តីដាក់សារណា និងអាចដាក់ឯកសារបន្ថែម។ ការដាក់សារណា និងឯកសារបន្ថែមរបៀបនេះនឹងតម្រូវឲ្យមានពេលវេលាបន្ថែមដល់ភាគីទាំងអស់ដើម្បីឆ្លើយតប។ រាល់ឯកសារទាំងអស់ ត្រូវតែបកប្រែទៅជាភាសាផ្លូវការមួយ ឬ ច្រើនរបស់ អ.វ.ត.ក។

អង្គបុរេជំនុំជម្រះគ្រោងនឹងចេញសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនេះនៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០០៨ ហើយយើងរំពឹងទុកថា បន្ទាប់ពីកាលបរិច្ឆេទនេះទើបសំណុំរឿងនឹងត្រូវផ្ទេរមកអង្គជំនុំជម្រះសាលាដំបូង។ បន្ទាប់មកអង្គជំនុំជម្រះសាលាដំបូងនឹងស្នើទៅភាគីទាំងអស់ឲ្យផ្តល់ជូនខ្លួននូវបញ្ជីឈ្មោះសាក្សីដែលពួកគេមានបំណងឲ្យតុលាការកោះហៅចូលរួមសវនាការ និងធ្វើការប្រជុំរៀបចំសវនាការមួយដែលតាមរយៈកិច្ចប្រជុំនេះ តុលាការនឹងកំណត់កាលបរិច្ឆេទសម្រាប់សវនាការបឋម។ រយៈពេលកំណត់សម្រាប់ការផ្តល់នូវបញ្ជីឈ្មោះសាក្សីដោយសហព្រះរាជអាជ្ញា និងមេធាវីការពារក្តី និងរយៈពេលដែលត្រូវការសំរាប់ការបកប្រែ យើងរំពឹងទុកថា ការប្រជុំរៀបចំសវនាការអាចនឹងត្រូវធ្វើឡើងនាពាក់កណ្តាលខែមករា ឆ្នាំ២០០៩ ខាងមុខនេះ។

សវនាការបឋមដែលជាដំណាក់កាលនៃដំណើរការសវនាការជាសាធារណៈលើកដំបូងនឹងពិនិត្យដោះស្រាយអំពីអញ្ញត្រកម្មនានាដែលលើកឡើងដោយភាគី ពិចារណាលើបញ្ជីឈ្មោះសាក្សីដែលដាក់ដោយភាគីទាំងនោះ និងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីថ្មីៗ។ តាមរយៈសវនាការបឋមនេះ តុលាការនឹងកំណត់កាលបរិច្ឆេទនៃការចាប់ផ្តើមសវនាការលើអង្គសេចក្តី។

ដំណើរការជំនុំជម្រះក្តីដែលមានសារៈសំខាន់បែបនេះប្រកបដោយជោគជ័យគឺជាដំណើរការដ៏ស្មុគស្មាញមួយ ហើយយើងពិតជាទទួលស្គាល់ថា វាអាចប៉ះពាល់ដល់សតិអារម្មណ៍ប្រជាជនរាប់លាននាក់ដែលកំពុងរង់ចាំយុត្តិធម៌អស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ។ ផ្ទុយទៅវិញ ដំណាក់កាលនីមួយៗនៃនីតិវិធីច្បាប់ត្រូវតែអនុវត្តដោយប្រុងប្រយ័ត្ន ហើយត្រូវធ្វើឱ្យស្របតាមខ្សែបន្ទាត់ស្តង់ដារយុត្តិធម៌ដែលមានកំរិតខ្ពស់បំផុត។ ដំណើរការនេះនឹងធានាបានផងដែរនូវកេរដំណែលដ៏ល្អសម្រាប់តុលាការកម្ពុជា។

ដោយយើងកំពុងធ្វើដំណើរទៅមុខ ព័ត៌មានថ្មីៗទាក់ទិននឹងការវិវត្តន៍នៃរឿងក្តីនឹងត្រូវផ្សព្វផ្សាយតាមរយៈការិយាល័យកិច្ចការសាធារណៈនៃ អ.វ.ត.ក ។ គេហទំព័ររបស់អ.វ.ត.ក នឹងបន្តធ្វើបច្ចុប្បន្នភាពនូវវឌ្ឍនភាពនានាផងដែរនៅពេលដែលទទួលបានព័ត៌មានថ្មីៗ។

# នីតិវិធីបំបែកជនជាប់ឃុំបណ្តោះអាសន្នឱ្យនៅដាច់ពីគ្នា

ការិយាល័យសហចៅក្រមស៊ើបអង្កេតនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបំបែកអ្នកជាប់ឃុំឃាំងបណ្តោះអាសន្នទាំង៥ឲ្យនៅដាច់ពីគ្នាបន្ទាប់ពីមានការឃុំខ្លួនតាំងពីដំបូងមក ។ ជនជាប់ឃុំទាំងនោះត្រូវបានហាមមិនឲ្យមានទំនាក់ទំនងជាមួយគ្នារួមទាំងការសួរសុខទុក្ខគ្នារវាងប្តីប្រពន្ធ អៀង សារី និង អៀង ធីរិទ្ធ ផង ។ នេះមានន័យថា បុគ្គលិកមន្ទីរឃុំឃាំងបានកំណត់ជម្រើសក្នុងការប្រាស្រ័យទាក់ទងគ្នារបស់ជនជាប់ឃុំ ហើយការិយាល័យសហចៅក្រមស៊ើបអង្កេតអនុញ្ញាតឲ្យមេធាវីនិងសមាជិកក្រុមគ្រួសាររបស់អ្នកជាប់ឃុំអាចមកសួរសុខទុក្ខបាន ។ ការដាក់ឲ្យនៅដាច់ពីគ្នានេះមិនត្រឹមតែជះឥទ្ធិពលដល់ការងារតុលាការដោយសារតែវាធ្វើឲ្យប៉ះពាល់សុខភាពរបស់ជនជាប់ឃុំនោះទេ ប៉ុន្តែតាមវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងវិធានច្បាប់អន្តរជាតិមិនបានអនុញ្ញាតឲ្យមានការដាក់ឲ្យនៅដាច់ពីគ្នាបែបនេះឡើយ ។

ក្នុងការកំណត់បែបបទនៃការចាប់បង្ខំលើជនជាប់ឃុំបណ្តោះអាសន្នតាមវិធាន២១(២) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតម្រូវថា សិទ្ធិជាមូលដ្ឋានរបស់ជនជាប់ឃុំត្រូវតែសមាមាត្រនឹងភាពចាំបាច់នៃវិធានការនិងទម្ងន់នៃបទល្មើសដែលបានចោទប្រកាន់ ។ យុត្តិសាស្រ្តនេះបានឆ្លុះបញ្ចាំងពីបទបញ្ញត្តរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិនិងវិធានច្បាប់នៃការឃុំឃាំងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ។

ដំណើរការនីតិវិធីដែលធ្លាប់មាននៅតុលាការព្រហ្មទណ្ឌអន្តរជាតិនិងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានបង្ហាញថា ការដាក់ឲ្យនៅដាច់ពីគ្នានេះមិនស័ក្តិសមនឹងយកមកប្រើទេបើទោះបីជាក្នុងករណីមានជាប់ពាក់ព័ន្ធនឹងចុងចោទដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុតក៏ដោយ ។ ឧទាហរណ៍នៅក្នុងករណីព្រះរាជអាជ្ញាទល់នឹងចុងចោទ ហ្សឺម៉ែន កាតាំងហ្គា (Germain Katanga) និង ម៉ាតធ្យើ ង្គូជូឡូ ជូ (Mathieu Ngudjolo Chui) ចៅក្រមនិយាយថា ការកំណត់ព្រំដែនទៅលើការប្រាស្រ័យទាក់ទងគ្នារបស់ជនជាប់ឃុំបណ្តោះអាសន្នគឺជាវិធានការពិសេសមួយដែលតម្រូវឲ្យមានវត្តមាននៃភ័ស្តុតាងជាក់ស្តែង ដើម្បីបង្ហាញពីការប៉ុនប៉ងប្រព្រឹត្តបទល្មើសប្រឆាំងនឹងការឃុំខ្លួន ។ ការធ្វើនេះគឺដើម្បីការពារកុំឲ្យមានការរំលោភលើសិទ្ធិរបស់ជនជាប់ឃុំក្នុងគោលបំណងរៀបចំការការពារសិទ្ធិរបស់ពួកគេឲ្យបានសមស្រប ។ ករណីសំណុំរឿង ដឹឡាលីក នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី គឺជាករណីតែមួយគត់ដែលតុលាការព្រហ្មទណ្ឌអន្តរជាតិ ឬតុលាការកូនកាត់សម្រេចចេញដីកាដាក់ឲ្យជនជាប់ឃុំនៅដាច់ពីគ្នា ។ នៅក្នុងករណីនេះ



អៀង សារី

ព្រះរាជអាជ្ញាស្នើថាការដាក់ឲ្យនៅដាច់ពីគ្នា គឺដោយសារតែមានភ័ស្តុតាងជាក់ស្តែងដែលបញ្ជាក់ថាអ្នកជាប់ឃុំពីរនាក់បានប៉ុនប៉ងប្រាស្រ័យទាក់ទងគ្នាតាមរយៈការសរសេរកំណត់ត្រា ។ អាស្រ័យហេតុនេះ តុលាការសម្រេចហាមឃាត់មិនឲ្យអ្នកទាំងនេះមានការប្រាស្រ័យទាក់ទងគ្នា ហើយសម្រេចធ្វើបែបនេះនៅពេលដែលមានបណ្តឹងឧទ្ធរណ៍ផ្សេងទៀតនៅពេលអនាគត ។

មានកត្តាច្រើនដែលដាក់ទម្ងន់ទៅលើការប្រឆាំងនឹងការដាក់ឲ្យនៅដាច់ពីគ្នាក្នុងអង្គជំនុំជម្រះ ។ ទីមួយ ខុសពីករណី ឌូជូឡូ ដូ និង ឡាលីក ការិយាល័យសហព្រះរាជអាជ្ញាមិនទាន់បានស្នើឲ្យមានការដាក់ជនជាប់ឃុំឲ្យនៅដាច់ពីគ្នានៅឡើយទេ ។ ប៉ុន្តែ ការិយាល័យសហចៅក្រមស៊ើបអង្កេតបានដាក់ឲ្យមានការធ្វើបែបនេះដោយខ្លួនឯង ។

ទីពីរ ទោះបីជាការិយាល័យសហចៅក្រមស៊ើបអង្កេតបានបង្ហាញពីការព្រួយបារម្ភថា ជនជាប់ឃុំយាំងនឹងឃុបឃិតជាមួយគ្នាប្រសិនបើយើងអនុញ្ញាតឲ្យជនជាប់ឃុំនៅទាក់ទងគ្នាបាន ប៉ុន្តែការិយាល័យសហចៅក្រមស៊ើបអង្កេតមិនទាន់បានបង្ហាញជាសាធារណៈពីភ័ស្តុតាងជាក់ស្តែងនៃការប៉ុនប៉ងឃុបឃិតគ្នាយោងទៅតាមដំណើរការនីតិវិធីអន្តរជាតិដែលធ្លាប់មានពីមុនមក ។ ជនជាប់ឃុំបានរស់នៅយ៉ាងមានសេរីភាពអស់រយៈពេលជាង ៣០ឆ្នាំមកហើយ បន្ទាប់ពីខ្លួនបានប្រព្រឹត្តឧក្រិដ្ឋកម្មនិងមានពេលវេលាជាច្រើនសម្រាប់សហការគ្នា ។ ប៉ុន្តែការិយាល័យសហចៅក្រមស៊ើបអង្កេតបានអះអាងថា អ្នកនៅជាប់ឃុំទាំងនោះមិនបានគិតថាចង់ឃុបឃិតគ្នាទេ ប៉ុន្តែអ្នកទាំងនោះនឹងធ្វើដូច្នេះពីព្រោះ បច្ចុប្បន្នគាត់កំពុងតែត្រូវចោទប្រកាន់ ។ ប៉ុន្តែយោងទៅតាមករណីដឺឡាលីក ប្រសិនមិនមានភ័ស្តុតាងជាក់ស្តែងបញ្ជាក់ពីការប៉ុនប៉ងឃុបឃិតគ្នា ការព្រួយបារម្ភនេះមិនមែនជាភាពចាំបាច់ដែលធ្វើឲ្យយើងអាចរំលោភទៅលើសិទ្ធិមូលដ្ឋានរបស់ជនជាប់ឃុំបណ្តោះអាសន្នបានទេ ។




ទីបី មានការអះអាងដ៏រឹងមាំមួយថា ការដាក់ឲ្យជនជាប់ឃុំនៅដាច់ពីគ្នាគឺជាកាយវិការដែលមិនផ្តល់ផលប្រយោជន៍អ្វីដល់តុលាការសោះឡើយ ។ ការដាក់ឲ្យនៅដាច់ពីគ្នារយៈពេលយូរអាចធ្វើឲ្យខូចសុខភាពផ្លូវចិត្តជនជាប់ឃុំដែលមានសុខភាពមិនល្អស្រាប់ ហើយក៏អាចជះឥទ្ធិពលដល់ជនជាប់ឃុំ ធ្វើឲ្យគេមិនអាចប្រឈមមុខនឹងអង្គជំនុំជម្រះបាន ។ ការសួរសុខទុក្ខពីសំណាក់មិត្តភក្តិក្រុមគ្រួសារនិងមេធាវីមិនអាចជួយសម្រួលដល់ផលអាក្រក់ដែលបណ្តាលមកពីការដាក់ឲ្យនៅដាច់ពីគ្នាបានទេ ។ ប៉ុន្តែការសួរសុខទុក្ខបែបនេះ អាចផ្តល់ឱកាសដល់ជនជាប់ឃុំឃុបឃិតជាមួយគ្នា អាស្រ័យហេតុនេះគួរតែបង្អាក់ការដាក់ឲ្យជនជាប់ឃុំនៅដាច់ពីគ្នា ។

ការដាក់ឲ្យនៅដាច់ពីគ្នាងាយស្រួលនឹងទទួលរងការរិះគន់ដោយសារវាគឺជាវិធានការមួយដែលមានគោលបំណងធ្វើឲ្យជនជាប់ឃុំបណ្តោះអាសន្នមិនមានភាពសុខស្រួលជាជាងការពារដំណើរការនីតិវិធី ។ ដូច្នេះ តុលាការត្រូវតែយកចិត្តទុកដាក់ពិចារណាលើគោលការណ៍ច្បាប់និងលទ្ធផលនៃការដាក់ឲ្យនៅដាច់ពីគ្នា ខណៈពេលដែលតុលាការព្យាយាមប្រកាន់ខ្ជាប់នូវបទដ្ឋានខ្ពស់បំផុតនៃសិទ្ធិមនុស្សនិងយុត្តិធម៌ ។

**អានី ហ្គេល**

# ការពន្យារពេលឃុំខ្លួន នួន ជា

នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានរកឃើញមូលហេតុច្បាស់លាស់ក្នុងការជឿថា នួន ជា បានប្រព្រឹត្តបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិនិងឧក្រិដ្ឋកម្មសង្គ្រាម និងបានបញ្ជាឲ្យមានការឃុំខ្លួនបណ្តោះអាសន្ន «សម្រាប់រយៈពេលមិនលើសពីមួយឆ្នាំ» ។ នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានពន្យារការឃុំខ្លួនរបស់ នួន ជា មួយឆ្នាំបន្ថែមទៀត ។ នួន ជា កំពុងតែប្តឹងតវ៉ាចំពោះបទបញ្ជានេះ ។

វិធានផ្ទៃក្នុង៦៣របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអនុញ្ញាតឲ្យជនដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិនិងឧក្រិដ្ឋកម្មសង្គ្រាមត្រូវឃុំខ្លួនសម្រាប់រយៈពេលមួយឆ្នាំដំបូង ដែលអាចត្រូវបានពន្យារពីរដងជាអតិបរមា ។ ហេតុដូចនេះ ប្រសិនបើមានលក្ខខណ្ឌចាំបាច់នៅតែបន្តមាន នួន ជា អាចត្រូវសម្រេចឲ្យជាប់ក្នុងការឃុំខ្លួន ដោយមិនត្រូវបានចោទប្រកាន់ជាផ្លូវការ រហូតដល់ខែកញ្ញា ឆ្នាំ២០១០ ។

វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតម្រូវឲ្យមានដីកាឃុំខ្លួនបណ្តោះអាសន្ន ដើម្បីពន្យល់ឲ្យបានក្បោះក្បាយពីហេតុផលតាមផ្លូវច្បាប់និងមូលដ្ឋានអង្គហេតុសម្រាប់ការឃុំខ្លួនអ្នកដែលត្រូវបានគេចោទប្រកាន់ ។ (វិធានផ្ទៃក្នុង៦៣៣) ចែងថា សហចៅក្រមស៊ើបអង្កេតមានហេតុផលច្បាស់លាស់ដើម្បីជឿថា ជនដែលជាប់ឃុំបានប្រព្រឹត្តបទឧក្រិដ្ឋដែលគាត់ត្រូវបានគេចោទប្រកាន់ ។ សហចៅក្រមស៊ើបអង្កេតយល់ឃើញថាការឃុំខ្លួនបណ្តោះអាសន្នជាវិធានការចាំបាច់ដើម្បី ៖



នួន ជា

១) រារាំងកុំឲ្យជនដែលត្រូវចោទគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬ រារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិតចំពោះបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។

២) ថែរក្សាភ័ស្តុតាង ឬ ការពារមិនឲ្យបំផ្លាញភ័ស្តុតាង ។

៣) ធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី ។

៤) ការពារសន្តិសុខឲ្យជនដែលត្រូវចោទ ឬ

៥) ថែរក្សាសណ្តាប់ធ្នាប់សាធារណៈ ។

នៅក្នុងដីកាពន្យារពេលការឃុំខ្លួនរបស់ នួន ជា សហចៅក្រមស៊ើបអង្កេតបាននិយាយថា សេចក្តីថ្លែងការណ៍ថ្មីចំនួន២៣ ដោយជនត្រូវចោទ កាំង ហ្កេកអ៊ាវ ចំពោះតួនាទីរបស់ នួន ជា នៅមន្ទីរ ស-២១ បានផ្តល់ការគាំទ្របន្ថែមទៀតសម្រាប់ជំនឿដែលបានរកឃើញថា គាត់បានប្រព្រឹត្តបទឧក្រិដ្ឋទាំងឡាយដែលបានចោទប្រកាន់ ។ សហចៅក្រមស៊ើបអង្កេតមិនបានពិភាក្សាអំពីលក្ខខណ្ឌចំនួនប្រាំដទៃទៀតទេ ប៉ុន្តែបានឃើញថា «មូលហេតុនានារបស់អង្គបុរេជំនុំជម្រះវិសាមញ្ញនៅក្នុងសេចក្តីសម្រេចនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨ នៅតែមានសុពលភាព» ។

វិធានផ្ទៃក្នុង៦៣(៧) តម្រូវឲ្យសហចៅក្រមស៊ើបអង្កេតផ្តល់នូវមូលហេតុជាលាយលក្ខណ៍អក្សរ ដើម្បីពន្យារការឃុំខ្លួនបណ្តោះអាសន្ននេះ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានសង្កត់ថា ការសើរើការឃុំខ្លួនបណ្តោះអាសន្នគឺចាំបាច់ក្នុងផ្លូវច្បាប់ទើបឲ្យអង្គជំនុំជម្រះមួយ «អាចធានាខ្លួនឯងថានៅតែមានមូលហេតុនានាសម្រាប់ធ្វើឲ្យការឃុំខ្លួន» ។ នេះមានសារសំខាន់ច្រើនជាងការដែលជនត្រូវចោទត្រូវសម្រេចឲ្យឃុំខ្លួនរយៈពេលយូរ ។ ឧទាហរណ៍ គណៈកម្មការសិទ្ធិមនុស្សនៅទ្វីបអាមេរិកបានរកឃើញថា «ប្រសិទ្ធភាពនៃការធានាផ្លូវច្បាប់គួរតែបង្កើនឡើងឲ្យសមស្របទៅនឹងពេលវេលាដែលបានឃុំខ្លួនគាត់បណ្តោះអាសន្ន» ។

យុត្តិសាស្ត្រនៃស្ថាប័នសិទ្ធិមនុស្សដូចជា គណៈកម្មការសិទ្ធិមនុស្សនៅទ្វីបអាមេរិក តុលាការសិទ្ធិមនុស្សអឺរ៉ុបនិងគណៈកម្មាធិការសិទ្ធិមនុស្ស មិនគាំទ្រចំពោះការឃុំខ្លួនបណ្តោះអាសន្នទេ និងបានដាក់បន្ទុកទៅលើរដ្ឋនីមួយៗដើម្បីសម្រេចពីការឃុំខ្លួនបន្ត ។ ផ្ទុយទៅវិញ តុលាការព្រហ្មទណ្ឌអន្តរជាតិនិងតុលាការព្រហ្មទណ្ឌចម្រុះបានចាត់ទុកថាការដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្នជាការលើកលែង ហើយដាក់ស្តែងបានដាក់បន្ទុកទៅលើចុងចោទឲ្យបង្ហាញថាការដោះលែងមានភាពចាំបាច់ ។ គួរឲ្យកត់សម្គាល់ផងដែរថា ទាំងតុលាការពិសេសសម្រាប់សេរ៉ាឡេអូននិងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វាន់ដាមិនដែលធ្លាប់អនុញ្ញាតឲ្យមានការដោះលែងជាបណ្តោះអាសន្នដល់ជនជាប់ចោទឡើយ ។ តុលាការទាំងនេះបានបញ្ជាក់អំពីការរឹតបន្តឹងដោយផ្អែកដោយសង្កត់ទៅលើភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋនានាដែលពួកគេបានកាត់ទោស ។

ទោះបីជាមានចំណុចចាប់ផ្តើមខុសគ្នាក៏ដោយ ក៏ស្ថាប័នសិទ្ធិមនុស្សនានានិងតុលាការអន្តរជាតិឬតុលាការចម្រុះទាំងឡាយបានចាប់យកវិធីសាស្ត្រស្រដៀងគ្នាក្នុងការកំណត់ថាតើកត្តាណាដែលបញ្ជាក់ពីការឃុំខ្លួន ។ ពួកគេមើលទៅលើស្ថានភាពនីមួយៗសំណុំរឿងនីមួយៗនិងកត្តាតុល្យភាពទាំងឡាយ រួមមានទាំងការបញ្ជាក់ផ្សេងៗនៅក្នុងវិធាន៦៣(៣) ។ ស្ថាប័នសិទ្ធិមនុស្សតែងតែទាមទារជាទូទៅថា កត្តានានាដែលបង្ហាញហេតុផលសម្រាប់ការឃុំខ្លួនអាចត្រូវបានពិភាក្សានៅក្នុងរបៀបដែល «ច្បាស់និងជាក់លាក់» និងមិនមាន «លក្ខណៈតែមួយ» ។ ផ្ទុយទៅវិញ តុលាការអន្តរជាតិនិងតុលាការចម្រុះនានាទំនងជាយល់ព្រមទៅលើដំណោះស្រាយជាទូទៅទាំងឡាយសម្រាប់ការឃុំខ្លួន ។

ប្រភពទាំងនេះបញ្ជាក់ដោយប្រយោលថា នៅក្នុងការពន្យារការឃុំខ្លួនរបស់ នួន ជា សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចបង្ហាញថាលក្ខខណ្ឌទាំងប្រាំនៅក្នុងវិធាន៦៣នៅតែមានបន្ត គឺយ៉ាងហោចណាស់នៅក្នុងរបៀបជាទូទៅនិងមិនត្រឹមតែយោងទៅលើសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះនោះទេ ។ ទោះជាយ៉ាងណាក៏ដោយ ស្របតាមការអនុវត្តរបស់តុលាការអន្តរជាតិនិងតុលាការចម្រុះ អង្គបុរេជំនុំជម្រះនឹងទំនងជាសម្រេចថាបន្ទុកគឺធ្លាក់ទៅលើ នួន ជា ដើម្បីបង្ហាញថាតើហេតុអ្វីបានលែងមានការឃុំខ្លួនបន្តទៀត ។

**អាន ហេនដល**

# អនុស្សរណៈ

## សុពលភាពនៃការពន្យារដែនអាជ្ញាយុកាលច្បាប់សម្រាប់ឧក្រិដ្ឋកម្មជាតិរបស់កម្ពុជា ដែលត្រូវកាត់សេចក្តីនៅមុខអង្គជំនុំជម្រះវិសាមញ្ញនិងការជាប់ពាក់ព័ន្ធនៅនឹងប្រតិសកម្ម

### ១) សេចក្តីផ្តើម

*អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានបង្កើតឡើងជាតុលាការកូនកាត់ដែលមានលក្ខណៈជាតិនិងអន្តរជាតិ ហើយមានអំណាចចោទប្រកាន់ទាំងឧក្រិដ្ឋកម្មជាតិនិងអន្តរជាតិ ។ ដើម្បីសម្រេចគោលបំណងនេះ មាត្រា៣នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញចែងយ៉ាងច្បាស់អំពីក្រមដាក់លាក់ស្តីពីយុត្តាធិការរបស់តុលាការដែលចាត់ទុកថាជាបទឧក្រិដ្ឋនៅក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ។ ដោយហេតុថា បទឧក្រិដ្ឋនៅក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦មានដែនអាជ្ញាយុកាលកំណត់ត្រឹមតែរយៈពេល១០ឆ្នាំ មាត្រា៣ក៏បានពន្យារពេលលើដែនអាជ្ញាយុកាលនេះរហូតដល់៣០ឆ្នាំទៀត ។ ការពន្យារពេលនេះចោទជាសំណួរប្រតិសកម្មឡើង ដោយសារយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអនុវត្តបានចំពោះតែបទឧក្រិដ្ឋដែលប្រព្រឹត្តឡើងរវាងឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ប៉ុណ្ណោះ ។*

*វាជាគោលការណ៍ដែលមានការទទួលស្គាល់ជាទូទៅសម្រាប់ច្បាប់អន្តរជាតិដែលហាមប្រាមមិនឲ្យអនុវត្តច្បាប់ព្រហ្មទណ្ឌប្រតិសកម្ម (ex post facto) ដែលអត្ថន័យពាក្យនេះជាភាសាឡាតាំងមានន័យថា «ក្រោយពីមានអង្គហេតុកើតឡើង» ។*

*គ្មានជនណាម្នាក់ត្រូវបានសម្រេចថាមានទោសចំពោះបទល្មើសឧក្រិដ្ឋទៅលើសសកម្មភាពណាមួយឬការខកខានដែលបានបង្កើតទៅជាបទល្មើសឧក្រិដ្ឋនៅក្រោមច្បាប់ជាតិនិងអន្តរជាតិនៅពេលដែលបទឧក្រិដ្ឋនោះត្រូវបានប្រព្រឹត្តឡើង ។ មិនមានទណ្ឌកម្មធ្ងន់ធ្ងរណាយកមកអនុវត្តជាងទណ្ឌកម្មដែលយកមកអនុវត្តនៅពេលដែលបទល្មើសឧក្រិដ្ឋត្រូវបានប្រព្រឹត្តឡើងនោះទេ ។ ប៉ុន្តែប្រសិនបើបទបញ្ញត្តិត្រូវបានធ្វើឡើងតាមច្បាប់សម្រាប់ការដាក់ទណ្ឌកម្មស្រាល នោះជនល្មើសអាចទទួលបានផលប្រយោជន៍តាមរយៈបទបញ្ញត្តិនេះ ។*

*ដូច្នេះ ប្រសិនបើបទបញ្ញត្តិធ្វើឡើងក្រោយរឿងរ៉ាវ (អង្គហេតុ) កើតឡើង ហើយមានប្រតិសកម្មទៅនឹងបញ្ញត្តិ នោះច្បាប់ត្រូវបានហាមប្រាម ។ បន្ថែមលើសពីនេះទៀត ប្រទេសជាច្រើនបានដាក់បញ្ចូលការហាមប្រាមនៃការបង្កើតច្បាប់ប្រតិសកម្មទៅក្នុងរដ្ឋធម្មនុញ្ញរបស់ខ្លួន ។ ការទទួលស្គាល់ជាទូទៅនេះឆ្លុះបញ្ចាំងអំពីទស្សនៈដែលគោលការណ៍ប្រតិសកម្មធានាបាននូវយុត្តិធម៌ជាសារវន្ត ហើយការពារប្រឆាំងនឹងបទឧក្រិដ្ឋដែលជំរុញឬបង្កឡើងដោយភាពមិនសមស្រប ។*

*តុលាការជាតិចែងច្បាស់លាស់ថា មុនពេលដែលដែនអាជ្ញាយុកាលចាប់ផ្តើមដំណើរការ អំឡុងពេលនេះគឺគ្រាន់តែជាបញ្ហានីតិវិធីមួយប៉ុណ្ណោះ ហើយអាចពន្យារពេលដោយគ្មានពាក់ព័ន្ធនឹងការបង្កើតច្បាប់ប្រតិសកម្មឡើយ ។ បញ្ហានេះកាន់តែមានលក្ខណៈចម្រូងចម្រាសថែមទៀត បន្ទាប់ពីដែនអាជ្ញាយុកាលចាប់ផ្តើមដំណើរការ ។ ដូច្នេះយោងតាមការសម្រេចរបស់កម្ពុជា ដើម្បីពន្យារពេលលើដែនកំណត់ចំពោះបទល្មើសជាតិ សំណួរបីក៏បានចោទសួរឡើង ។ ទីមួយថាតើដែនកំណត់អាជ្ញាយុកាលចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្តក្នុងរបបខ្មែរក្រហមបានបញ្ចប់ហើយឬនៅពេលដែលច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានអនុម័តរួច ឬថាតើដែនកំណត់អាជ្ញាយុកាលត្រូវបានពន្យារពេលហើយឬនៅពេលដែលប្រព័ន្ធតុលាការកម្ពុជាមិនអាចដំណើការទៅរួចដោយសារតែបញ្ហាខ្មែរក្រហម ។ ទីពីរ ប្រសិនបើតុលាការរកឃើញថាដែនអាជ្ញាយុកាលបានដំណើររួចទៅហើយ សំណួរបន្ទាប់សួរថាតើការរំលោភបំពានទៅលើគោលការណ៍ប្រតិសកម្មពិតជាបន្តបទឧក្រិដ្ឋដែលរារាំងដោយពេលវេលាដែរឬទេ ។ នៅចុងបញ្ចប់ ឧបមាថាដែនអាជ្ញាយុកាលហួសកាលកំណត់ ហើយថាការសើរើឡើងវិញគឺជាការរំលោភបំពានលើគោលការណ៍*

ប្រតិសកម្ម សំណួរទីបីសួរថាតើមានការពិចារណាផ្សេងទៀតទេ ដែលអាចផ្តល់ការដោះសាដោយសមហេតុផល ដើម្បីទុកការពិភាក្សាលើដែនអាជ្ញាយុកាលដោយឡែក ហើយនាំយកជនដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើឃោរឃៅដែលរំលោភបំពានច្បាប់កម្ពុជាមកធ្វើការជំនុំជម្រះទោស ។

## ២) ការប្រព្រឹត្តទៅរបស់ដែនអាជ្ញាយុកាលសម្រាប់បទឧក្រិដ្ឋថ្នាក់ជាតិ

ដូចដែលបានបញ្ជាក់ខាងលើ ដែនអាជ្ញាយុកាលសម្រាប់បទឧក្រិដ្ឋធ្ងន់ធ្ងរនៅក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦មានរយៈកាល១០ឆ្នាំ ហើយបទឧក្រិដ្ឋដែលស្ថិតក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគិតចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ បទឧក្រិដ្ឋថ្នាក់ជាតិគ្របដណ្តប់ដោយក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ហើយស្ថិតក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ គឺអំពើមនុស្សឃាត ទារុណកម្ម និងការធ្វើទុក្ខបុកម្នេញលើសាសនា ។ ដូច្នេះ ប្រសិនបើដែនអាជ្ញាយុកាលដែលកំណត់ធ្វើឡើងនៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ចំពោះបទឧក្រិដ្ឋទាំងនេះ ពេលវេលាសម្រាប់ការចោទប្រកាន់គួរតែមានរហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៨៩ ។ ប៉ុន្តែកត្តាផ្សេងៗមួយចំនួនអាចពន្យារដែនអាជ្ញាយុកាលនោះ ។ ការពន្យារពេលនេះសំដៅទៅលើការអាក់ខានមិនឲ្យអនុវត្តដែនអាជ្ញាយុកាលដែលបានកំណត់ ។ ពេលវេលាដែលដែនអាជ្ញា-យុកាលត្រូវបានពន្យារមិនរាប់បញ្ចូលកាលបរិច្ឆេទបន្ទាប់ពីការចោទប្រកាន់ដែលមានការរារាំងដោយពេលវេលាទេ ។ កិច្ចខិតខំប្រឹងប្រែងរបស់តុលាការជាតិដើម្បីចោទប្រកាន់បទឧក្រិដ្ឋទាក់ទងនឹងដែនអាជ្ញាយុកាលចង្អុលបង្ហាញថា ការពន្យារពេលអាចកើតឡើងនៅពេលប្រព័ន្ធតុលាការដែលទទួលខុសត្រូវចំពោះការចោទប្រកាន់មិនអាចដំណើរការបាន ឬនៅពេលអំពើរបស់ជនត្រូវចោទធ្វើឲ្យមានការចោទប្រកាន់កើតឡើង ។

ឧទាហរណ៍ បន្ទាប់ពីមានអំពើឃោរឃៅរបស់ណាហ្ស៊ី ប្រទេសអាល្លឺម៉ង់ខាងលិចស្ទុះស្ទែងធ្វើការចោទប្រកាន់បុគ្គលផ្សេងៗមួយចំនួនដែលមិនត្រូវបានជំនុំជម្រះនៅតុលាការនូរឹមបឺក ចំពោះអំពើមនុស្សឃាតដែលប្រព្រឹត្តឡើងមុនឆ្នាំ១៩៤៥ ។ ជាលទ្ធផល នៅឆ្នាំ១៩៦៥ រដ្ឋាភិបាលអាល្លឺម៉ង់ខាងលិចប្រឈមមុខជាមួយបញ្ហាស្រដៀងគ្នាទៅនឹងបញ្ហាដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកំពុងតែជួបប្រទះ ។ ដែនអាជ្ញា-យុកាលរយៈពេល២០ឆ្នាំចំពោះអំពើមនុស្សឃាតដែលរដ្ឋាភិ-បាលអាល្លឺម៉ង់ខាងលិចកំណត់យកចាប់ពីខែឧសភា ឆ្នាំ១៩៤៥ ត្រូវបានផុតកំណត់ ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលនោះតុលាការនិងព្រះរាជអាជ្ញាមិនបានរៀបចំធ្វើការចោទប្រកាន់ជនត្រូវចោទសំខាន់ៗឡើយ ។ ដូច្នេះ ដើម្បីឆ្លើយតបទៅនឹងបញ្ហានេះ នៅខែមីនា ឆ្នាំ១៩៦៥ សភាជាតិអាល្លឺម៉ង់បានសម្រេចថា ដែនកំណត់អាជ្ញាយុកាលមិនបានចាប់ផ្តើមរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៤៩ ទេ ដោយសារថា «តុលាការអាល្លឺម៉ង់មិនមានសមត្ថភាពដំណើរការពីឆ្នាំ១៩៤៥ដល់ឆ្នាំ ១៩៤៩» ។

ប្រទេសអាល្លឺម៉ង់ពន្យារពេលដែនអាជ្ញាយុកាលដល់៤ឆ្នាំកន្លះទៀត ។ ការពន្យារដែនអាជ្ញាយុកាលដោយសារតែអសមត្ថភាពរបស់តុលាការមិនមែនជាទស្សនាទានប្រលោមលោកទេ ។ ឧទាហរណ៍នៅសហរដ្ឋអាមេរិក «សំណុំរឿងក្តីផ្នែកច្បាប់ទៅលើការពន្យារពេលត្រឹមត្រូវនៅក្នុងបរិបទកតិកាសញ្ញាស្តីពីការអះអាងទៅលើការដកហូតសិទ្ធិមនុស្សដោយអយុត្តិធម៌និងកតិកាសញ្ញាស្តីពីការការពារជនរងគ្រោះដោយអំពើទារុណកម្ម *(ATCA [Alien Tort Claims Act] and TVPA [Torture Victim Protection Act])* អាចយកមកប្រើប្រាស់បាន ។ ជាពិសេសតុលាការសហរដ្ឋអាមេរិករកឃើញថា ដែនអាជ្ញាយុកាលគួរតែត្រូវពន្យារពេល «នៅពេលដែល ១) ការប្រព្រឹត្តខុសឆ្គងរបស់ចុងចោទរារាំងដើមបណ្តឹងមិនឲ្យទាមទារសំណង ឬ២) កាលៈទេសៈពិសេសក្រៅពីការគ្រប់គ្រងដើមបណ្តឹងធ្វើឲ្យមិនអាចទៅរួចដើម្បីទាមទារសំណងទាន់ពេលវេលា ។ សរុបមកដែនអាជ្ញាយុកាលអាចដំណើរការបាននៅពេលដែលសវនាការអាចធ្វើទៅរួច ។

ប្រទេសផ្សេងទៀតអនុវត្តតាមវិធីសាស្ត្រស្រដៀងគ្នានេះ ។ នៅដើមទសវត្សរ៍ឆ្នាំ១៩៩០ ប្រទេសរូម៉ានីបានពន្យារពេលលើដែនអាជ្ញាយុកាលចំពោះបទឧក្រិដ្ឋមនុស្សឃាតអំឡុងពេលនៃការកាន់អំណាចរបស់ពួកកុម្មុយនីស្ត ដូច្នេះ អាចអនុញ្ញាតឲ្យមានការចោទប្រកាន់ចំពោះអំពើមនុស្សឃាតទៅលើជនដែល

ប្រឆាំងនឹងគោលនយោបាយរដ្ឋាភិបាលក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៥០ និងឆ្នាំ១៩៦០»។ ប្រទេសសាធារណរដ្ឋឆេកអនុវត្តទៅលើចំណុចនេះដូចគ្នា ។ តុលាការធម្មនុញ្ញឆេកផ្តល់ហេតុថា ចុងចោទមិនអាចទទួលបានផលប្រយោជន៍ពីដែនអាជ្ញាយុកាលនៅពេលដែលចុងចោទខ្លួនឯងទទួលខុសត្រូវចំពោះការបរាជ័យរបស់របបកុម្មុយនីស្ត ដើម្បីកាត់សេចក្តីទៅលើបទឧក្រិដ្ឋឲ្យទាន់ពេលវេលាទេ ។ តុលាការបញ្ជាក់ថា ដែនអាជ្ញាយុកាលអាចអនុវត្តបាន «ប្រសិនបើមានសកម្មភាពទាក់ទងគ្នាទៅវិញទៅមកជាសារវន្តរយៈពេលវែងរវាងធាតុផ្សំពីរគឺចេតនានិងកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋដើម្បីដាក់ទណ្ឌកម្មជនល្មើស និងគ្រោះថ្នាក់កំពុងកើតមានចំពោះជនល្មើសដែលជនល្មើសអាចទទួលទោសទណ្ឌ ហេតុនេះហើយធាតុផ្សំទាំងពីរនេះផ្តល់អត្ថន័យពិតប្រាកដចំពោះការបង្កើតឲ្យមានដែនអាជ្ញាយុកាលលើសកម្មភាព» ។ ដូច្នេះ តុលាការថែងថា អាជ្ញាយុកាលមិនអាចចាប់ផ្តើមបានរហូតដល់ឆ្នាំ១៩៨៩ នៅពេលដែលការចោទប្រកាន់មន្ត្រីកុម្មុយនីស្ត ចុងក្រោយអាចធ្វើទៅរួចបន្ទាប់ពីរបបកុម្មុយនីស្តដួលរលំហើយ «ប្រព័ន្ធរបស់ការចោទប្រកាន់ (មិនមែន) លែងមានសុពលភាព» ។ នៅទីបំផុតលទ្ធភាពចោទប្រកាន់លើបទឧក្រិដ្ឋធ្ងន់ធ្ងរគឺសំខាន់មិនអាចអត់បានសម្រាប់ដំណើរការដែនអាជ្ញាយុកាល ។

ទោះបីយ៉ាងណាក៏ដោយ វិធីសាស្ត្រនេះមិនមានលក្ខណៈជាសកលឡើយ ។ ឧទាហរណ៍ ប្រទេសហុងគ្រីបន្ទាប់ពីស្ថានការណ៍កុម្មុយនីស្តមានលក្ខណៈស្រដៀងគ្នាទៅនឹងសាធារណរដ្ឋឆេក បានបដិសេធមិនធ្វើការចោទប្រកាន់បុគ្គលជាច្រើនចំពោះបទឧក្រិដ្ឋនៅពេលដែលដែនអាជ្ញាយុកាលហួសកំណត់ទៅហើយ ។ តុលាការធម្មនុញ្ញហុងគ្រីផ្តោតសំខាន់ទៅលើគោលការណ៍ជាក់លាក់របស់ច្បាប់និងសារសំខាន់របស់នីតិរដ្ឋក្នុងការបង្កើតរដ្ឋាភិបាលប្រជាធិបតេយ្យថ្មីមួយដោយស្របច្បាប់ ។ អ្នកស្រាវជ្រាវជាន់ខ្ពស់ផ្តល់យោបល់ថា ភាពខុសគ្នានៅក្នុងវិធីសាស្ត្ររបស់ប្រទេសហុងគ្រីនិងសាធារណរដ្ឋឆេក គឺដោយសារការគាបសង្កត់ធ្ងន់ធ្ងរទៅលើប្រទេសទាំងពីរនេះ ប៉ុន្តែប្រទេសហុងគ្រីទទួលរងការគាបសង្កត់ពីរបបកុម្មុយនីស្តតិចជាងសាធារណរដ្ឋឆេក ។

កាលៈទេសៈនៅក្នុងប្រទេសកម្ពុជាអាចវាយតម្លៃស្រដៀងគ្នាដើម្បីកំណត់ពេលវេលាទៅលើដែនអាជ្ញាយុកាលចំពោះបទឧក្រិដ្ឋក្នុងរបបខ្មែរក្រហមដែលគួរតែចាប់ផ្តើម ។ អង្គជំនុំជម្រះវិសាមញ្ញអាចពិនិត្យមើលទៅលើកត្តាជាច្រើនដូចជា ការបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធនៅក្នុងប្រទេសកម្ពុជា រួមមាន វិស័យតុលាការ ការសម្លាប់បំផុតពូជប្រជាជនដែលមានក្រមចៅក្រមនិងមេធាវីមួយចំនួនតូច និងជម្លោះដែលកើតឡើងបន្តយាយីប្រទេសនេះអស់រយៈកាលជាច្រើនទសវត្សរ៍ បន្ទាប់ពីការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យ ។ លើសពីនេះទៀត តុលាការត្រូវតែពិចារណាឲ្យបានច្បាស់លាស់ថា ការបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធតុលាការរបស់ប្រទេសទាំងមូលគឺជាទំហំនៃការបាត់បង់ដែលមិនអាចឲ្យអ្នកធ្វើសេចក្តីព្រាងច្បាប់ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ទាយទុកជាមុនបាន នៅពេលដែលអ្នកធ្វើសេចក្តីព្រាងច្បាប់ទាំងនេះកំណត់យកដែនអាជ្ញាយុកាលត្រឹមតែរយៈពេល១០ឆ្នាំទៅលើបទឧក្រិដ្ឋធ្ងន់ធ្ងរ ។ ការបំផ្លិចបំផ្លាញយន្តការយុត្តិធម៌ពីរបបខ្មែរក្រហម បានប៉ះពាល់យ៉ាងខ្លាំងដល់ចេតនាច្បាប់និងការគាំទ្រសេចក្តីត្រូវការដើម្បីពន្យារពេលការអនុវត្តច្បាប់រហូតដល់មានការកំណត់ថា ចេតនាសមស្របរបស់ច្បាប់ត្រូវបានស្តារឡើងវិញ ។ ដូច្នេះ ប្រសិនបើតុលាការរកឃើញថា ដែនអាជ្ញាយុកាលត្រូវបានពន្យារពេលដោយសារការចោទប្រកាន់ទៅលើរបបខ្មែរក្រហមមិនអាចទៅរួច បញ្ហាគោលការណ៍ប្រតិសកម្មគួរតែមិនគំរាមកំហែងដល់ភាពស្របច្បាប់នៃការពន្យារពេលដែនអាជ្ញា-យុកាលដែលមានរយៈពេលត្រឹម៣០ឆ្នាំឡើយ ។ ដែនអាជ្ញា-យុកាលមិនអាចបញ្ចប់ដោយផ្អែកលើដំណើរការរបស់ច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឡើយ ។

### ៣) ការជាប់ពាក់ព័ន្ធនៃការហាមប្រាមទៅលើគោលការណ៍ប្រតិសកម្មស្តីពីដែនអាជ្ញាយុកាល

តុលាការថែងថា ដែនអាជ្ញាយុកាលបានដំណើររួចទៅហើយ ។ នៅក្រោមកាលៈទេសៈបែបនេះ សំណួរអាចសួរថាតើការពន្យារពេលដែនអាជ្ញាយុកាលរំលោភទៅលើការហាមប្រាមគោលការណ៍ប្រតិសកម្មដែរឬទេ ។ ចៅក្រមរបស់អង្គជំនុំជម្រះវិសាមញ្ញត្រូវតែជ្រើសរើសរវាងវិធីសាស្ត្រពីរមកអនុវត្ត ។ ចៅក្រមអាចទទួលយកភាពសមហេតុផលនៅក្នុងអត្ថបទនេះ

ដោយមើលលម្អិតទៅលើកិច្ចព្រមព្រៀងអន្តរជាតិផ្សេងៗ នៅក្នុងអត្ថបទ ដើម្បីកំណត់ថាតើវិសោធនកម្មទៅលើដែនអាជ្ញាយុកាលជាប់ពាក់ព័ន្ធនឹងគោលការណ៍ប្រតិសកម្មដែរឬទេ ។ តាមជម្រើសផ្សេងៗ ចៅក្រមអាចមើលទៅលើគោលការណ៍និងសិទ្ធិស្តីពីបទបញ្ញត្តិប្រតិសកម្ម ដើម្បីស្វែងរកការការពារនិងផ្អែកលើការសម្រេចចិត្តទៅលើការពិចារណាទាំងនេះ ។

នៅឆ្នាំ២០០៣ តុលាការកំពូលរបស់សហរដ្ឋអាមេរិកបានធ្វើការបោះឆ្នោតដោយមានសំឡេង៥ទល់នឹង៤ ដែលថា ការពន្យារពេលប្រតិសកម្មនៃដែនអាជ្ញាយុកាលដែលកំពុងខិតទៅរកការបញ្ចប់ការរំលោភទៅលើឃ្លាស្តីពីគោលការណ៍ប្រតិសកម្មរបស់រដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក ។ ការវិភាគនេះបានធ្វើឲ្យរឿងក្តីមួយនៅឆ្នាំ១៩៧៨ របស់ ខលឌឺ ប៊ុល ដែលគោលការណ៍យុត្តិធម៌របស់ឆេស (Justice Chase) កំណត់នូវការហាមប្រាមលើគោលការណ៍ប្រតិសកម្មនៅក្នុងយុត្តិសាស្ត្រអាមេរិក ។ តុលាការរបស់ ខលឌឺ បានរកឃើញថា ការហាមប្រាមប្រតិសកម្មធ្វើឲ្យមានកំហុសខុសឆ្គងបួនប្រភេទទៅលើច្បាប់ ៖

*ទី១) រាល់ច្បាប់ដែលសកម្មភាពចប់មុនពេលអនុម័តច្បាប់ ហើយទង្វើនេះមិនស្មោះត្រង់នៅពេលដែលអំពើនោះចប់ក្លាយជាឧក្រិដ្ឋកម្មនិងមានការដាក់ទណ្ឌកម្មទៅលើអំពើបែបនោះ ។ ទី២) រាល់ច្បាប់ដែលដាក់ទម្ងន់ទោសលើបទឧក្រិដ្ឋឬធ្វើឲ្យបទឧក្រិដ្ឋនោះកាន់តែធំឡើងនៅពេលបទឧក្រិដ្ឋនោះបានប្រព្រឹត្តរួច ។ ទី៣) រាល់ច្បាប់ដែលកែប្រែទោសទណ្ឌ ហើយដាក់បន្ទាប់ទៅលើទោសទណ្ឌកាន់តែធ្ងន់ធ្ងរឡើងជាជាងច្បាប់ដែលចងភ្ជាប់ទៅនឹងបទឧក្រិដ្ឋនៅពេលបទឧក្រិដ្ឋត្រូវបានប្រព្រឹត្តឡើង ។ រាល់ច្បាប់ដែលកែប្រែវិធានភស្តុតាងផ្លូវច្បាប់ ហើយទទួលបានសក្ខីភាពតិចឬផ្សេងគ្នាជាងច្បាប់ដែលតម្រូវ នៅពេលមានការប្រព្រឹត្តបទល្មើសដើម្បីដាក់ទោសទណ្ឌដល់ឧក្រិដ្ឋជន ។*

តុលាការកំពូលថែងថា ច្បាប់ពន្យារពេលដែនកំណត់អាជ្ញា-យុកាលចូលក្នុងការស្វែងរកយុត្តិធម៌ដំណាក់កាលទី២របស់គោលការណ៍យុត្តិធម៌របស់ឆេស (Justice Chase) ប្រភេទទី៤ ដែលនាំទៅដល់ «ច្បាប់ដាក់ទោសទណ្ឌធ្ងន់ធ្ងរទៅលើបទឧក្រិដ្ឋ ឬធ្វើឲ្យបទឧក្រិដ្ឋនោះកាន់តែធ្ងន់ធ្ងរជាងពេលដែលបទឧក្រិដ្ឋនោះប្រព្រឹត្តឡើង» ។ តុលាការនេះឲ្យយោបល់បន្ថែមទៀតថា ការរកឃើញផ្សេងៗទៀតអាចត្រឹមត្រូវតាមគោលការណ៍ព្រមានឲ្យមានភាពត្រឹមត្រូវនិងយុត្តិធម៌ ។ តាមរយៈការសរសេរសម្តីចៅក្រម លីនហែន តុលាការកំពូលនេះថែងថា «ការពន្យារអាជ្ញាយុកាលបន្ទាប់ពីរដ្ឋបានអះអាងថា «មនុស្សម្នាក់ដែលគាត់មានសុវត្ថិភាពរួចទៅហើយ...ហាក់ដូចជាមិនយុត្តិធម៌ឬមិនស្មោះត្រង់ចំពោះយើងស្ទើរតែទាំងអស់» ។

ទោះបីយ៉ាងណាក៏ដោយ តុលាការយុត្តិធម៌៤ក្នុងចំណោម៩មិនយល់ស្របគ្នាទេ ។ តុលាការយុត្តិធម៌របស់ កេណឌី ឲ្យហេតុផលថា «ច្បាប់ដែលមិនកែប្រែនិយមន័យឧក្រិដ្ឋកម្ម ប៉ុន្តែកែប្រែការចោទប្រកាន់មិនអាចធ្វើឲ្យបទឧក្រិដ្ឋ «កាន់តែធ្ងន់ធ្ងរជាងបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើយ» ។ ឃ្លាស្តីពីគោលការណ៍ប្រតិសកម្មដែលក្រុមអ្នកជំទាស់បានរកឃើញគួរតែអានឲ្យបានលម្អិត ដោយផ្តោតទៅលើអត្ថបទសាមញ្ញនៃសាលដីការបស់ ខលឌឺ ហើយមិនចាំបាច់ពង្រីកប្រភេទទាំង៤នោះទេ» ។ តុលាការកេណឌី ពិនិត្យបន្ថែមទៅលើការអត្ថាធិប្បាយដ៏មានឥទ្ធិពលរបស់ចូល ព្រិនធីស ប៊ីសប ដែល «សន្និដ្ឋានថា ច្បាប់ដែលកែប្រែការចោទប្រកាន់ឡើងវិញដែលបានហួសកំណត់ទៅហើយមិនស្ថិតនៅក្នុងនិយមន័យច្បាប់ណាមួយដែលមានការទទួលស្គាល់ទៅលើច្បាប់ប្រតិសកម្មឡើយ» ។ ប៊ីសប ឲ្យហេតុផលថា ៖

*ទោសទណ្ឌដែលអាចធ្វើទៅបានដោយហាមឃាត់ការការពារមិនឲ្យពេលវេលាកន្លងហួសទៅ គឺជាអ្វីដែលច្បាប់ផ្តល់ឲ្យនៅពេលដែល «អង្គហេតុ» កើតឡើងរួចហើយ ។ គ្មានការកែប្រែភាសា ហើយគ្មានការផ្តល់ឲ្យនូវអត្ថន័យបង្កប់ដែលអាចដោះស្រាយលើសេចក្តីសន្និដ្ឋានផ្ទុយគ្នាដោយផ្អែកលើហេតុផលធម្មតា... ។ ការដំណើរការលក្ខន្តិកៈចាស់បានដកចេញពីតុលាការនូវសិទ្ធិដើម្បីបន្តការប្រឆាំងទៅលើជនល្មើស ដោយទុកច្បាប់ដែលបានរំលោភគ្មានការកែតម្រូវពីមុនឡើយ ប៉ុន្តែវាមិនអាចលុបបំបាត់ការពិតដែលច្បាប់បានហាមឃាត់អំពើនោះនៅពេលដែលវាត្រូវបានធ្វើឡើងឬដកចេញពីគំនិតរបស់អ្នកធ្វើអំពើនូវការទទួលស្គាល់ទោសកំហុសដើមរបស់ខ្លួន ។*

ដូច្នេះ តុលាការកំពូលរបស់សហរដ្ឋអាមេរិកបានសន្និដ្ឋាន

ដោយមតិភាគច្រើនរបស់ក្រសួងយុត្តិធម៌ថា ការពន្យារដែនអាជ្ញាយុកាលដែលផុតកំណត់គឺជាការរំលោភលើគោលការណ៍ប្រតិសកម្ម ។

ការអនុវត្តការសម្រេចចិត្តនៅក្នុងបរិបទអន្តរជាតិ វាជាការចាំបាច់ក្នុងការកត់សម្គាល់ថា ប្រភេទ៤យ៉ាងនេះត្រូវបានគ្រោងរៀបចំឡើងនៅក្នុងសេចក្តីសម្រេចចិត្តរបស់ ខលឌី នៅឆ្នាំ ១៩៧៨ មានលក្ខណៈទូលំទូលាយជាងឯកសារអន្តរជាតិដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា ។ ចំណុចនេះអាចជួយពង្រឹងទស្សនៈប្រឆាំងក្នុងអត្ថបទរបស់តុលាការកេណឺឌីនៅក្នុងកម្រិតអន្តរជាតិ ។ ដូចដែលបានកត់សម្គាល់ខាងលើ បញ្ញត្តិប្រតិសកម្មរបស់សន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយធ្វើការហាមឃាត់លើកដំបូង ដោយរកឃើញថា «ជនណាម្នាក់មានទោសឧក្រិដ្ឋទៅលើដំណើររឿងឬមិនមានទោសអាចបង្កើតបានជាបទឧក្រិដ្ឋធ្ងន់ធ្ងរនៅក្រោមច្បាប់ជាតិនិងអន្តរជាតិ នៅពេលដែលបទឧក្រិដ្ឋនោះប្រព្រឹត្តឡើង» ហើយភាពស្មើគ្នានៃប្រភេទទីមួយនិងប្រភេទទីពីររបស់ ខលឌី ដាក់ទម្ងន់ទោសទណ្ឌធ្ងន់ធ្ងរ «ជាងប្រភេទមួយទៀត (ប្រភេទទីបី) ដែលយកមកអនុវត្តនៅពេលដែលបទឧក្រិដ្ឋធ្ងន់ធ្ងរប្រព្រឹត្តឡើង សូមមើលសន្ធិសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយត្រង់មាត្រា១៥» ។ ទោះបីយ៉ាងណាក៏ដោយ ដីកាសម្រេចរបស់ស្តុគណី (សាលដីកាដែលចេញដោយតុលាការជាន់ខ្ពស់របស់សហរដ្ឋអាមេរិក) រកឃើញថា ការពន្យារច្បាប់អាជ្ញាយុកាលត្រូវបានហាមប្រាមដោយប្រភេទទី២ ដែលមិនទាន់ដាក់បញ្ចូលនៅក្នុងច្បាប់អន្តរជាតិឲ្យបានច្បាស់លាស់នៅឡើយទេ ។

ប្រទេសផ្សេងៗជាច្រើនទៀត ក៏បានថែងអំពីសុពលភាពនៃការពន្យារដែនច្បាប់អាជ្ញាយុកាលបន្ទាប់ពីដែនច្បាប់អាជ្ញាយុកាលនោះផុតកំណត់ ។ ច្បាប់រដ្ឋធម្មនុញ្ញរបស់អាល្លឺម៉ង់ត្រូវបានរកឃើញថា បានហាមប្រាមមិនឲ្យមានការពន្យារពេលទៅលើដែនអាជ្ញាយុកាលបែបនេះទេ ។ ប្រទេសហុងគ្រីក៏បដិសេធផងដែរទៅលើការពន្យារពេលដែនច្បាប់អាជ្ញាយុកាលដែលផុតកំណត់ស្តីពីដំណើររឿងក្នុងការហាមប្រាមលើគោលការណ៍ប្រតិសកម្ម ។ តុលាការធម្មនុញ្ញរបស់ហុងគ្រីបានផ្តោតទៅលើគោលការណ៍នៃភាពប្រាកដប្រជាសន្តិសុខ ការកំណត់បង្ហាញនិងស្ថានភាពស្ងប់ស្ងាត់ឈានទៅរកការធ្វើសេចក្តីសម្រេចចិត្ត ។ ទោះបីមិនមានការថែងច្បាស់លាស់ទៅលើសំណួរនេះក៏ដោយ ក៏ប្រទេសជាច្រើនដូចជាប្រទេសហូឡង់កាលពីពេលថ្មីៗនេះលុបបំបាត់ដែនច្បាប់អាជ្ញា-យុកាលចំពោះអំពើមនុស្សឃាតនិងបទឧក្រិដ្ឋធ្ងន់ធ្ងរដទៃទៀតដែរ ប៉ុន្តែអនុវត្តតែទៅលើច្បាប់ដែលបង្កើតថ្មី ដើម្បីកុំឲ្យជួបប្រទះបញ្ហាគោលការណ៍ប្រតិសកម្មនេះ ។

ទីបំផុត មិនថាចៅក្រមរបស់អង្គជំនុំជម្រះវិសាមញ្ញប្រកាន់យកវិធីសាស្រ្តក្នុងអត្ថបទឬវិធីសាស្រ្តជាគោលការណ៍ចំពោះសំណួរនេះនឹងកំណត់បទបញ្ញត្តិដែនច្បាប់អាជ្ញាយុកាលក្នុងការបង្កើតច្បាប់មានសុពលភាពបែបនោះនៅក្រោមច្បាប់អន្តរជាតិ ។

### ៤) នីតិរដ្ឋដែលយល់ថាអាចដឹងមុនបាន ផ្ទុយពីនីតិរដ្ឋដែលយល់ថាជាយុត្តិធម៌ត្រឹមត្រូវ

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកំណត់ថា កាលៈទេសៈកំណត់ជាក់លាក់ចំពោះបទពិសោធន៍របស់កម្ពុជាផ្តល់ឲ្យនូវហេតុផលបន្ថែមដើម្បីទុកការការពារនិងដំណើរការបច្ចេកទេសច្បាប់មួយឡែក ដោយមិនគិតពីការចោទប្រកាន់ទៅលើបទឧក្រិដ្ឋរបស់ប្រទេសដែលរារាំងដោយពេលវេលា ។

ភាពសមហេតុផលនៅក្រោយដែនអាជ្ញាយុកាលមានគោលបំណងពីរ ។ ទីមួយ ដែនអាជ្ញាយុកាលត្រូវបានដាក់ឲ្យអនុវត្តដើម្បីត្រួតពិនិត្យអំណាចក្រមច្បាប់របស់ប្រទេស និងដើម្បីផ្តល់ឲ្យបុគ្គលជាច្រើននូវស្ថានភាពស្ងប់ស្ងាត់ ធានាបាននូវការដឹងឮដែលថារដ្ឋមួយលែងនៅពីក្រោយដែនអាជ្ញាយុកាលនិងលែងបង្ហាញភ័ស្តុតាងដោះបន្ទុក ។ ការណ៍នេះឆ្លុះបញ្ចាំងអត្ថប្រយោជន៍ដែលថយចុះរបស់រដ្ឋនៅក្នុងការចោទប្រកាន់បុគ្គល (ប្រព្រឹត្តបទល្មើស) ។ ទីពីរ ដែនអាជ្ញាយុកាលចាំបាច់ចំពោះការរំពឹងទុកនូវភ័ស្តុតាងជាក់ស្តែង ។ ជាពិសេស នៅពេលដែលធ្វើការប្រមូលភ័ស្តុតាងដើម្បីបញ្ជាក់រឿងក្តីមួយមានការលំបាកណាស់ ហើយជាបន្តបន្ទាប់ ចំណុចនេះលើកឡើងនូវបញ្ហាស្តីពីភាពគួរឲ្យទុកចិត្តបានជាច្រើន ។ ការចងចាំថយចុះ ហើយជារឿយៗឯកសារត្រូវបានបាត់បង់ ។

ទោះជាយ៉ាងក៏ដោយ ក៏ដែនអាជ្ញាយុកាលមិនមែនជាគោលការណ៍សិទ្ធិមនុស្សជាមូលដ្ឋាននោះទេ ហើយមិនត្រូវបានទទួលស្គាល់ជាសកលឡើយ ។ ដែនអាជ្ញាយុកាលត្រូវបានរិះគន់ថា

ជាទុបសគ្គចំពោះយុត្តិធម៌ត្រឹមត្រូវ ។ លើសពីនេះទៅទៀត ប្រទេសជាច្រើនលុបបំបាត់ដែនអាជ្ញាយុកាលចំពោះអំពើមនុស្សឃាតនិងបទឧក្រិដ្ឋធ្ងន់ធ្ងរផ្សេងទៀត ហើយដែនអាជ្ញាយុកាលមិនមានចំពោះបទឧក្រិដ្ឋថ្នាក់អន្តរជាតិឡើយ ។ ជាក់ស្តែង ក្នុងអំឡុងពេលជជែកវែកញែកនៅឆ្នាំ១៩៦៤នៅក្នុងប្រទេសបារាំងទាក់ទិននឹងដែនអាជ្ញាយុកាលនិងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលប្រព្រឹត្តឡើងដោយរបបណាហ្ស៊ី អ្នកយកការណ៍ កូសតឹះ ដូរ៉េ បាននិយាយសម្តីខាងក្រោមនេះទៅកាន់សភាជាតិបារាំងដោយឆ្លុះបញ្ចាំងនូវភាពសមហេតុផលដែលនៅពីក្រោយទ្រឹស្តីបញ្ញាក់ពីពេលវេលាកំណត់ថា ៈ

ភាពសមហេតុផលចំពោះទ្រឹស្តីស្តីពីអាជ្ញាយុកាល ការបាត់ភស្តុតាងនិងគោលការណ៍ «អត់ឱនទោសនិងបំភ្លេច» មិនអនុវត្តដោយងាយៗឡើយ ។ ទីមួយ ភស្តុតាងមានច្រើនសម្បូរបែបក្នុងរយៈពេល២០ឆ្នាំមុនតាំងពីសម័យរំដោះ គឺនៅពេលដែលបណ្តូសារត្រូវបានរកឃើញ ហើយសាក្សីចេញមកផ្តល់សេចក្តីបំភ្លឺ ។ ទីពីរ បទឧក្រិដ្ឋដែលបានប្រព្រឹត្តមានភាពធ្ងន់ធ្ងរដែលមិនអាចអត់ឱននិងបំភ្លេចបាន ។

តាមទស្សនៈនេះ ភាពត្រឹមត្រូវនិងភាពពិតជាក់ស្តែងនៃអំពើឃោរឃៅទ្រង់ទ្រាយធំជាងការការពារដោយដែនអាជ្ញា-យុកាល ។

សេចក្តីថ្លែងការណ៍ដោយអ្នកយកការណ៍ជនជាតិបារាំងនៅឆ្នាំ១៩៦៤ ជាប់ពាក់ព័ន្ធយ៉ាងខ្លាំងរហូតដល់ពេលបច្ចុប្បន្នខណៈពេលដែលប្រទេសកម្ពុជាស្វែងរកការចោទប្រកាន់លើបទឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហម ។ នៅចុងបញ្ចប់នេះ ចៅក្រមរបស់អង្គជំនុំជម្រះវិសាមញ្ញនឹងធ្វើឲ្យមានតុល្យភាពម្រូវការដើម្បីធានថាយុត្តិធម៌តាមនីតិវិធីស្របតាមតម្រូវការ ដើម្បីស្វែងរកយុត្តិធម៌ត្រឹមត្រូវដល់ប្រជាជនកម្ពុជា ។ គោលការណ៍សីលធម៌ជាមូលដ្ឋានដែលសំខាន់សម្រាប់ប្រទេសកម្ពុជានឹងអាចឆ្លុះបញ្ចាំងដោយសាលាក្តី គឺគោលការណ៍សីលធម៌ដើម្បីជជែកវែកញែកនិងកំណត់ ។

## ៥) សេចក្តីសន្និដ្ឋាន

អង្គជំនុំជម្រះវិសាមញ្ញអាចអនុវត្តយុត្តាធិការទៅលើបទឧក្រិដ្ឋថ្នាក់ជាតិដែលបានរំលោភក្រមច្បាប់ព្រហ្មទណ្ឌឆ្នាំ១៩៥៦ ប្រសិនបើ ១) ដែនអាជ្ញាយុកាលត្រូវបានពន្យារពេលដោយសារការបំផ្លិចបំផ្លាញប្រព័ន្ធយុត្តិធម៌កម្ពុជាទាំងស្រុងដោយខ្មែរក្រហម ២) តុលាការរកឃើញថា ដែនអាជ្ញាយុកាលមានដំណើរការ ប៉ុន្តែទទួលយកការវិភាគអត្ថបទស្តីពីការហាមប្រាមក្នុងការបង្កើតច្បាប់ប្រតិសកម្ម ដោយរកឃើញថា ការពន្យារពេលដែនអាជ្ញាយុកាលមិនរំលោភលើសិទ្ធិដែលទទួលស្គាល់ជាអន្តរជាតិ និង៣) តុលាការសម្រេចថា តាមគោលការណ៍សីលធម៌ដាក់បន្ទុំដោយមិនគិតពីដែនអាជ្ញាយុកាល តម្រូវឲ្យខ្មែរក្រហមទទួលការកាត់ទោសតាមយុត្តិធម៌ត្រឹមត្រូវ ។ **អាន ហេនឌុល**

# ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង ៧-៧ៈ៣០ព្រឹក និងម៉ោង៧ៈ០០-៧ៈ៣០ល្ងាច ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។ **ស៊ិន សុធីតា**

# កម្មវិធីអប់រំអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរនឹងធ្វើការចាក់ផ្សាយកម្មវិធីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» ដែលនិពន្ធដោយលោក ឌី ខាំបូលី ឡើងវិញនៅលើគេហទំព័ររបស់ខ្លួននៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨ ខាងមុខនេះ ។

អ្នកទាំងអស់គ្នាអាចស្តាប់ ថតចម្លង និងអានសាច់រឿងដែលមាននៅក្នុងសៀវភៅនេះតាមរយៈគេហទំព័រវិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរ ។

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

# បណ្តឹងយុត្តាធិការរបស់ អៀង សារី មុនពេលអង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ទាក់ទងទៅនឹងការលើកលែងទោសនិងការអត់ឱនទោស

សំណួរទាក់ទងទៅនឹងការកាត់ទោសកំបាំងមុខរបស់ អៀង សារី នៅក្នុងឆ្នាំ១៩៧៩ ដោយតុលាការប្រជាជនបដិវត្តន៍កម្ពុជា ហើយនឹងការលើកលែងទោស ព្រមទាំងការអនុគ្រោះទោស ត្រូវបានលើកមកពិភាក្សានៅក្នុងសវនាការផ្ទាល់មាត់ឆ្នាំ១៩៩៦ មុនពេលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៨ ។ អង្គបុរេជំនុំជម្រះបានស្តាប់ការស្នើសុំទាក់ទងទៅនឹងទ្វេហានិភ័យនិងការអាក់ខាន ក៏ដូចជាប្រសិទ្ធភាពយុត្តាធិការនៃការលើកលែងទោសនិងការអនុគ្រោះទោស ។ ការអនុគ្រោះទោសប្រហារជីវិត អៀង សារី ដោយតុលាការប្រជាជនបដិវត្តន៍កម្ពុជា ។ ការលើកលែងទោសនេះបានការពារ អៀង សារី ពីការកាត់ទោសឲ្យនៅក្រោមច្បាប់របស់ខ្មែរក្រហមនៅឆ្នាំ ១៩៩៤ និងត្រូវបានអនុញ្ញាតឲ្យជួយសម្រួលលើភាពខ្វះចន្លោះរបស់ អៀង សារី ពីខ្មែរក្រហម ។

## ១) ទ្វេហានិភ័យ និងសំបុត្របដិសេធនូវសិទ្ធិកាត់ទោសដោយយុត្តិធម៌

អង្គបុរេជំនុំជម្រះបានសុំឲ្យមានការស្នើសុំផ្ទាល់មាត់ទាក់ទងទៅនឹងប្រសិទ្ធភាព ប្រសិនបើគេទទួលស្គាល់ការកាត់ទោសកំបាំងមុខរបស់ អៀង សារី នៅឆ្នាំ១៩៧៩ គឺជាបញ្ហាទ្វេហានិភ័យ ។ ដោយគិតទៅលើកំហុសរឿងក្តីដែលពាក់ពន្ធ័មានចំនួនធំធេងនៅក្នុងដំណើរការនៃការកាត់ក្តីឆ្នាំ១៩៧៩ អង្គជំនុំជម្រះចង់ដឹងថាតើ អៀង សារី អាចបោះបង់ចោលសិទ្ធិកាត់ទោសដោយយុត្តិធម៌ដោយទទួលយកសេចក្តីសម្រេចនេះ ហើយតើសំបុត្របដិសេធមានឥទ្ធិពលអ្វីខ្លះទៅលើសមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីស៊ើបសួរទៅលើអំពើឧក្រិដ្ឋរបស់ អៀង សារី ដែលគាត់ត្រូវបានកាត់ទោសកាលពីមុន ។

ការកាត់ទោសនេះបានលើកឡើងថា សិទ្ធិការពារក្តីដោយយុត្តិធម៌ទាំងចុងចោទ និងធម្មានុរូបនៃនីតិវិធីច្បាប់ ដូច្នេះគាត់មិនអាចបដិសេធចោលបានទេ ។ ជាងនេះទៅទៀត ការគោរពសិទ្ធិដែលពាក់ពន្ធ័នឹងអន្តរជាតិ ទាមទារឲ្យសាលក្រមដែលសម្រេចដោយតុលាការប្រជាជនបដិវត្តន៍គិតថាជាមោឃៈ ខណៈដែលវាមានគុណវិបត្តិ ព្រោះតែភាពលម្អៀង ខ្វះការបង្ហាញដែលមានសារសំខាន់លើចំណាប់អារម្មណ៍ និងខ្វះការចូលរួម របស់ អៀង សារី នៅក្នុងដំណើរការក្តីនិងខ្វះការត្រួតពិនិត្យលើបណ្តឹងឧទ្ធរណ៍ ក៏ដូចជាកំហុសរឿងក្តីសំខាន់ៗដទៃទៀត ។ ដើមបណ្តឹងរដ្ឋប្បវេណីបានចូលរួមការកាត់ក្តី ហើយបានរំឭកទៅតុលាការថា អៀង សារី គ្រាន់តែស្រុះស្រួលទៅតាមតុលាការប្រជាជនបដិវត្តន៍ប៉ុណ្ណោះ បន្ទាប់ពីមានការអត់ឱនទោសរួច ។ ដោយយោងទៅលើមេធាវីសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ពេលវេលាដ៏សមរម្យនៃការទទួលយករបស់ អៀង សារី លើសាលក្រមដែលដាក់ភាពស្មោះត្រង់របស់គាត់ទៅក្នុងការមន្ទិលសង្ស័យដ៏ធ្ងន់ធ្ងរ ។

ចុងចោទជជែកអំពីសិទ្ធិនៃការកាត់ក្តីដោយយុត្តិធម៌គឺមានភាពស្រដៀងគ្នាទៅនឹងការការពារដទៃទៀតដែរ សិទ្ធិដែលគេបោះបង់ចោលដូចជាសិទ្ធិបង្ហាញខ្លួននៅពេលកាត់ទោសនិងសិទ្ធិមានស្នាក្តី ។ ដើម្បីគាំទ្រស្ថានភាពនេះ ការការពារបានកត់សម្គាល់ឃើញថាតុលាការប្រជាជនលីបង់ដែលកំពុងចាប់កំណើតបានផ្តល់ឲ្យចុងចោទមានសិទ្ធិជ្រើសរើសក្នុងការទទួលយកឬបដិសេធនូវលទ្ធផលនៃការកាត់ទោសកំបាំងមុខ ។ ជាងនេះទៅទៀតដោយយោងតាមការការពារសាលាក្តីជាច្រើនដូចជាសហរដ្ឋអាមេរិកអនុញ្ញាតឲ្យចុងចោទសារភាពទោសនិងទទួលយកការដាក់ទណ្ឌកម្មដោយមិនចាំបាច់សារភាពកំហុសនោះទេ ដូច្នេះសិទ្ធិរបស់ពួកគេ

ក្នុងការការពារក្តីត្រូវបានបោះបង់ចោល ។

ចុងចោទជាច្រើនបានប្រឆាំងដោយលើកហេតុផលថា ការកាត់ទោសខ្មែរក្រហម គឺគ្របដណ្តប់នូវរាល់សកម្មភាពរបស់ អៀង សារី ទាំងអស់នៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ដូចដែលបានពិភាក្សាខាងក្រោមតាមការពិនិត្យមើលទៅលើសកម្មភាពឧក្រិដ្ឋកម្មបាននិយាយបំផ្លើសទាំងស្រុងដែលប្រព្រឹត្តឡើងដោយ អៀង សារី គឺត្រូវបានរាប់បញ្ចូលទាំងការកាត់ទោសរបបប្រល័យពូជសាសន៍ ។ ដូច្នេះ ការកាត់ក្តីសម្រាប់សកម្មភាពទាំងនេះដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងរំលោភលើគោលការណ៍ទ្វេហានិភ័យ ។

## ២) ការខកខាន និងច្បាប់នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលកំពុងអនុវត្ត

តុលាការនេះក៏បានស្តាប់ការជជែកគ្នាពីភាគីទាំងសងខាងនូវសំណួរដែលទាក់ទងទៅនឹងបញ្ហាខកខាន ទ្រឹស្តីមួយដែលថាយើងមិនអាចប្តឹងលើបញ្ហាតែមួយដែលបានសម្រេចរួចទៅហើយទេ ។ ភាគីទាំងសងខាងបានពិភាក្សាគ្នាថាតើនិយមន័យច្បាប់កម្ពុជាឬក៏ច្បាប់អន្តរជាតិស្តីពីបញ្ហាខកខានគួរតែដាក់បញ្ចូលនៅក្នុងករណីនេះដែរទេ ។ ច្បាប់នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតម្រូវឲ្យតុលាការដាក់បញ្ចូលនូវនីតិវិធីទាំងនោះខាងផ្នែកកម្ពុជាប៉ុន្តែវាក៏តម្រូវឲ្យតុលាការនេះរង់ចាំដោយបង្រួមកម្រិតអន្តរជាតិដែរ ។ ក្រមព្រហ្មទណ្ឌកម្ពុជាបានរារាំងទៅលើការកាត់ទោសសកម្មភាពឧក្រិដ្ឋកម្មដដែលនេះ ។ ផុយពីអនុសញ្ញាអន្តរជាតិទាក់ទងទៅនឹងជនស៊ីវិល និងសិទ្ធអ្នកនយោបាយមិនអាចកាត់ទោសលើបទឧក្រិដ្ឋតែមួយបានទេ ។

ការកាត់ទោសដែលចូលរួមដោយដើមបណ្តឹងរដ្ឋប្បវេណីបានចោទថាច្បាប់អន្តរជាតិនិង «ឧក្រិដ្ឋកម្មដដែល» នេះ ត្រូវតែត្រួតពិនិត្យដោយសារហេតុផល២យ៉ាង ។ ហេតុផលទី១ចរិតនៃឧក្រិដ្ឋកម្មអន្តរជាតិមិនមែនត្រឹមតែត្រូវបានគេអនុញ្ញាតទេ ថែមទាំងត្រូវបានគេបញ្ឈរទៀតផង ការកាត់ទោសជាច្រើនសម្រាប់សកម្មភាពដដែលនេះគឺដើម្បីឆ្លុះបញ្ចាំងឲ្យបានត្រឹមត្រូវនិងផ្តន្ទាទោសបទល្មើសជាក់ស្តែង ។ ហេតុផលទី២មិនមានភាពត្រឹមត្រូវក្នុងការដោះលែងឲ្យរួចខ្លួន គន្លឹះដែលធ្វើឲ្យមានបញ្ហាខកខានធ្វើឲ្យវាខុសពីទ្វេហានិភ័យ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានចោទថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនបានកំណត់ពីបញ្ហាខកខានឲ្យបានច្បាស់លាស់និងមិនពេញលេញទេ ។ ដូច្នេះខណៈដែលបន្ទាប់ដោយច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងច្បាប់អន្តរជាតិត្រូវបានប្រើដើម្បីបំពេញចន្លោះប្រហោងនៅក្នុងផ្នែកច្បាប់ ។

ចុងចោទបានចោទថា មិនមានភាពខុសប្លែកគ្នាទេរវាងការដោះលែងឲ្យរួចខ្លួននិងការផ្តន្ទាទោសសម្រាប់គោលបំណងនៃការខកខាននិងដើម្បីបង្កើតការការពារមួយដែលអាចបំផ្លាញនូវគោលបំណងជាមូលដ្ឋាននៃលទ្ធិដែលធ្វើឲ្យភាគីជាច្រើនជឿជាក់លើការសម្រេចចិត្តផ្នែកច្បាប់ចុងក្រោយទេ ។ ជាងនេះទៅទៀតចុងចោទបានចោទថាមិនមានន័យពិតប្រាកដនៅក្នុងច្បាប់នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទេ ដូច្នេះហើយការសាកល្បងដាក់បញ្ចូលនូវសកម្មភាពដដែលសម្រាប់បញ្ហាខកខានត្រូវតែអនុវត្ត ។ បន្ថែមពីលើនេះទៀត ការការពារបានចោទថា ភាសាដែលងាយយល់នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបង្ហាញថាទ្រឹស្តីនៃបញ្ហាខកខានគួរតែយកមកអនុវត្តចំពោះសកម្មភាពទាំងអស់របស់ អៀង សារី ដែលត្រូវបានកាត់ទោសថាជាឧក្រិដ្ឋជនដោយតុលាការប្រជាជនបដិវត្តន៍កម្ពុជា ។

## ៣) ប្រសិទ្ធភាពនៃយុត្តាធិការក្នុងការលើកលែងទោស និងការអត់ឱនទោស

### ក) ការស្នើសុំឲ្យមានការការពារ

ចុងចោទបានចោទថា ការលើកលែងទោសនិងការអនុគ្រោះទោសទាំងពីរនេះគឺផ្នែកច្បាប់នឹងអាចយកជាផ្លូវការបាន ។ ដើម្បីជាជំនួយដល់តួនាទីនេះ ចុងចោទបានកត់សម្គាល់ថាមិនមានភាគីណាមួយឡើយ លើកលែងតែដើមបណ្តឹងរដ្ឋប្បវេណីដែលបានចូលរួម ហើយជជែកពីនីត្យានុកូលភាពរបស់ពួកគេដែលស្ថិតនៅក្រោមច្បាប់កម្ពុជា ។ ជាងនេះទៅទៀត ចុងចោទបានស្នើឲ្យមានការលើកលែងទោសនិងអនុគ្រោះទោសដល់ អៀង សារី ដែលផ្តល់សារសំខាន់សម្រាប់ការបញ្ចប់សង្គ្រាមស៊ីវិលជាង៣០ឆ្នាំនៅក្នុងប្រទេសកម្ពុជា និងនាំឆ្ពោះទៅរកសន្តិភាព និងភាពរុងរឿង ។

ចុងចោទបានស្នើឲ្យមានការលើកលែងទោសនិងអនុគ្រោះ

នូវរាល់សកម្មភាពទាំងអស់របស់ អៀង សារី ដែលជាសមាជិកខ្មែរក្រហមម្នាក់រហូតដល់ឆ្នាំ១៩៩៦ ដោយរួមទាំងរយៈពេលពីឆ្នាំ១៩៧៥-៧៩ ដែលរួមជាមួយយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ចុងចោទបានចោទថា ការលើកលែងទោសគឺក្នុងគោលបំណងផ្តល់នូវអភ័យឯកសិទ្ធិទាំងស្រុងសម្រាប់បទឧក្រិដ្ឋទាំងអស់របស់ អៀង សារី ដែលគាត់បានប្រព្រឹត្តមុនឆ្នាំ១៩៩៦ ។ ធ្វើដូច្នេះដើម្បីប្រឆាំងទៅនឹងការបកស្រាយផ្នែកច្បាប់របស់សហចៅក្រមស៊ើបអង្កេតក្នុងការបញ្ជាឲ្យមានការឃុំឃាំងជាបណ្តោះអាសន្ន ដែលបានរកឃើញនៅក្នុងច្បាប់ឆ្នាំ១៩៩៤ ដើម្បីកំណត់ជុំវិញបទឧក្រិដ្ឋក្នុងស្រុកដែលបានរៀបរាប់តែប៉ុណ្ណោះ ។

ក្នុងការជួយដល់ការបកស្រាយនៃការកំណត់ការលើកលែងទោសចុងចោទបានចោទថា ច្បាប់ឆ្នាំ១៩៩៤ ត្រូវតែលើកមកនិយាយពី «កម្មវត្ថុនិងគោលបំណង» ដែលយោងតាមចុងចោទច្បាប់នេះបានបញ្ឆោតឲ្យខ្មែរក្រហមទម្លាក់អាវុធចុះនិងចូលមករួមរស់ក្នុងសង្គមកម្ពុជាវិញ ។ ការបញ្ឆោតនេះមានន័យថាច្បាប់១៩៩៤នេះត្រូវតែប្រតិសកម្ម ។ ជាងនេះទៅទៀត លំនាំនៃច្បាប់ឆ្នាំ១៩៩៤ ជាពិសេសការផ្តន្ទាទោសមេដឹកនាំខ្មែរក្រហមលើបទឧក្រិដ្ឋដែលរួមទាំងសកម្មភាពសម្លាប់និងកំណត់ថាបទឧក្រិដ្ឋទាំងនេះគឺជាចរិតលក្ខណៈនៃខ្មែរក្រហមចាប់តាំងពីខែមេសា ឆ្នាំ១៩៧៥ បង្ហាញថា ច្បាប់នេះមានគោលបំណងដាក់បញ្ចូលបទឧក្រិដ្ឋទាំងអស់ដែលប្រព្រឹត្តដោយ អៀង សារី ។

### ១) ការស្នើសុំឲ្យមានការកាត់ទោសនិងដើមបណ្តឹងរដ្ឋប្បវេណី

ការកាត់ទោសបានលើកឡើងថា ការលើកលែងទោសនិងការអនុគ្រោះទោសមិនបានអត់ឱនឲ្យ អៀង សារី ពីយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទេ ។ ជាងនេះទៅទៀត វាជាបញ្ហា២ដាច់ដោយឡែកដែលតម្រូវឲ្យទាក់ទងជាមួយបុគ្គលម្នាក់ៗមុនតុលាការនិងមុនពេលដាក់បញ្ចូលវាទៅក្នុងប្រធានបទតែមួយ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានចូលរួមស្នើឲ្យមានការកាត់ក្តី ។ បន្ថែមពីលើនេះទៀត ដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថាការអនុគ្រោះទោសត្រូវទុកជាមោឃៈដោយព្រះមហាក្សត្របានប្រើអំណាចមិនត្រឹមត្រូវ ពីព្រោះរដ្ឋធម្មនុញ្ញបានអនុញ្ញាតឲ្យព្រះមហាក្សត្រមានអំណាចត្រឹមតែប្រទាន «ការអនុគ្រោះទោស» ប៉ុណ្ណោះ ដែលជាវិធីមួយខុសប្លែកជាងការអត់ឱនទោស ។

### ១) ការលើកលែងទោសទាក់ទងនឹងច្បាប់ឆ្នាំ១៩៩៤និងអនុគ្រោះទោសដែលចាត់ទុកជាមោឃៈក្នុងការកាត់ទោសនៅតុលាការខ្មែរក្រហម

ការកាត់ទោសបានលើកឡើងថា ការលើកលែងទោសគឺក្នុងគោលបំណងផ្តល់អភ័យឯកសិទ្ធិដល់ អៀង សារី ពីការកាត់ទោសសម្រាប់ការប្រព្រឹត្តបទល្មើសជាក់លាក់នៃច្បាប់ឆ្នាំ១៩៩៤ ដែលដាក់ខ្មែរក្រហមឲ្យនៅក្រៅច្បាប់ ។ ដូចដែលការអត់ឱនទោសត្រូវបានគេយកមកអនុវត្តក្នុងការកាត់ទោសប្រហារជីវិតប្រឆាំងទៅនឹងការកាត់ទោសកំបាំងមុខរបស់គាត់ដោយតុលាការប្រជាជនបដិវត្តន៍កម្ពុជា ។ ហេតុផលតែមួយប៉ុណ្ណោះដែលការអត់ឱនទោសត្រូវបានអនុញ្ញាតគឺដើម្បីជួយសម្រួលដល់ភាពខ្វះខាតរបស់ អៀង សារី ខណៈពេលកំពុងផ្តល់លទ្ធភាពដល់ការកាត់ក្តីនៅពេលអនាគត ។ ដូច្នេះប្រសិទ្ធភាពនៃការអត់ឱនទោសគឺដើម្បីបោះបង់ចោលការកាត់ទោសដែលបានធ្វើឡើងដោយតុលាការប្រជាជនបដិវត្តន៍កម្ពុជាដោយគេមិនបដិសេធចោលនូវរាល់សកម្មភាពឧក្រិដ្ឋកម្មរបស់គាត់ទេ ។

### ២) ភាពខុសគ្នា (១) អាជ្ញាធរក្នុងស្រុកមិនអាចបដិសេធចោលនូវបទឧក្រិដ្ឋកម្មអន្តរជាតិឬ (២) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនបានយកចិត្តទុកដាក់លើការលើកលែងទោសនិងអនុគ្រោះទោស

ការកាត់ទោសបានលើកឡើងនូវភាពខុសគ្នាថា រដ្ឋាភិបាលថ្នាក់ជាតិមិនមានអំណាចក្នុងការលើកលែងទោសឬផ្តល់ការលើកលែងទោសសម្រាប់ឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរនោះទេ ។ ភាពអសមត្ថភាពនេះគឺច្បាស់លាស់ណាស់សម្រាប់បទឧក្រិដ្ឋដែលប្រឆាំងនឹងបទដ្ឋានមួយដែលគេបានហាមឃាត់ដូចជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ជាដើម ។ ដើម្បីគាំទ្រទៅនឹងការលើកឡើងនេះ ការកាត់ទោសបានទាញយកហេតុផលឲ្យតុលាការយុត្តិធម៌អន្តរជាតិស្វែងរកយុត្តិធម៌ ក្នុងករណីបាសេឡូណា ត្រេកសេន ដែលប្រឆាំងនឹងអំពើប្រល័យពូជសាសន៍ដែលគេហៅថាជាបទដ្ឋានមួយដែលគេបានហាមឃាត់ ។ ដោយអនុលោមតាមបទដ្ឋាននេះវាជាកាតព្វកិច្ច

*របស់រដ្ឋទាំងអស់ក្នុងការការពារនិងដាក់ទោសទៅលើបទឧក្រិដ្ឋ ។ ដូច្នេះការលើកលែងទោសនិងអនុគ្រោះទោសដល់ អៀង សារី សម្រាប់ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍គឺត្រូវចាត់ទុកជាមោឃៈពីព្រោះវារំលោភទៅនឹងច្បាប់អន្តរជាតិដែលជាកាតព្វកិច្ចនៃរាជរដ្ឋាភិបាលកម្ពុជា ។*

*ដើម្បីជាជំនួយបន្ថែមទៀត ការកាត់ទោសបានលើកហេតុផលលើករណី ហ៊ឺរ៉ាន់ស៊ីចា ដែលគាត់យល់ឃើញថា ច្បាប់ជាតិគ្មានឥទ្ធិពលទៅលើការអនុវត្តនៃបទដ្ឋានដែលគេបានហាមឃាត់ទេ ។ វាក៏បានកត់សម្គាល់ឲ្យឃើញថាការកាត់ទោសឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតជនជាតិយូហ្គោស្លាវីដែលគេចាត់ទុកថាជាឥទ្ធិពលនៃការអនុគ្រោះទោសបើសិនជាចុងចោទបានជួយដល់ផ្នែកសំខាន់មួយនៃការកាត់ទោស ។ ចំណែកឯ អៀង សារី វិញគាត់មិនដែលទទួលរងនូវការដាក់ទោសអ្វីទាំងអស់ ។ ចុងបញ្ចប់ ការការពារបានបង្ហាញឲ្យឃើញថាច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ ជាពិសេសតុលាការពិសេសប្រទេសសេរ៉ាឡេអូន និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិប្រទេសរ៉ាន់ដា បានកំណត់យ៉ាងត្រឹមត្រូវពីការអនុគ្រោះទោសពីព្រោះ វាមិនទាក់ទងទៅនឹងការសម្រេចចិត្តនៃសិទ្ធិរបស់ចុងចោទ ។*

*ដូចជាការលើកឡើងជាលើកទី២ ការកាត់ទោសបានអះអាងថាអង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជាគឺជាផ្នែកមួយនៃប្រពន្ធ័យុត្តិធម៌អន្តរជាតិដែលដាច់ចេញពីប្រពន្ធ័យុត្តិធម៌នៅកម្ពុជា ដូច្នេះវាមិនអាស្រ័យទៅលើកិត្តិយស ការលើកលែងទោសឬអនុគ្រោះទោស ដោយគេមិនបានគិតពីសុពលភាពទាំងនៅក្នុងប្រទេសឬក៏អន្តរជាតិនោះទេ ។ ការកាត់ទោសបានលើកហេតុផលលើករណីនៃអ្នកកាត់ទោសឈ្មោះ កាឡូន ដែលតុលាការពិសេសគឺជាតុលាការចម្រុះផ្នែកជាតិឬក៏អន្តរជាតិដូចជាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលបោះបង់ចោលការលើកលែងទោសថ្នាក់ជាតិមួយសម្រាប់ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដោយមិនបានគិតថ្លឹងថ្លែងអ្វីទាំងអស់ ។*

## ***គ) ការជំទាស់របស់មេធាវី***

*មេធាវីបានយល់ស្របថា ការហាមឃាត់ប្រឆាំងនឹងអំពើប្រល័យពូជសាសន៍គឺជាបទដ្ឋានមួយដែលគេបានហាមឃាត់ ប៉ុន្តែគេបានអះអាងថាបទដ្ឋាននេះមិនមានសុពលភាពជាស្វ័យប្រវត្តិទៅលើការលើកលែងទោសឬអនុគ្រោះទោសដែលបានផ្តល់សម្រាប់ការកាត់ទោសប្រល័យពូជសាសន៍នោះទេ ។ ដោយយោងទៅលើមេធាវី មិនមែនមានការលើកលែងទោសថ្នាក់ជាតិទាំងអស់ឬក៏ការអនុគ្រោះទោសត្រូវបានអនុញ្ញាតសម្រាប់ឧក្រិដ្ឋកម្មអន្តរជាតិនោះទេ ។ ឧទាហរណ៍ ដូចជាប្រទេសអៀរឡង់ និងប្រទេសសេរ៉ាឡេអូន បានអនុញ្ញាតឲ្យមានការលើកលែងទោសសម្រាប់ឧក្រិដ្ឋកម្មអន្តរជាតិដើម្បីជួយសម្រួលដល់ដំណើរការសន្តិភាព ។ នៅក្នុងប្រទេសសេរ៉ាឡេអូន អង្គការសហប្រជាជាតិថែមទាំងយល់ព្រមឲ្យសម្រុះសម្រួលគ្នានិងចុះហត្ថលេខាលើកិច្ចព្រមព្រៀង ឡូម៉េទៀតផង ទោះបីជាប្រទេសនោះមិនព្រមទទួលយកការចរចាឲ្យលើកលែងទោសក៏ដោយ ។ មេធាវីបានស្គាល់យ៉ាងច្បាស់នូវផ្នែកមួយនៅកាលូន របស់តុលាការពិសេស ដោយសម្គាល់ឃើញកិច្ចព្រមព្រៀងលើកលែងទោសរវាងរាជរដ្ឋាភិបាលនិងចុងចោទគឺត្រូវចាត់ទុកជាមោឃៈ បន្ទាប់ពីចុងចោទបានបដិសេធកិច្ចព្រមព្រៀងនិងនៅតែបន្តការប្រយុទ្ធ ។ សម្រាប់ហេតុផលទាំងនេះ ការការពារបានអះអាងថា ការលើកលែងទោស និងអនុគ្រោះទោសអាចធ្វើឲ្យអាក់ខានការកាត់ទោសនៅក្នុងកាលៈទេសៈខ្លះ ។ នៅចុងបញ្ចប់ មេធាវីមិនបានយល់ស្របថាអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាគឺជាផ្នែកមួយនៃប្រពន្ធ័យុត្តិធម៌អន្តរជាតិនោះទេ ហើយបានលើកឡើងថាវាគឺជាតុលាការក្នុងស្រុកមួយដែលមើលទៅលើច្បាប់អន្តរជាតិក្នុងករណីមានភាពខ្វះចន្លោះនៅក្នុងច្បាប់តែប៉ុណ្ណោះ ។*

## ***សេចក្តីសន្និដ្ឋាន***

*អង្គបុរេជំនុំជម្រះបានពន្យារពេលបន្ទាប់ពីស្តាប់ការស្នើសុំដោយផ្ទាល់មាត់នៃភាគីទាំងសងខាង ។ ការជជែកវែកញែកដោយភាគីទាំងសងខាងទាក់ទងទៅនឹងការបង្ហាញខ្លួនរបស់ អៀង សារី ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នដែលចេញដោយសហចៅក្រមស៊ើបអង្កេតត្រូវបានកំណត់ពេលទៅថ្ងៃក្រោយ ។ ការសម្រេចចិត្តដោយអង្គបុរេជំនុំជម្រះទាក់ទងទៅនឹងបញ្ហាយុត្តិធម៌លើករណីរបស់ អៀង សារី គឺត្រូវបានគិតទុកថានឹងធ្វើឡើងនៅក្នុងពាក់កណ្តាលខែវិច្ឆិកា ។* **រ៉េនដល ជីហ្វាល់កូ**

# សត្រូវខាងក្នុងនិងខាងក្រៅ៖
# បទពិសោធន៍ឆ្លងកាត់សម័យខ្មែរក្រហមរបស់ជនជាតិវៀតណាម

***(តចប់)***

មុ៉ន នៅចាំថា ប្រជាជនខ្មែរនិងវៀតណាមនៅក្នុងភូមិរបស់គាត់មានទំនាក់ទំនងល្អជាមួយគ្នា ។ មុ៉ន រៀបរាប់ថា កាលពីដំបូងខ្មែរក្រហមប្រព្រឹត្តល្អនឹង ហួរ ដូចប្រជាជនខ្មែរដទៃទៀតដែរ ។ ហួរ ធ្វើការងារដូចប្រជាជនខ្មែរឯទៀត ហើយពេលចប់ការងារគាត់អាចត្រឡប់ទៅផ្ទះ ហើយរស់នៅជាមួយគ្រួសារបានដូចប្រជាជនខ្មែរដែរ ។ ប៉ុន្តែអ្វីៗបានប្រែប្រួលនៅអំឡុងឆ្នាំ១៩៧៦ យោងទៅតាមសម្ដីរបស់ ប៉ាច ខ្មែរក្រហមចាប់ផ្ដើមឡោមព័ទ្ធប្រជាជនវៀតណាម ហើយផ្លាស់ពួកគេចេញពីភូមិ ។ ខ្មែរក្រហមព្យាយាមប្រាប់គ្រួសារជនជាតិវៀតណាមថា ជនជាតិវៀតណាមទាំងអស់នោះគ្រាន់តែត្រូវបញ្ជូនទៅ «រៀនសូត្រ» ឬក៏ «ទៅកាប់ព្រៃ» បណ្ដោះអាសន្នប៉ុណ្ណោះ រួចនឹងត្រឡប់មកផ្ទះជាមិនខាន ។ ប៉ាច បានពន្យល់ទៀតថា ការយកលេសថាបញ្ជូនទៅ «រៀនសូត្រ» បានធ្វើឲ្យខ្មែរក្រហមមានភាពងាយស្រួលក្នុងការប្រមូលយកនូវគោលដៅរបស់ខ្លួន ពីព្រោះដំបូងឡើយប្រជាជនសុទ្ធតែជឿទៅលើសំបកក្រៅទាំងអស់នេះ ដូច្នេះទើបមិនបង្កទំនាស់វាយតប់គ្នា ។ គោលការណ៍ប្រទូសរ៉ាយរបស់ខ្មែរក្រហមចំពោះជនជាតិវៀតណាមកើតឡើងដោយសារតែជំនឿរបស់ខ្មែរក្រហមដែលថាជនជាតិវៀតណាមជាអ្នកឈ្លានពានទឹកដីកម្ពុជា ។ នៅពេលនោះមានការប្រជុំមួយដែលកម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហមបានប្រាប់ទៅកម្មាភិបាលថ្នាក់ក្រោមរបស់ខ្លួនថា ទាហានវៀតណាមបានដេញបាញ់ខ្មែរក្រហមនៅតាមព្រំដែន ហើយភាពកំណាចឃោរឃៅរបស់ជនជាតិវៀតណាមបែបនេះហើយទើបធ្វើឲ្យកំហឹងនិងរោគឆ្កួតរបស់ខ្មែរក្រហមរើឡើងវិញ ។

មុ៉ន ជឿជាក់ថា ខ្មែរក្រហមបានកំណត់យកគ្រួសារគាត់ធ្វើជាគោលដៅ ដោយសារតែប្រវត្តិជាជនជាតិវៀតណាមរបស់គ្រួសារគាត់ ។ មុ៉ន នៅចាំថា តាអោក ដែលជាមេភូមិបានប្រាប់កម្មាភិបាលថ្នាក់ខ្ពស់ខ្មែរក្រហមថា គ្រួសាររបស់ សេង គឺមានឈាមជ័រជាជនជាតិវៀតណាម ។ បងស្រីច្បងរបស់ មុ៉ន ឈ្មោះ យុន មុត ដែលធ្លាប់រស់នៅក្នុងភូមិស្វាយអន្ទរកាលពីជំនាន់នោះ បានប្រាប់ថាខ្មែរក្រហមបានចាប់ខ្លួនគ្រួសាររបស់ សេង ជាបន្តបន្ទាប់តែម្ដង ដំបូងគឺចាប់ប្អូនប្រុស និងប្អូនស្រីរបស់ ហួរ ឈ្មោះ កេ និង ទៀង ហើយរំលងបានប៉ុន្មានថ្ងៃ មានខ្មែរក្រហម២នាក់ឈ្មោះ លឹម និង ឈឿន បានមកប្រាប់ ហួរ និងម្ដាយរបស់គាត់ថាអ្នកទាំងពីរនាក់ត្រូវទៅចូលរួមអង្គប្រជុំមួយនៅក្នុងវត្តជាខ្លាង ហើយបន្ទាប់មកក៏ដឹកនារីទាំងពីរនាក់នេះទៅបាត់ ។ ហួរ កាលនោះអាយុ២៥ឆ្នាំ គាត់បានបន្សល់ទុកកូនឲ្យគ្រួសារខាងប្ដីរបស់គាត់ជួយមើលថែរក្សា ។ បន្ទាប់ពី ហួរ និងម្ដាយរបស់គាត់ចាកចេញទៅ អ្នកភូមិមិនដែលបានឃើញអ្នកទាំងពីរត្រឡប់មកផ្ទះវិញឡើយ ។

នៅថ្ងៃបន្ទាប់ មុ៉ន ត្រឡប់មកផ្ទះវិញដែលតាមព័ត៌មានបានឮថាប្រពន្ធនិងគ្រួសារខាងប្រពន្ធបានបាត់ខ្លួន ។ ខ្មែរក្រហម២នាក់ទៀតគឺ តាអោក និងកងឈ្លបឈ្មោះ ហ៊ិន បានមកដល់ផ្ទះរបស់គាត់ដើម្បីប្រមូលយកកូនទាំង៣នាក់របស់គាត់ទៅទៀត ។ គ្រួសាររបស់គាត់នាំគ្នាអង្វរករខ្មែរក្រហមទាំងនោះឲ្យទុកកូនមួយឲ្យគាត់ តែខ្មែរក្រហមបដិសេធដោយនិយាយថា កូនទាំងនេះត្រូវទៅតាមម្ដាយរបស់វា ។ គ្រួសារគាត់មិនដែលឃើញក្មេងៗទាំងនោះត្រឡប់មកវិញទេ បន្ទាប់ពីខ្មែរក្រហមដឹកទៅ ។ មុ៉ន ជឿថា ខ្មែរក្រហមនៅស្វាយអន្ទរប្រហែលជាធ្វើតាមគោលការណ៍ពិសេសដែលថា ចាប់និងសម្លាប់តែកូនណាដែលមានម្ដាយជាជនជាតិវៀតណាមប៉ុណ្ណោះ ហើយទុកជីវិតឲ្យកូនណាដែលមានឪពុកជាជនជាតិវៀតណាម ។ មុ៉ន ក៏បន្តទៀតថា គាត់មិនយល់ទាល់តែសោះថាហេតុអ្វីបានជាខ្មែរក្រហមអនុវត្តតាមគោលការណ៍បែបនេះ ដោយឡែកគោលការណ៍នេះក៏ត្រូវបានយកទៅអនុវត្តនៅឯ

ភូមិដទៃទៀតដែរ ។ ប៉ុក សុខុម ដែលជាអតីតប្រធានកងយុវជននៅស្វាយអន្ទរបានបញ្ជាក់ថា ខ្មែរក្រហមពិតជាមានគោលការណ៍សម្លាប់ម្តាយជនជាតិវៀតណាមនិងកូនរបស់គេមែន ហើយខ្មែរក្រហមបានកំណត់គោលដៅនេះព្រោះខ្មែរក្រហមយល់ឃើញថាជនជាតិវៀតណាមជាសត្រូវរបស់គេ ។

ម៉ុន នៅចាំថា បន្ទាប់ពីការបាត់ខ្លួនរបស់ក្រុមគ្រួសារគាត់មក មានខ្មែរក្រហមពីរបីនាក់បានមកផ្ទះរបស់គាត់ហើយព្យាយាមប្រមែប្រមូលយករបស់របររបស់ប្រពន្ធគាត់ទៀតផង ។ ម៉ុន និងគ្រួសាររបស់គាត់បានប្រឆាំងនឹងខ្មែរក្រហមដោយប្រាប់ថាប្រពន្ធគាត់មិនមានបន្សល់ទុករបស់អ្វីទេ ។ បន្ទាប់មក បានយក ម៉ុន ទៅដាក់នៅឃុំដាខ្លាងដែលមានមេឃុំឈ្មោះ ចែម ព្យាយាមអប់រំ ម៉ុន ថាកុំឲ្យស្រណោះប្រពន្ធនិងកូនវៀតណាមទៀតអី ។ ម៉ុន បន្តរស់នៅក្នុងឃុំហ្នឹងរហូតដល់របបខ្មែរក្រហមដួលរលំ ។ ប្អូនស្រីរបស់ ម៉ុន ទាំងបីនាក់មាន មុត, សាមិត និង មីន ក៏ត្រូវបានចាប់យកទៅអប់រំណែនាំថាកុំឲ្យមានវិប្បដិសារីចំពោះការបាត់ខ្លួនកូនរបស់ ហួរ នោះអី ។

ម៉ុន មិនបានដឹងព្ទពីអ្វីដែលកើតឡើងចំពោះប្រពន្ធ និងកូនរបស់គាត់ទៀតទេ ។ រូបភាពកូនទាំងបីរបស់គាត់ដែលត្រូវឈ្លបអូសដាក់លើរទេះសេះបានក្លាយទៅជាការចងចាំចុងក្រោយបំផុតដែលគាត់មានអំពីគ្រួសារគាត់ ។ ឃុន សាមិត ដែលជាប្អូនស្រីរបស់ ឃុន ម៉ុន បាននិយាយប្រាប់ពីការព្រួយបារម្ភរបស់អ្នកភូមិក្នុងពេលដែលគេស្តាប់ឮសំឡេងរទេះសេះនៅពេលយប់ពីព្រោះគេដឹងថាសំឡេងនេះជាសញ្ញាដែលខ្មែរក្រហមមកចាប់យកនរណាម្នាក់ ហើយដឹកទៅកាន់វាលពិឃាត ។ បន្ទាប់មក ម៉ុន លេចឮពាក្យចចាមអារ៉ាមថា ប្រពន្ធនិងកូនរបស់គាត់ត្រូវដឹកយកទៅភូមិចម្ការគួយ ។ នៅពេលដែលគាត់ទៅដល់ អ្នកភូមិទាំងនោះបាននិយាយថា ប្រជាជនវៀតណាមដែលនាំមកដាក់នៅភូមិនេះសុទ្ធតែត្រូវបានសម្លាប់ទាំងអស់ ។ ម៉ុន និយាយថា បន្ទាប់ពីពេលដែលរដ្ឋាភិបាលទៅស៊ើបអង្កេតដល់ទីកន្លែងជុំវិញចម្ការគួយ គេក៏សន្និតថាទីនេះជាកន្លែងសម្លាប់មួយដែរ ព្រោះគេបានរកឃើញសាកសពនិងឆ្អឹងមនុស្សនៅទីនោះ ។

លន និយាយពីអាកប្បកិរិយាសម្ងាត់របស់ខ្មែរក្រហម ជាពិសេសគឺអាថ៌កំបាំងរបស់គេក្នុងការកំណត់គោលដៅសម្លាប់មនុស្ស ។ យោងទៅតាមការរៀបរាប់របស់ លន កម្មាភិបាលខ្មែរក្រហមថ្នាក់ខ្ពស់ដូចជា មេស្រុកជាអ្នករៀបចំបញ្ជីសម្លាប់មនុស្ស ដោយធ្វើការប្រមូលព័ត៌មានពីមេឃុំនិងមេភូមិស្តីពីជីវប្រវត្តិរបស់អ្នកភូមិ ។ បញ្ជីនោះត្រូវបានរក្សាទុកយ៉ាងសម្ងាត់ជាទីបំផុត សូម្បីតែអ្នកបររទេះដែលដឹកមនុស្សទៅដាក់នៅវាលពិឃាតក៏មិនអាចដឹងជាមុននូវឈ្មោះជនរងគ្រោះទាំងអស់នោះដែរ ។

## ម៉េង ស៊ីម

រឿងរ៉ាវរបស់ ម៉េង ស៊ីម ដែលមានឈាមជ័រជាជនជាតិវៀតណាមបានចាប់ផ្តើមនៅភូមិអង្គរយស ឃុំព្រែកអន្ទះ ស្រុកកំពង់លាវ ខេត្តព្រៃវែង ។ នៅក្នុងភូមិអង្គរយសនេះ ស៊ីម រស់នៅជាមួយស្វាមីនិងកូន៦នាក់ដែលមានអាយុចាប់ពី២ខែរហូតដល់



១៦ឆ្នាំ ។ ស៊ីម មានឈាមជ័រជាជនជាតិវៀតណាមដោយសារតែគាត់តាមជីលួតជីលារបស់គាត់ដែលជាកូនវៀតណាមកាត់ចិន ។ ដូច្នេះ ប្រវត្តិជាតិសាសន៍របស់គាត់សឹងតែកាត់មកជាជនជាតិខ្មែរទៅហើយ ។ ស៊ីម និងបងប្អូនគាត់សុទ្ធតែបាត់ខ្លួនទាំងអស់នៅសម័យខ្មែរក្រហម ទោះបីជាគាត់សឹងតែពុំមានឈាមជ័រជាវៀតណាមក៏ដោយ ។ ចំណែកគ្រួសាររបស់គាត់នៅសម័យ ខ្មែរក្រហម គឺនៅរស់តែ២នាក់ប៉ុណ្ណោះ មួយគឺកូនប្រុសឈ្មោះ ពៅ អោង និងប្តីរបស់គាត់ឈ្មោះ អៀ ពៅ ។ យោងតាម អោង ដែលកាលពីជំនាន់នោះមានអាយុប្រហែល១២ឆ្នាំ បាននិយាយរៀបរាប់ថា កាលដែលខ្មែរក្រហមកំណត់គោលដៅយកគ្រួសាររបស់គាត់គឺដោយមានហេតុការណ៍ពីរយ៉ាង ។ ទីមួយកើតឡើង នៅខែមករា ឆ្នាំ១៩៧៦ អោង នៅចាំថាកាលនោះមានពាក្យចចាមអារ៉ាមមួយនិយាយថា ខ្មែរក្រហមកំពុងតែប្រមូលយកជនជាតិវៀតណាមដែលរស់នៅក្នុងទឹកដីកម្ពុជាទាំងអស់ ហើយបញ្ជូនអ្នកទាំងនេះទៅវៀតណាមវិញ ។ ខ្មែរក្រហមបានប្រាប់គ្រួសាររបស់ អោង ថា ខ្មែរក្រហមដើររកមើលថានរណាជាជនជាតិវៀតណាម នឹងអាលបញ្ជូនត្រឡប់ទៅប្រទេសដើមវិញ ។ បន្ទាប់មកគ្រួសាររបស់ អោង ត្រូវផ្លាស់ពីអង្គរយសទៅនៅឯខេត្តកណ្តាលវិញ ។ ការបញ្ជូននេះគឺមានគ្រួសារវៀតណាមចំនួនប្រាំគ្រួសារទៀតរួមដំណើរជាមួយ ដែលក្នុងមួយគ្រួសារៗមានមនុស្សប្រហែល៦ទៅ៧នាក់ ។



បន្ទាប់ពីធ្វើដំណើរបាន២ថ្ងៃ អ្នកទាំងអស់នេះបានទៅដល់ខេត្តកណ្តាលហើយរស់នៅក្នុងភូមិមួយ ។ នៅទីនោះ អោង នៅចាំថាបានឃើញមនុស្សជិត១០០នាក់រង់ចាំទៅមុខផ្ទះប្រធានភូមិដែលក្នុងនោះមានមនុស្សគ្រប់វ័យទាំងអស់ ហើយភាគច្រើនសុទ្ធតែមិនមែនជាជនជាតិវៀតណាមមួយរយភាគរយនោះទេ គ្រាន់តែជាប់សាច់ឈាមវៀតណាមបន្តិចបន្តួចប៉ុណ្ណោះ ។ ខ្មែរក្រហមចោទប្រកាន់អ្នកទាំងអស់នោះថាជាជនជាតិវៀតណាម ហើយបង្ខំពួកគេឲ្យទៅព្រំដែន ។ បន្ទាប់ពីទន្ទឹងរង់ចាំអស់រយៈពេល៣ថ្ងៃ អ្នកតំណាងនិងកងទ័ពវៀតណាមបានមកធ្វើការត្រួតពិនិត្យ ។ កងទ័ពវៀតណាមបានឲ្យប្រជាជនទាំងនោះនិយាយភាសាវៀតណាមដើម្បីធ្វើការសាកល្បងមើលថាតើពួកគេពិតជាជនជាតិវៀតណាមមែនឬអត់ ។ នៅពេលដែលប្រជាជនមិនអាចនិយាយភាសាវៀតណាមបាន ទាហានទាំងនោះបាននិយាយថាប្រជាជនទាំងនេះមិនមែនជាជនជាតិវៀតណាមទេ ហើយបានបដិសេធមិនទទួលយកអ្នកទាំងនេះចូលក្នុងប្រទេសវៀតណាមឡើយ ។ ដោយសារតែមិនមានកន្លែងឲ្យប្រជាជនរស់នៅ ខ្មែរក្រហមបានបញ្ជូនប្រជាជនទាំងនោះទៅភូមិកំណើតរបស់គេវិញ ។

នៅពេលដែល អោង និងគ្រួសាររបស់គាត់ត្រឡប់មកភូមិអង្គរយសវិញ ខ្មែរក្រហមដែលប្រចាំការនៅទីនោះបានចាត់ទុកគ្រួសារគាត់ជា «ប្រជាជនថ្មី» ជាពាក្យមួយដែលខ្មែរក្រហមប្រើសម្រាប់សម្គាល់ថាជាប្រជាជនដែលមានទ្រព្យសម្បត្តិនិងមានអត្តសញ្ញាណពូជសាសន៍ខុសគ្នា ។ គណៈឃុំបានចាត់តាំងបងប្រុសរបស់ អោង ពីរនាក់ទៅធ្វើការនៅក្នុងកងចល័ត ហើយបញ្ជូនគ្រួសាររបស់ អោង ដែលនៅសេសសល់ទៅនៅភូមិថ្មីដែលនៅឆ្ងាយពីភូមិអង្គរយសប្រហែល៣គីឡូម៉ែត្រ ។ នៅទីនោះ អោង

ត្រូវប្រមូលខុសនៅក្នុងភូមិនិងចាប់កណ្តុរដែលស៊ីបន្លែនៅក្នុងភូមិ ។ អោង និងគ្រួសាររបស់គាត់រស់នៅនិងធ្វើការនៅភូមិថ្មីរហូតទាល់តែខ្មែរក្រហមកំណត់គោលដៅយកគ្រួសាររបស់គាត់ជាថ្មីម្តងទៀត ។

អោង នៅចាំថាហេតុការណ៍ទីពីរដែលបានកើតឡើងគឺនៅដើមឆ្នាំ១៩៧៧ ពេលដែលខ្មែរក្រហមប្រមូលយកជីដូន-ជីតាឈ្មោះ ហោ និង តាប ទៅរៀនសូត្រ ។ អោង និយាយថាខ្មែរក្រហមប្រើប្រាស់ពាក្យថា «រៀនសូត្រ» ធ្វើជាផ្លាក់ដើម្បីជម្លៀសប្រជាជនស្លូតៗចេញពីផ្ទះរបស់ពួកគាត់ហើយយកទៅសម្លាប់ ។ ពៅ នៅចាំថា ខ្មែរក្រហមបានចាប់ខ្លួនបងប្អូនរបស់ ស៊ីម និងគ្រួសាររបស់ពួកគេយកទៅរៀនសូត្រ រួមមានបងស្រីរបស់គាត់ ម៉េង មួយ និងគ្រួសារ បងប្រុស ម៉េង សៀនី និងគ្រួសារ និងបងប្អូនស្រីរបស់គាត់បីនាក់ទៀត ម៉េង គេក និង គ្រួសារ, ម៉េង សៀ និងគ្រួសារ និង ម៉េង ពៅ នៅលីវ ។ ១៥ថ្ងៃក្រោយមកនៅក្នុងខែកុម្ភៈឆ្នាំ១៩៧៧ ខ្មែរក្រហមបានមកយក ស៊ីម និងគ្រួសាររបស់គាត់ទៀត ។ យោងទៅតាមការរៀបរាប់របស់ ពៅ យោធាខ្មែរក្រហមបីនាក់ឈ្មោះ យស, សែន និងមួន បានមកដល់ផ្ទះរបស់គាត់ហើយបញ្ជាឲ្យគ្រួសារគាត់ទៅរៀនសូត្រ ។ ជាដំបូងនៅប្រហែលម៉ោង៣រសៀល ខ្មែរក្រហមបានចាប់ ស៊ីម និងកូនប្រុសច្បងពីរនាក់របស់គាត់យកទៅ ។ បីម៉ោងក្រោយមក ខ្មែរក្រហមក៏ត្រឡប់មកចាប់ អោង និងប្អូនប្រុសស្រីទៅទៀត ។ អោង ជឿថាខ្មែរក្រហមធ្វើតាមគោលការណ៍ពិសេសដូចដែលបានរៀបរាប់នៅភូមិពោធិ៍ចិនដាំនិងស្វាយអន្ទរអ៊ីចឹង ។ នៅពេលនោះ ពៅ មានជំងឺម្យ៉ាងដែលធ្វើឲ្យពោះរបស់គាត់ឡើងប៉ោង ដូច្នេះខ្មែរក្រហមក៏ទុកគាត់ឲ្យនៅព្យាបាលជំងឺសិន ។ ទោះបីជាពេលនោះ ពៅ បានសុំខ្មែរក្រហមឲ្យគាត់បានទៅជាមួយគ្រួសាររបស់គាត់ក៏ដោយ ក៏ខ្មែរក្រហមនិយាយថាគាត់មិនចាំបាច់ត្រូវទៅទេ ។ នៅយប់នោះ ខ្មែរក្រហមបានមកដឹកប្រពន្ធកូនរបស់ ពៅ និងគ្រួសារវៀតណាមដទៃទៀតចេញពីភូមិទាំងអស់ ។

ខ្មែរក្រហមបាននាំ ស៊ីម និងកូនរបស់គាត់ទៅរស់នៅវត្តព្រែកតាំដែលខ្មែរក្រហមប្រើប្រាស់ជាកន្លែងឃុំខ្លួន ។ នៅព្រែកតាំ ស៊ីម ព្រួយបារម្ភយ៉ាងខ្លាំងចំពោះប្តីដែលឈឺនៅផ្ទះម្នាក់ឯង ដូច្នេះក៏ហៅ អោង និងបងប្រុសរបស់គាត់ឲ្យត្រឡប់ទៅភូមិថ្មីវិញ ។ តែបងប្រុសរបស់ អោង និយាយថា គាត់សុខចិត្តទៅរស់នៅជាមួយម្តាយប្រសើរជាង ហើយស្នើឲ្យ អោង ត្រឡប់ទៅភូមិមើលថែឪពុកវិញ ។ បន្ទាប់ពីយប់នោះ ខ្មែរក្រហមបានហៅ អោង និងបងប្អូនរបស់គាត់ញ៉ាំបាយល្ងាចជុំគ្នា ដែលពេលនោះ អោង បានលួចចេញតាមរបងក្រោយវត្តហើយដើរឆ្ពោះទៅផ្ទះ ។ ប៉ុន្មានម៉ោងក្រោយពេល អោង គេចខ្លួន គាត់បានឮសំឡេងកណ្តែលូ ហើយក៏ដឹងថាខ្មែរក្រហមកំពុងតែតាមចាប់គាត់ ។ បន្ទាប់ពីធ្វើដំណើរបាន១០គីឡូម៉ែត្រ អោង ក៏បានមកដល់ផ្ទះរបស់ឪពុកគាត់ ។ ប៉ុន្តែ អោង មិនហ៊ានចូលក្នុងភូមិទេ ដោយសារខ្លាចខ្មែរក្រហមរកគាត់ឃើញ ។ អោង សម្ងំពួននៅក្នុងព្រៃអស់បីថ្ងៃបីយប់ ។ នៅពេលនោះ គាត់នឹកឃើញការស្រេកឃ្លានរបស់គាត់ដែលពេលថ្ងៃមិនបានញ៉ាំអីសោះ ហើយយប់ឡើងត្រូវលបទៅជីកដំឡូងយកមកញ៉ាំថែមទៀត ។ ដោយទ្រាំទ្រការស្រេកឃ្លានពុំបាន អោង ក៏លួចចូលក្នុងផ្ទះរបស់ឪពុក ។ បន្ទាប់មក ពៅ ក៏បញ្ជូន អោង ទៅនៅផ្ទះមីងរបស់គាត់នៅឃុំកំពង់ឫស្សី ។ ១០ថ្ងៃក្រោយមក ពៅ ក៏ធូរស្បើយពីជំងឺ ហើយបានហៅ អោង ឲ្យត្រឡប់មកវិញ ។ អ្នកទាំងពីរនាក់បានភៀសខ្លួនមកនៅភូមិពោធិ៍ចិនដាំដែលជាកន្លែងបងប្រុសរបស់ ពៅ ស្នាក់នៅ ។

នៅពេលដែលឪពុកកូនទាំងពីរនាក់មកដល់ភូមិពោធិ៍ចិនដាំនៅពាក់កណ្តាលឆ្នាំ១៩៧៧ បងប្រុសរបស់ ពៅ បានប្រាប់មេដឹកនាំក្នុងភូមិរបស់គាត់ថា ពៅ និងអោង ជាជនភៀសខ្លួនមកពីខេត្តផ្សេងព្រោះមិនហ៊ាននិយាយពីជីវប្រវត្តិដែលគាត់មានប្រពន្ធវៀតណាមឡើយ ។ ពេលនោះ ពៅ នៅចាំថាក្នុងពេលដែលគាត់បានមកដល់ភូមិនេះ ខ្មែរក្រហមកំពុងតែអនុវត្តនូវគម្រោងការសម្លាប់រង្គាលប្រជាជនភូមិភាគបូព៌ា ។ ព្រោះតែអ៊ីចឹងហើយទើបធ្វើឲ្យ ពៅ និង អោង អាចរស់នៅក្នុងភូមិនេះបានដោយមិនមានការកត់សម្គាល់ពីខ្មែរក្រហម ។ ទោះបីជាបន្ទាប់មក គណៈឃុំចោទថាគាត់ជា «ប្រជាជនថ្មី» ហើយគំរាមថានឹងបញ្ជូនគាត់ទៅវិញក៏ដោយ ក៏បងប្រុសរបស់ ពៅ ជាអ្នកធានាជួស ដូច្នេះហើយទើបគណៈឃុំលែងធ្វើការចោទប្រកាន់ ។ ពៅ និង អោង បន្តរស់នៅក្នុងភូមិពោធិ៍ចិនដាំរហូតដល់របបខ្មែរក្រហមដួលរលំនៅឆ្នាំ

១៩៧៩ ។ ទោះបីជា ពៅ និង អោង មិនមែនជាសាក្សីដែលបានឃើញហេតុការណ៍កើតឡើងចំពោះ ស៊ឹម និងសមាជិកដទៃផ្សេងទៀតក៏ដោយ ក៏ អោង អះអាងថាគាត់បានឮខ្មែរក្រហមនិយាយពីការបញ្ជូនម្ដាយនិងបងប្អូនរបស់គាត់ទៅកន្លែងមួយផ្សេងទៀតជាកន្លែងដែលពួកគាត់នឹងត្រូវសម្លាប់ ។ ការបាត់ខ្លួនរបស់គ្រួសារគាត់នៅតែស្ថិតជាអាថ៌កំបាំងដដែលដូចគ្នានឹងការបាត់ខ្លួនរបស់គ្រួសារប្រជាជនដទៃទៀតនៅសម័យខ្មែរក្រហមដូច្នោះដែរ ។

## ផេង សាម៉ៃ

ផេង សាម៉ៃ ព្យាយាមលាក់ខ្លួនពួនអាត្មាដើម្បីគេចឲ្យផុតពីរបបខ្មែរក្រហម ។ ម្ដាយរបស់ សាម៉ៃ ជាជនជាតិវៀតណាម ១០០ភាគរយ ទោះបីជាគាត់កើតនិងធំធាត់នៅក្នុងប្រទេសកម្ពុជាក៏ដោយ ។ ចំណែកឪពុករបស់ សាម៉ៃ វិញជាជនជាតិខ្មែរសុទ្ធ ។ ឪពុកម្ដាយរបស់ម្ដាយគាត់បានបែកផ្លូវគ្នាតាំងពីគាត់នៅក្មេងម្ល៉េះទើបគាត់មិនដែលស្គាល់ឪពុករបស់គាត់ទេ ។ គាត់រស់នៅធំធាត់ជាមួយបងស្រីពីរនាក់និងមានម្ដាយរបស់គាត់រស់នៅជាមួយ ។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងសម័យខ្មែរក្រហម គ្រួសាររបស់ សាម៉ៃ ត្រូវបែកបាក់គ្នា ។ នៅឆ្នាំ១៩៧០ របបលន់ នល់ បានបង្ខំឲ្យបងស្រីធំរបស់ សាម៉ៃ និងស្វាមីរបស់គាត់ភៀសខ្លួនទៅរស់នៅប្រទេសវៀតណាមរហូតដល់ពេលបច្ចុប្បន្ន ហើយក៏បន្តរស់នៅទីនោះតទៀត ។ ចំណែកបងម្នាក់ទៀតរបស់ សាម៉ៃ បានធ្វើដំណើរមកទីក្រុងភ្នំពេញ តែចាប់តាំងពីពេលនោះមក គាត់និងម្ដាយពុំដែលបានឮដំណឹងពីគាត់ទាល់តែសោះ ។

នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាច សាម៉ៃ និងម្ដាយរបស់គាត់ក៏ចាកចេញពីស្រុកកំណើតទៅរស់នៅភូមិបឹងកក់ ស្រុកកំចាយមារ ខេត្តព្រៃវែងវិញ ។ សាម៉ៃ និយាយថាម្ដាយរបស់គាត់មិនដែលនឹកចង់ភៀសខ្លួនទៅប្រទេសវៀតណាមនោះទេ ព្រោះគាត់រស់នៅប្រទេសកម្ពុជាជិតមួយជីវិតទៅហើយ ។ នៅភូមិបឹងកក់ សាម៉ៃ និងម្ដាយបានរស់នៅជិតបងប្អូនជីដូនមួយរបស់គាត់ ។ នៅទីនោះ អ្នកទាំងពីររស់នៅនិងធ្វើការនៅជាមួយអ្នកភូមិដទៃទៀត ។ សាម៉ៃ នៅចាំថា កាលពីដំបូងគ្មានការបែងចែករវាងខ្មែរនិងវៀតណាមទេ ។ ទោះបីនៅពេលដែលខ្មែរក្រហមដែលប្រចាំការនៅទីនោះបានចាប់ផ្ដើមធ្វើការបែងចែកក្រុម ហើយបានកំណត់ថា សាម៉ៃ និងម្ដាយរបស់គាត់ជា «ប្រជាជនថ្មី» ក៏ដោយ ក៏ខ្មែរក្រហមទាំងនោះនៅតែបន្តប្រព្រឹត្តល្អជាមួយពួកគាត់ដូចប្រជាជនខ្មែរដទៃដែរ ។ ម្ដាយរបស់ សាម៉ៃ មានតួនាទីជាអ្នកឲ្យបាយជ្រូក ហើយដើរប្រមូលលាមកគោមកធ្វើជី ។ ម្ដាយ សាម៉ៃ ចេះនិយាយទាំងភាសាវៀតណាមនិងខ្មែរយ៉ាងស្ទាត់ជំនាញ ប៉ុន្តែគាត់មិនដែលហ៊ាននិយាយភាសាវៀតណាមទេនៅសម័យខ្មែរក្រហម ។

ទោះបីជាម្ដាយរបស់ សាម៉ៃ ព្យាយាមលាក់បាំងប្រវត្តិរូបជាជនជាតិវៀតណាមរបស់គាត់យ៉ាងណាក៏ដោយ ក៏នៅពាក់កណ្ដាលឆ្នាំ១៩៧៨ខ្មែរក្រហមនៅតែចោទប្រកាន់គាត់ថាជាជនជាតិវៀតណាមដដែល ។ សាម៉ៃ យល់ឃើញថា ដោយសារតែពណ៌សម្បុររបស់ម្ដាយគាត់ទើបធ្វើឲ្យមានការសង្ស័យនេះឡើង ហើយម្យ៉ាងទៀតដោយសារតែអ្នកភូមិខ្លះបានរាយការណ៍ប្រាប់ខ្មែរក្រហមផង ។ បន្ទាប់មកទៀត ប្រធានសហករណ៍ឈ្មោះ ឆម បានចាត់តាំងឲ្យ សាម៉ៃ ទៅធ្វើការនៅកន្លែងផ្សេងដែលមានតួនាទីធ្វើប្រហិតត្រី ។ នៅពេលនោះ សាម៉ៃ មានអាយុ២០ឆ្នាំ ហើយទើបតែឆ្លងទន្លេកូនដំបូងរួច ដូច្នេះខ្មែរក្រហមមិនទៅហៅ សាម៉ៃ ឲ្យទៅជាមួយម្ដាយរបស់គាត់ទេ ។ បន្ទាប់ពី សាម៉ៃ ឆ្លងទន្លេបានពីរថ្ងៃ ខ្មែរក្រហមក៏បញ្ជូនម្ដាយរបស់ សាម៉ៃ ដែលមានអាយុ៥៨ឆ្នាំទៅកងចល័ត ហើយបន្ទាប់មកទៅកន្លែងមួយទៀតដែលគ្មាននរណាដឹងសោះ ។ សាម៉ៃ មិនដែលឃើញម្ដាយរបស់គាត់ម្ដងទៀតឡើយ ប៉ុន្តែគាត់បានឮពាក្យចចាមអារ៉ាមមួយថាខ្មែរក្រហមសម្លាប់ម្ដាយគាត់បាត់ទៅហើយ ។

តមកទៀត ខ្មែរក្រហមបានត្រឡប់មកភូមិវិញដើម្បីមករក សាម៉ៃ ។ សាម៉ៃ បានពួននៅក្នុងជង្រុកចំបើងដើម្បីគេចខ្លួនពីការតាមចាប់របស់ខ្មែរក្រហម ។ ខ្មែរក្រហមនៅតែស្វែងរក សាម៉ៃ បន្តទៀត ដោយខស្សព្រាហ៍ត្រឡប់ទៅភូមិរបស់គាត់ជាច្រើនដងក្នុងមួយសប្ដាហ៍ ហើយម្ដងៗមានរយៈពេលជិតមួយម៉ោង ។ សាម៉ៃ នៅចាំថាគាត់បានពឹងបងប្អូនរបស់គាត់និងមេក្រុមជាមេខ្មែរក្រហមម្នាក់ឈ្មោះ មួន ដើម្បីជួយគាត់ឲ្យរត់គេចពីការចាប់ខ្លួនរបស់ខ្មែរក្រហម ។ មួន និង សាម៉ៃ មានទំនាក់ទំនងល្អនឹងគ្នានៅពេលធ្វើការនៅកងចល័ត (មួន ជាមេកង ហើយ សាម៉ៃ ជាកូនក្រុម) ។

សាម៉ៃ បាននិយាយថា រាល់ពេលដែលខ្មែរក្រហមឲ្យដំណឹងថានឹងមកដល់ភូមិបឹងកក់ មួន តែងតែមកប្រាប់ សាម៉ៃ ជានិច្ច ។ ដោយសារតែមានជំនួយពី មួន ទើបធ្វើឲ្យ សាម៉ៃ មានពេលគ្រប់គ្រាន់ក្នុងការលាក់ខ្លួនក្នុងជង្រុកចំបើងជាមួយនឹងកូនគាត់ ។ នៅពេលនោះគាត់ចាំថាគាត់ត្រូវបំបៅកូនគាត់ផងដើម្បីកុំឲ្យវាយំ ។ គាត់នៅរស់ក្នុងភូមិនោះដដែលនៅពេលដែលគាត់លែងពួនពីខ្មែរក្រហម ។ គាត់នៅចាំថាខ្មែរក្រហមបានដំឡើងខគ្សោសនសព្ទដើម្បីប្រកាសឲ្យដឹងពីអង្គប្រជុំជាសាធារណៈរបស់ពួកខ្មែរក្រហម ។ អំឡុងពេលធ្វើការប្រជុំនេះ គាត់បានឮខ្មែរក្រហមនិយាយសំដៅទៅរកជនជាតិវៀតណាមថាជាសត្រូវនិងជាអ្នកឈ្លានពានទឹកដីកម្ពុជា ។ យោងតាមពាក្យសម្តីនេះនិងបទពិសោធន៍ផ្ទាល់របស់ សាម៉ៃ គាត់ហ៊ាននិយាយថា ជនជាតិវៀតណាមនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យត្រូវតែលាក់នូវប្រវត្តិជាតិសាសន៍របស់ខ្លួន ឬត្រូវគេចខ្លួនចេញពីប្រទេសតែម្តងដើម្បីរស់រានមានជីវិតពីរបបនេះ ។

**ហ៊ឹម សាមន**

បន្ថែមទៅលើជនជាតិវៀតណាមដែលរួចខ្លួនមានជីវិតនៅក្នុងខេត្តព្រៃវែង មជ្ឈមណ្ឌលឯកសារកម្ពុជានិងខ្ញុំបានរកឃើញជនជាតិវៀតណាមដែលនៅរស់ជីវិតក្នុងខេត្តស្វាយរៀងទៀត ។ ក្នុងបទសម្ភាសន៍ឆ្នាំ២០០៨ ហ៊ឹម សាមន បាននិយាយរៀបរាប់ពីរឿងដែលគាត់និងគ្រួសារវៀតណាមកាត់ចិនរបស់គាត់អាចរួចផុតពីរបបខ្មែរក្រហម ។ ឪពុករបស់ សាមន ជាជនជាតិចិនសុទ្ធសាធ គាត់មកដល់ប្រទេសកម្ពុជានៅពេលដែលគាត់អាយុ១៨ឆ្នាំ ហើយបានជួបម្តាយរបស់ សាមន ជាជនជាតិវៀតណាមសុទ្ធសាធដែរ រស់នៅមេសថ្ងកជិតព្រំដែនកម្ពុជា-វៀតណាម ។ អ្នកទាំងពីររៀបការជាមួយគ្នា ហើយមានកូន៤នាក់ឈ្មោះ ទី, សាវុទ្ធ, សាវន និងសាមន ។ ក្នុងអំឡុងសម័យខ្មែរក្រហម បងប្អូនរបស់ សាមន បីនាក់ត្រូវទៅរស់នៅក្នុងកងចល័តឆ្ងាយពីគ្រួសាររបស់ខ្លួន ។ នៅទីនោះ ពួកគេមាននាទីជីកប្រឡាយ ។ សាមន និងឪពុកម្តាយរបស់គាត់រស់នៅភូមិកំណើតរបស់ខ្លួននៅភូមិប្រសូត្រ ឃុំកណ្តៀងរាយ ស្រុកស្វាយទាប ខេត្តស្វាយរៀង ។ សាមន និងឪពុកម្តាយរបស់គាត់ចេះនិយាយភាសាខ្មែរបានច្បាស់ល្អណាស់ តែគាត់និយាយថានៅសម័យនោះគ្មាននរណាម្នាក់ហ៊ាននិយាយភាសាវៀតណាមទេ ។

សាមន និយាយថា ខ្មែរក្រហមនៅក្នុងភូមិរបស់គាត់ប្រព្រឹត្តដាក់ជនជាតិវៀតណាមដូចជាជនជាតិខ្មែរដែរ គឺខុសពីទស្សនៈដែលថាខ្មែរក្រហមស្អប់ជនជាតិវៀតណាម ។ គាត់នៅចាំបានថាទាំងជនជាតិខ្មែរនិងវៀតណាមសុទ្ធតែអត់ទ្រាំរស់នៅក្នុងជីវភាពដ៏លំបាកនោះ ។ ប្រជាជនត្រូវបង្ខំឲ្យធ្វើការធ្ងន់ធ្ងរ តែគ្មានអាហារហូបគ្រប់គ្រាន់ទេ ។ ប្រសិនបើធ្លាក់ខ្លួនឈឺគឺគ្មានមន្ទីរពេទ្យឬឱសថព្យាបាលឡើយ ។ ឪពុករបស់ សាមន ត្រូវទៅឃ្វាលគោ ហើយម្តាយរបស់គាត់ត្រូវមើលថែក្មេងតូចៗពេលម្តាយចេញទៅធ្វើស្រែអស់ ។ នៅពេលនោះ សាមន មានអាយុទើបតែ១០ឆ្នាំប៉ុណ្ណោះ ហើយធ្វើការនៅកងកុមារ ។ គាត់នៅចាំថា ពេលព្រឹកគាត់ត្រូវចូលរៀន៣ម៉ោង ប្រមូលលាមកគោដើម្បីយកមកធ្វើជីដាក់ស្រែ ហើយពេលរសៀលត្រូវកិនស្រូវ ។ សាមន និយាយថាខ្មែរក្រហមបានកម្រិតឲ្យក្មេងម្នាក់ៗកិនអង្ករឲ្យបាន១០៥គីឡូក្រាមជារៀងរាល់ថ្ងៃ ។ នៅពេលថ្ងៃគាត់និងម្តាយធ្វើការបែកគ្នា ប៉ុន្តែនៅពេលយប់ខ្មែរក្រហមអនុញ្ញាតឲ្យពួកគាត់ជួបជុំគ្នានៅក្នុងផ្ទះរបស់ខ្លួន ។

សាមន និយាយថា ខ្មែរក្រហមចាប់ផ្តើមធ្វើមិនល្អដាក់ជនជាតិវៀតណាមនៅពេលដែលកម្ពុជាប្រជាធិបតេយ្យនិងវៀតណាមចាប់ផ្តើមមានទំនាស់ព្រំដែននៅឆ្នាំ១៩៧៧ ។ គាត់បានឮថាឈ្លបនៅក្បែរភូមិរបស់គាត់ជាអ្នកប្រមូលនិងសម្លាប់ចោលអ្នកភូមិណាដែលមានឈាមជ័រជាជនជាតិវៀតណាម ។ សាមន និយាយថា ប្រជាជននៅភូមិគាត់មិនត្រូវខ្មែរក្រហមប្រព្រឹត្តបែបនោះទេ ។ តាមការពិត ទោះបីជាបន្ទាប់ពីឆ្នាំ១៩៧៧ក៏ដោយ ក៏ខ្មែរក្រហមនៅភូមិប្រសូត្រនៅតែប្រព្រឹត្តមកលើជនជាតិវៀតណាមនិងខ្មែរស្មើគ្នាដដែល ។ សាមន ជឿជាក់ថាគ្រួសារជនជាតិវៀតណាមក៏ដូចជាគ្រួសារគាត់ផ្ទាល់អាចរស់រានមានជីវិតបានក៏ដោយសារតែប្រធានភូមិដែរ ។ មុនពេលខ្មែរក្រហមចូលកាន់អំណាច គ្រួសាររបស់ សាមន បានរក្សាទំនាក់ទំនងល្អជាមួយមេភូមិនិងប្រធានសហករណ៍ឈ្មោះ តាយឿន ។ សាមន ជឿជាក់ថា យឿន មិនបានលាតត្រដាងពីប្រវត្តិគ្រួសារគាត់ ក៏ដូចជាគ្រួសារវៀតណាមដទៃទៀតប្រាប់ថ្នាក់លើទេ ។ គាត់បានបញ្ជាក់

ទៀតថា កម្មាភិបាលខ្មែរក្រហមថ្នាក់ខ្ពស់ជាអ្នករៀបចំបញ្ជីឈ្មោះមនុស្សដែលត្រូវយកទៅសម្លាប់ទៅតាមព័ត៌មានដែលប្រមូលបានពីប្រធានភូមិ ។ ប្រសិនបើប្រធានភូមិឬប្រធានសហករណ៍មិនបានរាយការណ៍ពីគ្រួសារជនជាតិវៀតណាមណាមួយទៅឲ្យគណៈស្រុក នោះជនជាតិវៀតណាមដែលរស់នៅក្នុងភូមិក៏ពុំត្រូវបានខ្មែរក្រហមកំណត់ថាគោលដៅដែរ ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើប្រធានភូមិរាយការណ៍ទៅថ្នាក់លើ នោះគណៈស្រុកនឹងបញ្ជូនយោធាទៅភូមិនោះភ្លាម ហើយនឹងចាប់ជនជាតិវៀតណាមជាមិនខាន ។ សាមន និយាយថា យឿន មិនដែលនិយាយជាមួយគាត់ពីរឿងការពារគ្រួសាររបស់គាត់ទេ ។ ទោះជាយ៉ាងណា សាមន បាននិយាយពីរបីដងនៅពេលដែលខ្មែរក្រហមក្រៅភូមិរបស់គាត់ចុះមកត្រួតពិនិត្យនៅក្នុងភូមិ ហើយខ្មែរក្រហមទាំងនោះជឿជាក់ថាគ្រួសាររបស់គាត់ជាជនជាតិខ្មែរ ។ យឿន ដឹងថាគ្រួសាររបស់ សាមន ជាជនជាតិវៀតណាម ប៉ុន្តែ សាមន ជឿជាក់ថា យឿន ប្រាកដជាមិនរាយការណ៍ប្រាប់ខ្មែរក្រហមទាំងនោះទេ ។ អាស្រ័យហេតុនេះ គ្រួសាររបស់ សាមន និងគ្រួសារវៀតណាមបីគ្រួសារទៀតនៅក្នុងភូមិប្រសូត្រ (គ្រួសាររបស់ មន ស៊ិន, សេង និង អែម) អាចនៅរស់រានមានជីវិតពីរបបខ្មែរក្រហម ។

## មូលន័យទូទៅនៃប្រវត្តិរឿងផ្ទាល់ខ្លួន

រឿងរ៉ាវដែលបានកើតឡើងដូចរៀបរាប់ខាងលើរបស់អ្នកដែលនៅរស់ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យគឺតំណាងឲ្យបទពិសោធន៍ផ្សេងៗគ្នា ។ រឿងរ៉ាវផ្ទាល់ខ្លួនរបស់អ្នកទាំងនេះបានបង្ហាញឲ្យយើងឃើញពីទំនាក់ទំនងរវាងខ្មែរក្រហមមនិងជនជាតិភាគតិចវៀតណាមនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ។ ចេញពីបទពិសោធន៍របស់អ្នកទាំងនេះ យើងអាចសន្និដ្ឋានបានពីរឿងរ៉ាវដែលបានកើតឡើងក្នុងសម័យនោះ ។ យើងអាចមើលឃើញថា ខ្មែរក្រហមប្រចាំការក្នុងភូមិមានអំណាចខ្លាំងណាស់ក្នុងអន្តរកម្មរវាងអង្គការនិងជនជាតិភាគតិចវៀតណាម ។ មេដឹកនាំប្រចាំការក្នុងភូមិដូចជាមេភូមិគឺមានទំនាក់ទំនងជាមួយប្រជាជនដោយផ្ទាល់តែម្តង ខុសពីអង្គការដែលជាអ្នកអនុវត្តតែគោល-ការណ៍ធំៗប៉ុណ្ណោះ ដោយពុំមានទំនាក់ទំនងជាមួយប្រជាជនដោយផ្ទាល់ទេ ។ ព័ត៌មានក្នុងស្រុកភូមិដែលមេភូមិទទួលបានពីប្រជាជនតែងតែត្រូវបានអង្គការយកមកប្រើប្រាស់ដើម្បីធ្វើការកំណត់អ្នកភូមិដែលមានជាប់សាច់ឈាមជាវៀតណាម ។ មានករណីខ្លះមេដឹកនាំប្រចាំការក្នុងស្រុកបានរាយការណ៍ជូនអង្គការនូវឈ្មោះអ្នកភូមិដែលជាជនជាតិវៀតណាម ។ តែមានករណីខ្លះអ្នកទាំងនេះក៏ជួយលាក់ប្រវត្តិឲ្យជនជាតិភាគតិចទាំងនោះមិនឲ្យអង្គការដឹងដែរ ។ មេដឹកនាំប្រចាំការក្នុងស្រុកអាចជួយបុលាក់ជនជាតិវៀតណាមដោយផ្ទាល់បាន ។ ដូចរឿងផ្ទាល់ខ្លួនរបស់អ្នកទាំងនេះនិយាយពីមេដឹកនាំប្រចាំការក្នុងស្រុកដែលជាអ្នកចាប់ខ្លួនគ្រួសារជនជាតិវៀតណាម ហើយមានរឿងខ្លះទៀតនិយាយពីមេដឹកនាំប្រចាំការក្នុងស្រុកបានជួយការពារអ្នកភូមិជាជនជាតិវៀតណាមដោយប្រាប់ពួកគេពីការជិតចុះមកត្រួតពិនិត្យក្នុងភូមិរបស់ខ្មែរក្រហម ។ មេដឹកនាំប្រចាំការក្នុងស្រុកខ្លះក៏គ្រប់គ្រងលើការអនុវត្តគោលការណ៍របស់អង្គការដើម្បីប្រឆាំងនឹងវៀតណាមដែរ ។ ដូចជារឿងដែលកើតឡើងនៅភូមិពោធិ៍ចិនដាំគឺជាឧទាហរណ៍មួយយ៉ាងជាក់ស្តែងដែលខ្មែរក្រហមប្រចាំការក្នុងស្រុកបានបង្កើតនូវគោលការណ៍ដោយខ្លួនឯងក្នុងការចាប់ខ្លួនកូនក្មេងដែលមានឈាមជ័រជាជនជាតិវៀតណាមដោយសម្គាល់ថាឪពុកឬក៏ម្តាយជាជនជាតិវៀតណាម ។

យោងទៅតាមរឿងផ្ទាល់ខ្លួនទាំងនេះ អាចឲ្យយើងមើលឃើញថា ខ្មែរក្រហមតែងតែមើលទៅលើរូបរាងខាងក្រៅដើម្បីកំណត់នូវជាតិសាសន៍របស់អ្នកភូមិ ។ ប្រជាជនណាដែលមានពណ៌សម្បុរភ្លឺថ្លា ឬស ត្រូវខ្មែរក្រហមចោទថាជាជនជាតិវៀតណាម ។ ចំពោះប្រជាជនខ្លះទៀតបានលើកឡើងថា ពាក្យសម្តីក៏ជាចំណុចសំខាន់មួយក្នុងការកំណត់ពីជាតិសាសន៍របស់អ្នកភូមិផងដែរ ។ ប្រជាជនណាដែលនិយាយភាសាវៀតណាមឬនិយាយភាសាខ្មែរមិនច្បាស់មុខជាត្រូវជាប់ជាមុខសញ្ញារបស់ខ្មែរក្រហមហើយ ។ អ្វីដែលគួរឲ្យចាប់អារម្មណ៍ជាងនេះទៅទៀតគឺទង្វើដែលខ្មែរក្រហមធ្វើមកលើជនជាតិភាគតិចវៀតណាមនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យគឺហាក់ដូចជាមានជាប់ទាក់ទងរវាងគោលនយោបាយរបស់ខ្មែរក្រហមនិងបក្សពលករវៀតណាមដូច្នេះ ។ ប្រជាជនដែលបានធ្វើបទសម្ភាសន៍នៅចាំថា នៅឆ្នាំ១៩៧៧ពេលដែល

ទំនាស់ព្រំដែនរវាងកម្ពុជាប្រជាធិបតេយ្យនិងវៀតណាមចាប់ផ្តើមកើតឡើង បានធ្វើឲ្យគោលនយោបាយរបស់ខ្មែរក្រហមចំពោះជនជាតិភាគតិចវៀតណាមប្រែប្រួលគួរឲ្យកត់សម្គាល់នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ។ នៅពេលនោះ មានប្រជាជនជាច្រើនបានឃើញដោយផ្ទាល់ភ្នែកពីការបែងចែកពូជសាសន៍ ការបាត់ខ្លួនរបស់ជនជាតិវៀតណាមនិងការចាត់ទុកជនជាតិវៀតណាមជាសត្រូវ ។ ចំណែកឯអ្នកធ្វើសម្ភាសន៍ដែលបានបាត់បង់បងប្អូនឬមិត្តភក្តិដែលជាគ្រួសារវៀតណាមមានការគិតដូចគ្នាមួយគឺមិនដឹងថាមានរឿងអ្វីបានកើតឡើងចំពោះអ្នកជាទីស្រឡាញ់របស់ពួកគេទេ ។ មានករណីជាច្រើនខ្មែរក្រហមបានយកលេសថាទៅ «រៀនសូត្រ» ឬ «ចាប់ខ្លួន» ដើម្បីពង្រត់ប្រជាជនទាំងនោះចេញពីគ្រួសាររបស់គេ ។ អាស្រ័យហេតុនេះ ប្រជាជនភាគច្រើនតែងតែនិយាយតគ្នាពីរឿងបាត់ខ្លួនរបស់គ្រួសារពួកគេ ប៉ុន្តែរហូតមកដល់ពេលនេះប្រជាជននៅតែមិនច្បាស់ក្នុងចិត្តពីជោគវាសនារបស់បងប្អូនគាត់ទៅជាយ៉ាងណាៗឡើយ ។

## សេចក្តីបញ្ចប់

យោងទៅតាមឯកសាររបស់ខ្ញុំនិងបទសម្ភាសន៍ដែលធ្វើឡើងនៅកម្ពុជាគឺបញ្ជាក់យ៉ាងច្បាស់ថាខ្មែរក្រហមបានអនុវត្តនូវគោលការណ៍យ៉ាងកាចសាហាវក្នុងការប្រល័យពូជសាសន៍និងការបោសសម្អាតជនជាតិភាគតិចជាពិសេសជនជាតិវៀតណាមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ គោលការណ៍ប្រល័យពូជសាសន៍របស់ខ្មែរក្រហមគឺមិនបញ្ចេញឲ្យឃើញឬសម្លាប់ជាទ្រង់ទ្រាយធំដូចរបបណាហ្ស៊ីនៅប្រទេសអាល្លឺម៉ង់ទេ ប៉ុន្តែអ្វីដែលសំខាន់គឺការមិនបានកាត់បន្ថយនូវភាពរន្ធត់នៃលទ្ធផលចុងក្រោយឬស្ថានភាពគួរឲ្យអាណោចអាធ័មរបស់ជនរងគ្រោះនោះទេ ។ ទោះបីជាអត្ថបទរបស់ខ្ញុំបានផ្តល់នូវការយល់ដឹងខ្លះស្តីពីបទពិសោធន៍របស់ជនជាតិវៀតណាម តែខ្ញុំគិតថាគួរតែមានការស្រាវជ្រាវបន្តទៀត ។ ចំពោះការស្រាវជ្រាវបន្តគួរតែផ្តោតសំខាន់ទៅលើជនជាតិវៀតណាមដែលរស់នៅតាមតំបន់ផ្សេងទៀតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ការស្រាវជ្រាវបន្ថែមទៀតគួរផ្តោតទៅលើតំបន់ភូមិភាគខាងលិចប្រទេសកម្ពុជា ព្រោះវាអាចឲ្យយើងធ្វើការប្រៀបធៀបគ្នារវាងបទពិសោធន៍របស់ប្រជាជនភូមិភាគខាងកើតនិងខាងលិច ។ ការស៊ើបអង្កេតឲ្យបានដិតដល់ចំពោះជនជាតិវៀតណាមដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងភូមិប្រសូត្រ ខេត្តស្វាយរៀង ក៏អាចផ្តល់នូវអត្ថប្រយោជន៍ផងដែរដល់អ្នកស្រាវជ្រាវ (ដូចបានរៀបរាប់ក្នុងរឿងរបស់ ហ៊ឹម សាមន) ។ ព្រោះតែជនជាតិវៀតណាមភាគតិចដែលអាចនៅរស់ដល់សព្វថ្ងៃគឺកម្រមាន អ្នកទាំងនោះ (ដូចជានៅក្នុងភូមិប្រសូត្រ) អាចផ្តល់ការយល់ឃើញចំពោះរបបខ្មែរក្រហមផ្សេងពីទស្សនៈរបស់ប្រជាជនដែលមានបងប្អូនស្លាប់ឬបាត់ខ្លួនក្នុងរបបនោះ ។ ម្យ៉ាងទៀត ការស្រាវជ្រាវបន្ថែមគួរតែប្រមូលព័ត៌មានទាំងអ្នកភូមិនិងកម្មាភិបាលខ្មែរក្រហម ព្រោះធ្វើបែបនេះអាចឲ្យយើងយល់កាន់តែច្បាស់ពីគោលនយោបាយរបស់ខ្មែរក្រហមនិងទង្វើដែលខ្មែរក្រហមធ្វើមកលើជនជាតិវៀតណាមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ ។

ការស្រាវជ្រាវបន្ថែមទាំងនេះនឹងផ្តល់ឱកាសឲ្យជនជាតិភាគតិចវៀតណាមដែលរស់នៅក្រោមរបបខ្មែរក្រហមនិយាយពីទុក្ខសោករបស់ខ្លួន ។ ព័ត៌មានទាំងនោះមិនត្រឹមតែបង្ហាញពីភាពអយុត្តិធម៌កន្លងមកទេ ថែមទាំងអាចរួមចំណែកដល់ការយល់ឃើញអំពីទំនាក់ទំនងរវាងទំនាស់នយោបាយនិងពូជសាសន៍ទៀតផង ។ ព័ត៌មានដែលទាក់ទងទៅនឹងជនជាតិភាគតិចវៀតណាមក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏អាចយកមកប្រើប្រាស់បានដែរក្នុងការកាត់ទោសពេលបច្ចុប្បន្ននេះនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាស្តីពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ជាមួយនឹងព័ត៌មានបន្ថែមស្តីអំពីការកំណត់មុខសញ្ញារបស់ខ្មែរក្រហមនិងការធ្វើទុក្ខបុកម្នេញមកលើជនជាតិភាគតិចវៀតណាមនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យគឺអាចជួយដល់ការកាត់ទោសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដោយពិចារណាទៅលើទោសប្រល័យពូជសាសន៍ប្រឆាំងទៅនឹងអតីតមេដឹកនាំខ្មែរក្រហមដែលញុះញង់ឲ្យមានគោលការណ៍បែបនេះឡើង ។ ជាការពិតណាស់ ការស្រាវជ្រាវនៅពេលបច្ចុប្បន្ននិងអនាគតអំពីជនជាតិភាគតិចវៀតណាមក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនឹងអាចផ្តល់ព័ត៌មានទាក់ទិនផ្សេងៗជំនួយដល់ការសិក្សាផ្នែកច្បាប់និងសហគមន៍សាធារណៈផ្សេងៗ ។ **អ៊ីលីហ្សាបែត ជូ**

# ការវាយតម្លៃទៅលើដីកាអង្គជំនុំជម្រះវិសាមញ្ញស្តីពីសិទ្ធិ និងកាតព្វកិច្ចក្នុងការបកប្រែ

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) កំពុងស្ថិតក្នុងការជជែកដេញដោលគ្មានដាច់ស្តីអំពីឯកសារដែលត្រូវផ្តល់អត្ថិភាពឲ្យធ្វើការបកប្រែសម្រាប់ជនជាប់ចោទនិងមេធាវីការពារក្តីរបស់ជនជាប់ចោទ ។ រឿងរ៉ាវទាក់ទងទៅនឹងការលំបាកក្នុងការបកប្រែនៅឯអង្គជំនុំជម្រះវិសាមញ្ញប្រទាញឲ្យមានការចាប់អារម្មណ៍នៅខែមេសា នៅពេលដែលលោក ហ្សាក់ វែហ្វេស មេធាវីការពារក្តីជនជាតិបារាំងរបស់ ខៀវ សំផន ចេញសេចក្តីប្រកាសក្នុងអំឡុងពេលសវនាការថាគាត់នឹងមិនចូលរួមទេដោយសារឯកសារភ័ស្តុតាងចំនួន១៦០០ទំព័រក្នុងសំណុំរឿងកូនក្តីរបស់គាត់មិនត្រូវបានបកប្រែជាភាសាបារាំង ។

សហចៅក្រមស៊ើបអង្កេតរបស់អង្គជំនុំជម្រះវិសាមញ្ញបានឆ្លើយតបទៅនឹងការតវ៉ារបស់មេធាវី ហ្សាក់ វែហ្វេស ដោយប្រើពាក្យសម្តីបន្ទោសល្មមៗរំឭកមេធាវី ខៀវ សំផន ថាគាត់មានសហមេធាវីកម្ពុជាម្នាក់ដែលអាចយល់ដឹងឯកសារក្នុងសំណុំរឿងក្តីនោះហើយ ។ វិធាន២២(១) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញស្នើឲ្យមានការសហការគ្នារវាងសហមេធាវីការពារក្តីខាងភាគីកម្ពុជានិងបរទេស ។ សហចៅក្រមស៊ើបអង្កេតក៏បានចង្អុលបង្ហាញថា ដូចដែលវិធានផ្ទៃក្នុងតម្រូវឲ្យមានគ្រប់សំណុំឯកសារទាំងអស់ (ឯកសារបញ្ជូនមកពីភាគីមួយសម្រាប់ឲ្យតុលាការធ្វើការពិចារណានិងចាត់វិធានការ) ត្រូវបានបកប្រែទៅជាភាសាផ្លូវការចំនួនបី គឺភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង ។

នៅខែមិថុនា សហចៅក្រមស៊ើបអង្កេតបានចេញសេចក្តីសម្រេចមួយយ៉ាងវែងទៅលើ បញ្ហាបកប្រែគឺសាលដីកាទៅលើសិទ្ធិនិងកាតព្វកិច្ចបកប្រែរបស់ភាគីទាំងអស់ («សេចក្តីបង្គាប់បញ្ជា») ។ សាលដីកាចែងថា អង្គជំនុំជម្រះវិសាមញ្ញមិនទាមទារឲ្យបកប្រែគ្រប់ឯកសារដែលប្រើប្រាស់សម្រាប់សំណុំរឿងក្តីទៅឲ្យមេធាវីការពារក្តីជនជាតិបរទេសរបស់ជនត្រូវចោទទេ ប៉ុន្តែសុំឲ្យមានការបកប្រែទៅលើឯកសារជាក់លាក់មួយចំនួនដែលជាឯកសារគោលសំខាន់របស់អង្គជំនុំជម្រះវិសាមញ្ញ វិធានផ្ទៃក្នុងនិងបទដ្ឋានយុត្តិធម៌អន្តរជាតិ ។ ដីកានេះផ្តល់ឲ្យមេធាវីការពារក្តីនូវសិទ្ធិបកប្រែដូចគ្នាទៅនឹងការផ្តល់ឲ្យជនត្រូវចោទដោយទាមទារឲ្យមានការបកប្រែសម្រាប់ភាគីទាំងពីរនូវគ្រប់ឯកសារសំខាន់បំផុតក្នុងចំណោមឯកសារដទៃទៀត ដោយរួមមានដីកាចោទប្រកាន់ភ័ស្តុតាងទៅលើដីកាចោទប្រកាន់និងការដាក់តម្កល់ឯកសារ ។ ដីកានេះក៏ផ្តល់ឲ្យក្រុមការពារក្តីនូវអ្នកបកប្រែមួយចំនួនដោយចែងថាអ្នកបកប្រែត្រូវតែប្រើប្រាស់សមត្ថភាពរបស់ខ្លួនដើម្បីដោះស្រាយបញ្ហាលំបាកខាងផ្នែកភាសាបន្ថែមទៅលើការបកប្រែសំណុំឯកសារសំខាន់ដូចមានរៀបរាប់ខាងលើ ។

សេចក្តីសន្និដ្ឋានរបស់ដីកានេះដែលថា អង្គជំនុំជម្រះវិសាមញ្ញមិនតម្រូវឲ្យបំពេញកាតព្វកិច្ចបកប្រែរាល់ឯកសារទៅជាភាសាចំនួនបីដែលប្រើប្រាស់នៅក្នុងតុលាការត្រូវបានបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ ។ ទី១) ដីកានេះមិនផ្ទុយទៅនឹងលក្ខន្តិកៈរបស់អង្គជំនុំជម្រះវិសាមញ្ញ វិធានផ្ទៃក្នុងនិងសេចក្តីណែនាំឲ្យអនុវត្ត ។ ច្បាប់និងវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញមិនចែងច្បាស់លាស់ថា ត្រូវផ្តល់ឯកសារបកប្រែឲ្យដល់ជនដែលត្រូវចោទឬមេធាវីការពារក្តីទេ ។ សេចក្តីណែនាំឲ្យអនុវត្តស្តីពីការដាក់តម្កល់ឯកសារ (សេចក្តីណែនាំឲ្យអនុវត្ត) ចែងពីវិធានច្បាស់លាស់ទៅលើការបកប្រែឯកសារតែប៉ុណ្ណោះ ។ សេចក្តីណែនាំឲ្យអនុវត្តនេះដោះស្រាយតែទៅលើការដាក់តម្កល់ឯកសារ ហើយមិននិយាយអ្វីអំពីឯកសារភ័ស្តុតាងសម្រាប់សំណុំរឿងក្តីឡើយ ដែលជាចំណុចសំខាន់នៃបញ្ហាបកប្រែថ្មីៗនេះ ។

ម្យ៉ាងវិញទៀត មិនទាន់ច្បាស់ទេថាតើដីកានេះតម្រូវឲ្យមានការបកប្រែភ័ស្តុតាងដែលបានបង្ហាញនៅសវនាការដោយបន្ថែម

ទៅនឹងការបកប្រែលើឯកសារដែលបានរៀបរាប់រួចហើយនោះទេ ។ អង្គជំនុំជម្រះវិសាមញ្ញនឹងគួសបញ្ជាក់ឲ្យច្បាស់លាស់នៅត្រង់ចំណុចនេះ ។ ប្រសិនបើតុលាការពិតជាអនុញ្ញាតឲ្យមានការបកប្រែភ័ស្តុតាងបែបនោះមែន ដីកានេះនឹងធានាបាននូវសិទ្ធិបកប្រែទូលំទូលាយទៅលើភាសាដែលប្រើប្រាស់ក្នុងតុលាការសម្រាប់ចុងចោទ និងមេធាវីការពារក្តីដូចដែលតុលាការអន្តរជាតិមួយចំនួនដូចជាតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេស រ៉្វាន់ដា និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងអង្គការសិទ្ធិមនុស្សមួយចំនួនទៀតអនុញ្ញាតឲ្យមាន ។

ដោយសារលក្ខន្តិកៈវិធានផ្ទៃក្នុង និងសេចក្តីណែនាំឲ្យអនុវត្តមិនបានកំណត់ច្បាស់លាស់អំពីវិសាលភាពនៃសិទ្ធិក្នុងការបកប្រែឯកសារសម្រាប់ជនត្រូវចោទនិងមេធាវីការពារក្តីរបស់ជនត្រូវចោទ ដូច្នេះវាចាំបាច់ក្នុងការមើលទៅលើបទដ្ឋានអន្តរជាតិដើម្បីកំណត់នីតិវិធីសមរម្យមួយ ។ វិធីនេះគឺស្របទៅនឹងមាត្រា៣៣ថ្មីនៃច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលចែងថា តុលាការគួរតែស្វែងរកការណែនាំតាមនីតិវិធីក្រមព្រហ្មទណ្ឌអន្តរជាតិ ដែលនីតិវិធីមានស្រាប់ មិនទាន់មាន ឬមិនទាន់ច្បាស់នៅត្រង់ចំណុចណាមួយ ។

ដោយហេតុថា ច្បាប់ចែងអំពីការបកប្រែសម្រាប់ចុងចោទ និងច្បាប់ចែងពីការបកប្រែសម្រាប់មេធាវីការពារក្តីចែងដាច់ពីគ្នា អត្ថបទនេះនឹងធ្វើការពិភាក្សាចំណុចទាំងពីរនេះដាច់ពីគ្នាដែរ ។

## ក) សិទ្ធិបកប្រែសម្រាប់ជនត្រូវចោទ

ច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញនិងវិធានផ្ទៃក្នុងមិនបានចែងច្បាស់លាស់អំពីការបកប្រែឯកសារសម្រាប់ចុងចោទ ប៉ុន្តែទាំងច្បាប់និងវិធានផ្ទៃក្នុងនេះចែងអំពី «ការប្រើប្រាស់អ្នកបកប្រែផ្ទាល់មាត់» នៅក្នុងមាត្រា៣៥នៃច្បាប់និងវិធាន៣០នៃវិធានផ្ទៃក្នុង ។ តុលាការអន្តរជាតិដទៃទៀតរក្សាសិទ្ធិឲ្យមានការ «បកប្រែ» ដើម្បីគ្របដណ្តប់សិទ្ធិបកប្រែទៅលើឯកសារមួយចំនួន ។ សេចក្តីណែនាំឲ្យអនុវត្តរបស់អង្គជំនុំជម្រះវិសាមញ្ញទៅលើការដាក់តម្កល់ចែងត្រឹមតែវិធានដាក់លាក់ស្តីពីការផ្តល់ឯកសារជាភាសារបស់ជនត្រូវចោទប៉ុណ្ណោះ ដោយតម្រូវឲ្យរាល់ការតម្កល់ឯកសារត្រូវតែជាភាសាខ្មែរដែលជាភាសាកំណើតរបស់ជនត្រូវចោទបន្ថែមទៅនឹងភាសាផ្លូវការផ្សេងមួយទៀត ។

ឯកសារគោលសំខាន់ៗរបស់តុលាការអន្តរជាតិដទៃទៀត និងឧបករណ៍សិទ្ធិមនុស្សជាច្រើនមានភាពស្រពេចស្រពិលស្រដៀងគ្នានេះដែរទាក់ទិននឹងវិសាលភាពសិទ្ធិក្នុងការបកប្រែ ។ ជាទូទៅតុលាការជាច្រើនកាត់បន្ថយបញ្ហាឲ្យនៅទាប ដើម្បីលើកជាសំណួរថាតើការបកប្រែបែបណាចាំបាច់ឲ្យមានយុត្តិធម៌ ។ ឧទាហរណ៍ តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្សនិយាយថា សិទ្ធិរួមមាន «ការបកប្រែ(ឯកសារ) ឬការបកប្រែផ្ទាល់មាត់ទៅលើឯកសារឬសេចក្តីសំអាងទាំងឡាយនៅក្នុងដំណើរការនាំឲ្យមានការប្រឆាំងនឹង (ចុងចោទ) ដែលចាំបាច់សម្រាប់ឲ្យចុងចោទយល់ដឹងដើម្បីទទួលសវនាការត្រឹមត្រូវនិងយុត្តិធម៌» ។

## ចុងចោទមិនមានសិទ្ធិទទួលបានការបកប្រែគ្រប់ឯកសារ

ស្របទៅនឹងការរកឃើញរបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាស្តីពីសិទ្ធិបកប្រែតុលាការអន្តរជាតិជាច្រើនចែងដដែលៗថា សិទ្ធិរបស់ចុងចោទទទួលបានការបកប្រែឯកសារទៅជាភាសាដែលគាត់អាចយល់បានមិនបានធ្វើឲ្យឯកសារនៅក្នុងសំណុំរឿងក្តីឬការដាក់តម្កល់ឯកសារទាំងឡាយដែលត្រូវបញ្ជូនកាន់តែវែងឡើយ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងតុលាការអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបដិសេធការស្នើសុំឲ្យមានការបកប្រែរាល់ឯកសារទាំងឡាយដែលលើសពីអ្វីដែលតម្រូវដោយលក្ខន្តិកៈនិងវិធានផ្ទៃក្នុង ហើយអាចនាំឲ្យប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិរបស់ចុងចោទក្នុងការកាត់សេចក្តីដោយគ្មានការពន្យារពេល ដោយសារពេលវេលានិងធនធានយ៉ាងច្រើនត្រូវចំណាយទៅលើការបកប្រែច្រើនសន្ធឹកសន្ធាប់ ។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិចែងថា គោលការណ៍យុត្តិធម៌មិនផ្តល់សិទ្ធិឲ្យមានការបកប្រែគ្រប់ឯកសារនីតិវិធីនិងភ័ស្តុតាងទាំងអស់ដែលបង្ហាញពីខាងព្រះរាជអាជ្ញានោះទេ ។ ដូចគ្នាដែរ តុលាការអឺរ៉ុប និងអង្គការសិទ្ធិមនុស្សចែងថា សិទ្ធិទទួលបានសវនាការត្រឹមត្រូវយុត្តិធម៌សម្រាប់ចុងចោទ មិនត្រូវបានរំលោភបំពានដោយសារតែថាមិនមែនរាល់ឯកសារទាំងអស់នៅក្នុងសំណុំរឿងក្តីរបស់ចុងចោទ គឺជាភាសាដែលគាត់អាចយល់ដឹង ។

## ប្រសិនបើមេធាវីការពារក្តីយល់ដឹង (លើឯកសារ) ចុងចោទមិន

## បាច់យល់ដឹង

តុលាការអន្តរជាតិជាច្រើនថែងថា លទ្ធភាពរបស់មេធាវីការពារក្តីក្នុងការយល់ដឹងឯកសារកាត់បន្ថយភាពអយុត្តិធម៌ដោយថាហេតុចេញពីភាពអសមត្ថភាពរបស់ចុងចោទក្នុងការយល់ដឹងឯកសារដោយខ្លួនឯង ។ ហេតុផលនេះប្រហែលជាត្រូវបានយកមកអនុវត្តដោយអង្គជំនុំជម្រះវិសាមញ្ញដើម្បីបដិសេធពាល់សំណើរបស់ជនត្រូវចោទក្នុងការសុំឲ្យឯកសារភ័ស្តុតាងទាំងអស់ដែលមានជាភាសាអង់គ្លេសឬភាសាបារាំងបកប្រែទៅជាភាសាខ្មែរ ប្រសិនបើជនត្រូវចោទមានមេធាវីការពារក្តីជាជនជាតិបរទេសដែលអាចយល់ដឹងឯកសារទាំងនោះបាន ។

## អ្នកបកប្រែផ្ទាល់មាត់អាចជួយបំពេញបន្ថែមលើឯកសារត្រូវបកប្រែ

អង្គភាពសិទ្ធិមនុស្សនិងតុលាការអន្តរជាតិជាច្រើន រួមមានគណៈកម្មការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិកំណត់ថា ការផ្តល់អ្នកបកប្រែផ្ទាល់មាត់ដល់ចុងចោទគឺជាការបំពេញបន្ថែមគ្រប់គ្រាន់សម្រាប់បទបញ្ញត្តិទៅលើឯកសារមួយចំនួនក្នុងភាសាដែលចុងចោទយល់ដឹង ។ ដូច្នេះសេចក្តីសម្រេចនៅក្នុងដីកាស្តីពីការបកប្រែក្នុងការផ្តល់ឲ្យក្រុមមេធាវីការពារក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញនូវជំនួយពីអ្នកបកប្រែពេញម៉ោងដោយមិនចាំបាច់ផ្តល់ឲ្យនូវអ្នកបកប្រែឯកសារ គឺស្របទៅតាមស្តង់ដារអន្តរជាតិ ។

## ភាពបត់បែនដែលថាអ្នកណាគួរតែទទួលខុសត្រូវក្នុងការបកប្រែ

តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដានិងតុលាការឧក្រិដ្ឋកម្មអន្តរជាតិឈរលើវិធីសាស្ត្រពីរផ្សេងគ្នាចំពោះការចាត់ចែងដាក់បន្ទុកថាតើអ្នកណាត្រូវផ្តល់ឲ្យនូវការបកប្រែឯកសារ ។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាតម្រូវឲ្យក្រឡាបញ្ជីបកប្រែឯកសារ ចំណែកតុលាការឧក្រិដ្ឋកម្មអន្តរជាតិដាក់បន្ទុកនេះទៅឲ្យក្រុមមេធាវីការពារក្តី ។ មិនមានភាពខុសប្លែកគ្នាគួរឲ្យកត់សម្គាល់រវាងវិធានផ្ទៃក្នុងនិងឯកសារគោលសំខាន់របស់តុលាការទាំងពីរនេះក្នុងការដោះស្រាយបញ្ហានេះទេ ។ ភាពខុសគ្នានៅត្រង់លទ្ធផលស្ថិតនៅលើការបកប្រែផ្ទាល់មាត់មិនស្របគ្នាពីសំណាក់ចៅក្រមប៉ុណ្ណោះ ។

ឯកសារសំខាន់របស់អង្គជំនុំជម្រះវិសាមញ្ញមិនបានផ្តល់តួនាទីបកប្រែឯកសារទៅឲ្យអង្គភាពរបស់ខ្លួនជាក់លាក់ណាមួយទេ លើកលែងតែការដាក់តម្កល់ឯកសារដែលជាការទទួលខុសត្រូវជាក់លាក់របស់អង្គភាពគ្រប់គ្រងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ។ ដីការបស់សហចៅក្រមស៊ើបអង្កេតបានដាក់ការទទួលខុសត្រូវលើការបកប្រែដល់អង្គភាពការពារជនត្រូវចោទនិងអង្គភាពគ្រប់គ្រងក្នុងអង្គជំនុំជម្រះវិសាមញ្ញនិងជួនកាលដាក់បន្ទុកនេះទៅលើក្រុមមេធាវីការពារក្តីតែម្តង ។ មិនទាន់មានគំរូជាអន្តរជាតិណាមួយបង្ហាញថាវិធីសាស្ត្រនេះមិនសមស្របនោះទេ ។

## ឯកសារជាក់លាក់ត្រូវបកប្រែ

បញ្ជីឯកសារជាក់លាក់មួយចំនួនដែលសហចៅក្រមស៊ើបអង្កេតតម្រូវឲ្យធ្វើការបកប្រែទៅជាភាសាប្រើប្រាស់ផ្លូវការនៅក្នុងតុលាការសម្រាប់ជនត្រូវចោទនិងមេធាវីការពារក្តីគឺមានភាពស្របគ្នាទៅនឹងបទដ្ឋានអន្តរជាតិ ។ បញ្ជីនោះរួមមានឯកសារមួយចំនួនដូចខាងក្រោម ÷

១) ដីកាចោទប្រកាន់

២) ភ័ស្តុតាងដែលដីកាចោទប្រកាន់ផ្អែកលើ

៣) ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដំបូងនិងស្ថាពររបស់សហព្រះរាជអាជ្ញា

៤) ព័ត៌មានយោងបន្ថែមនិងកំណត់សម្គាល់ស្តីពីធាតុផ្សំជាក់លាក់ដែលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមនិងស្ថាពរផ្អែកលើ

៥) ការដាក់តម្កល់ឯកសារ

៦) សេចក្តីសម្រេចនិងដីកាតុលាការ

យ៉ាងហោចណាស់ ការរកឃើញរបស់សហចៅក្រមស៊ើបអង្កេតទាក់ទិនទៅនឹងឯកសារនីមួយៗបានឆ្លើយតបតាមបទដ្ឋានអន្តរជាតិក្នុងកម្រិតអប្បបរមា ហើយទាក់ទិនទៅនឹងឯកសារមួយចំនួនទៀត ការរកឃើញនេះលើសពីបទដ្ឋានអន្តរជាតិថែមទៀត ។ ឧទាហរណ៍ សេចក្តីសម្រេចក្នុងការដាក់តម្កល់ឯកសារជាភាសារបស់ជនត្រូវចោទផ្តល់ការការពារយ៉ាងខ្លាំងដល់ចុងចោទជាងតុលាការអន្តរជាតិដទៃទៀត ។ បទបញ្ញត្តិក្នុងការបកប្រែគ្រប់

វត្ថុតាងដែលជួយគាំទ្រដីកាចោទប្រកាន់គឺស្របទៅតាមការគាំពារយ៉ាងខ្លាំងបំផុតដែលត្រូវបានរកឃើញ ។

## សេចក្តីសន្និដ្ឋាន

សរុបមក ដីកាស្តីពីសិទ្ធិបកប្រែគឺជាការការពារសិទ្ធិដល់ជនត្រូវចោទយ៉ាងខ្លាំងដើម្បីទទួលបានការបកប្រែឯកសារ ។ ទោះជាយ៉ាងណាក៏ដោយ មានបញ្ហាលើការបកប្រែមួយចំនួនមិនទាន់ត្រូវបានឆ្លើយតបបាននៅឡើយទេ ។ បញ្ហាសំខាន់ជាងគេបំផុតនោះគឺថាអង្គជំនុំជម្រះវិសាមញ្ញត្រូវតែដោះស្រាយភាពស្រពេចស្រពិលនៅក្នុងដីកាទាក់ទិននឹងវត្ថុតាងជាភ័ស្តុតាងណាមួយត្រូវបកប្រែដែលហួសពីការជួយគាំទ្រដល់ដីកាចោទប្រកាន់ ។ ការស្នើឡើងរបស់ដីកានេះគឺថាភ័ស្តុតាងដែលត្រូវដាក់បង្ហាញនៅក្នុងសវនាការត្រូវបកប្រែ ប៉ុន្តែមិនមែនអ្វីផ្សេងទៀតក្រៅពីនេះត្រូវតែធ្វើឲ្យស្របតាមបទដ្ឋានអន្តរជាតិ ប្រសិនបើតុលាការសម្រេចថាសេចក្តីបំភ្លឺរបស់សាក្សីនៅសវនាការត្រូវបានបញ្ចូលដែរ ។

## ១) ការបកប្រែសម្រាប់មេធាវីការពារក្តី

លក្ខន្តិកៈនិងវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាខ្វះខាតបទបញ្ញត្តិជាក់លាក់ក្នុងការពិនិត្យទៅលើសិទ្ធិរបស់មេធាវីការពារក្តីក្នុងការបកប្រែឯកសារជាលាយលក្ខណ៍អក្សរមួយចំនួនទៅជាភាសារបស់មេធាវីការពារក្តី ។ សេចក្តីណែនាំឲ្យអនុវត្តស្តីពីការដាក់តម្កល់ឯកសារចែងច្បាស់លាស់អំពីវិធានមួយចំនួន ប៉ុន្តែដោះស្រាយតែបញ្ហាទាក់ទិននឹងការដាក់តម្កល់ឯកសារ ដោយបញ្ជាក់ថាមេធាវីការពារក្តីទទួលបានសំណុំឯកសារជាភាសាផ្លូវការតាមជម្រើសរបស់ខ្លួន ។ ដូច្នេះ ជាថ្មីម្តងទៀត បញ្ហានេះចាំបាច់ត្រូវតែពិនិត្យមើលទៅលើបទដ្ឋានអន្តរជាតិ ។

ស្ទើរតែគ្រប់យុត្តិសាស្ត្រអន្តរជាតិស្តីពីការបកប្រែឯកសារត្រូវធ្វើការបកប្រែទៅជាភាសារបស់ជនត្រូវចោទ ។ ការសម្រេចចិត្តតិចតួចពិភាក្សាអំពីការបកប្រែសម្រាប់មេធាវីការពារក្តី ហើយសេចក្តីសម្រេចតិចជាងនេះទៀត ពិភាក្សាទៅលើសំណួរជាក់លាក់ ដែលប្រឈមមុខដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាស្តីពីអ្វីដែលត្រូវធ្វើនៅពេលដែលភាសារបស់មេធាវីការពារក្តី ជាភាសាផ្លូវការរបស់តុលាការ ។

តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាចែងថាមេធាវីការពារក្តីដែលនិយាយតែភាសាបារាំង មានសិទ្ធិទទួលបានការបកប្រែសេចក្តីសម្រេចដីកាទាំងឡាយរបស់តុលាការ ការដាក់តម្កល់ឯកសារនិងភ័ស្តុតាងដែលភាគីទាំងឡាយតម្រូវឲ្យបង្ហាញនិងដាក់ជូនទៅតុលាការ ។ តុលាការពិនិត្យពិចារណាថាមេធាវីការពារក្តីនិយាយភាសាបារាំងមានសហមេធាវីដែលនិយាយភាសាអង់គ្លេស ដែលជាភាសាផ្លូវការមួយរបស់តុលាការដែរ ។ តុលាការកំណត់ថា ក្រៅពីឯកសារដែលបានចុះបញ្ជីខាងលើ សហមេធាវីត្រូវបានរំពឹងថានឹងសហការគ្នាដើម្បីជម្នះការលំបាកក្នុងការបកប្រែភាសា ។

តុលាការឧក្រិដ្ឋកម្មអន្តរជាតិចេញសាលដីកាដែលស្នើឡើងថា តុលាការនេះអាចមិនចាត់ទុកតម្រូវការលើការបកប្រែរបស់មេធាវីការពារក្តីថាជាបញ្ហាដាច់ដោយឡែកពីសេចក្តីត្រូវការក្នុងការបកប្រែរបស់ចុងចោទនោះទេ ។ តុលាការនេះបានប្រឈមនឹងបណ្តឹងឧទ្ធរណ៍ដែលស្នើសុំឲ្យមានការបកប្រែដោយហេតុថា ទាំងចុងចោទនិងមេធាវីរបស់ខ្លួនមិនយល់ឯកសាររបស់តុលាការ ។ នៅក្នុងសាលដីកាទៅលើបណ្តឹងឧទ្ធរណ៍ តុលាការបានដោះស្រាយតែបញ្ហាទាក់ទិននឹងកាតព្វកិច្ចរបស់ខ្លួនទៅលើចុងចោទប៉ុណ្ណោះ ដោយបដិសេធមិនលើកឡើងពីសេចក្តីត្រូវការចំពោះការបកប្រែរបស់មេធាវីឡើយ ។ តុលាការនេះបានផ្តល់ការបកប្រែឯកសារគ្រប់ច្បាប់ដូចគ្នាដល់មេធាវីដូចដែលបានផ្តល់ក្នុងរឿងក្តីផ្សេងៗទៀត ដែលការបកប្រែត្រូវបានស្នើឡើងជំនួសឲ្យចុងចោទ ប៉ុន្តែមិនមែនជំនួសដោយមេធាវីរបស់ខ្លួនទេ ៖ ឯកសារចោទប្រកាន់និងបញ្ជីភ័ស្តុតាងទាំងឡាយ ។

ដីការបស់សហចៅក្រមស៊ើបអង្កេតផ្តល់ឲ្យមេធាវីការពារក្តីនូវសិទ្ធិបកប្រែដូចគ្នានឹងកូនក្តីរបស់ខ្លួន ដោយទទួលបានការផ្តល់សិទ្ធិទូលំទូលាយដូចដែលតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាផ្តល់ឲ្យដែរ ហើយលើសពីអ្វីដែលតុលាការឧក្រិដ្ឋកម្មអន្តរ-ជាតិផ្តល់ឲ្យ ។ ដីកានេះក៏ផ្តល់នូវការបកប្រែឯកសារបន្ថែមផ្សេងទៀតដែរលើសពីអ្វីដែលតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានកំណត់ថាចាំបាច់ទៅទៀត ។ ទោះបីជាយ៉ាងណាក៏ដោយ តុលាការនេះគួរតែដោះស្រាយការខ្វះខាតភាពជាក់

លាក់ទាក់ទិននឹងតម្រូវការភស្តុតាងដែលត្រូវបង្ហាញជូនតុលាការ ។

## សហមេធាវីរំពឹងថានឹងសហការគ្នា

វិធានផ្ទៃក្នុងហាក់ដូចជារំពឹងទុកអំពីតួនាទីសហប្រតិបត្តិការរវាងសហមេធាវីកម្ពុជានិងសហមេធាវីអន្តរជាតិក្នុងការការពារក្តី ។ វិធាន២២ចែងថា ចុងចោទមាន «ជំនួយពីមេធាវីកម្ពុជាម្នាក់ ឬមេធាវីអន្តរជាតិម្នាក់ ដោយធ្វើការសហការគ្នាជាមួយមេធាវីកម្ពុជា» ហើយមេធាវីអន្តរជាតិ «គួរតែធ្វើការជាមួយមេធាវីកម្ពុជាក្នុងការការពារក្តីឲ្យកូនក្តីរបស់ខ្លួននៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ» ។

តុលាការអន្តរជាតិរកឃើញលទ្ធភាពរបស់សហមេធាវីក្នុងការយល់ដឹងពីឯកសារដែលពាក់ព័ន្ធទៅនឹងសាលដីកាដែលតុលាការត្រូវធ្វើការបកប្រែ ។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាចែងថា ការដែលមេធាវីម្នាក់អាចយល់ដឹងទាំងពីរភាសាមិនបានជួយកាត់បន្ថយកាតព្វកិច្ចបកប្រែឯកសាររបស់តុលាការសម្រាប់មេធាវីការពារក្តីម្នាក់ទៀតទាំងស្រុងទេ ។ ទោះបីជាយ៉ាងណាក៏ដោយ តុលាការបានជំរុញឲ្យសហមេធាវីទាំងពីរសហការគ្នាដើម្បីយល់ដឹងអំពីឯកសារទាំងនោះ ក្រៅពីសំណុំឯកសារបកប្រែសំខាន់ៗដែលបានផ្តល់ឲ្យ ។

តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងគណៈកម្មការសិទ្ធិមនុស្សរកឃើញថា តុលាការជាច្រើនទទួលបន្ទុកស្រាលជាងនេះក្នុងការបកប្រែឯកសារទៅជាភាសារបស់ជនត្រូវចោទដែលជនត្រូវចោទម្នាក់ៗអាចជ្រើសរើសមេធាវីការពារក្តីដែលមានភាពស្ទាត់ជំនាញក្នុងការប្រើប្រាស់ភាសាផ្លូវការរបស់តុលាការ ។ ប្រសិនបើកាតព្វកិច្ចរបស់តុលាការក្នុងការបកប្រែឯកសារទៅជាភាសាដែលជនត្រូវចោទយល់បានអាចមានព្រំដែនកំណត់ត្រង់ចំណុចនេះ ហេតុផលស្រដៀងគ្នានេះអាចអនុវត្តចំពោះបញ្ហាលំបាកក្នុងការបកប្រែឯកសារសម្រាប់មេធាវីការពារជនត្រូវចោទ ។ គោលការណ៍នេះជួយគាំទ្រដល់ការស្នើយោបល់របស់អង្គជំនុំជម្រះវិសាមញ្ញដែលចែងក្នុងដីកាសម្រេចកាលពីថ្ងៃទី២៣ ខែមេសាថា ប្រសិនបើលោក ហ្សាក់ វែហ្សេស មិនអាចធ្វើការជាមួយសហមេធាវីកម្ពុជារបស់ខ្លួនដើម្បីដោះស្រាយបញ្ហាបកប្រែភាសាទេ ខៀវ សំផន មានសិទ្ធិជ្រើសរើសមេធាវីបរទេសម្នាក់ផ្សេងទៀតបាន ។ នៅក្នុងដីកាស្តីពីសិទ្ធិបកប្រែ សហចៅក្រមស៊ើបអង្កេតសង្កត់ធ្ងន់ទៅលើគោលការណ៍ដោយចែងថា «ភាគីទាំងអស់...ត្រូវតែចូលរួមចំណែកក្នុងសេចក្តីសម្រេចស្តីពីភាសាដែលខ្លួនត្រូវការ ដោយប្រើប្រាស់សមត្ថភាពប្រើប្រាស់ភាសាជាមួយក្រុមរបស់ខ្លួនដោយចែកដាច់ពីអង្គភាពគាំទ្រការពារក្តី» ។ វិធីសាស្ត្រនេះហាក់ដូចជាទទួលបានការគាំទ្រពីតុលាការអន្តរជាតិជាច្រើន ។

## ក) ដីកាស្តីសិទ្ធិបកប្រែត្រូវបានប្តឹងឧទ្ធរណ៍

ទោះបីជាដីកាស្តីពីសិទ្ធិបកប្រែស្របតាមបទដ្ឋានអន្តរជាតិក៏ដោយ ក៏លោក ហ្សាក់ វែហ្សេស ដែលជាមេធាវីការពារក្តី ខៀវ សំផន បន្តទទូចឲ្យតុលាការបកប្រែសំណុំរឿងក្តីរបស់កូនក្តីខ្លួនទាំងស្រុងទៅជាភាសាបារាំង ។ បណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន នៅខែកក្កដា ចាត់ទុកដីកានោះថា «ជាការទទួលស្គាល់បរាជ័យ» ដោយហេតុតុលាការពិចារណាឃើញថា ការបកប្រែរាល់ឯកសារនីមួយៗអាចប៉ះពាល់ធ្ងន់ធ្ងរដល់សិទ្ធិរបស់ចុងចោទក្នុងការទទួលបានសវនាការយ៉ាងឆាប់រហ័ស ។ ប៉ុន្តែសហចៅក្រមស៊ើបអង្កេតមិនមែនជាតុលាការលើកដំបូងដែលទទួលស្គាល់ថាកាលណាតម្រូវការបកប្រែកើនឡើងនោះល្បឿននៃការជំនុំជម្រះក្តីថយចុះទេ ។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាធ្លាប់បានពិភាក្សាចំណុចពាក់ព័ន្ធទាំងពីរនេះនៅពេលដែលសម្រេចអំពីកាតព្វកិច្ចបកប្រែឯកសារ ។

ក្នុងបណ្តឹងឧទ្ធរណ៍ខែកក្កដា ក្រុមការពារក្តីរបស់មេធាវីវែហ្សេស ធ្វើឲ្យលេចឡើងចំណុចមួយដែលទទួលការចាប់អារម្មណ៍ ។ បណ្តឹងឧទ្ធរណ៍នេះចង្អុលបង្ហាញថាច្បាប់ជាច្រើនដែលយោងដោយដីកាស្តីពីសិទ្ធិបកប្រែរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានមកពីតុលាការអន្តរជាតិ ដែលផ្អែកលើច្បាប់ខុមមិនឡ ខណៈពេលដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអនុវត្តតាមនីតិវិធីច្បាប់ស៊ីវិល ។ បណ្តឹងឧទ្ធរណ៍នេះបង្ហាញការពិតដែលថាភាពខុសគ្នាជាសារវន្តដែលប្រព័ន្ធច្បាប់ទាំងពីរនេះប្រើប្រាស់ភស្តុតាងនៅក្នុងដំណាក់កាលអង្គបុរេជំនុំជម្រះនិងអង្គជំនុំជម្រះជាបន្តបន្ទាប់ នាំឲ្យការអនុវត្តលើការបកប្រែភស្តុតាងក្នុងប្រព័ន្ធ

ច្បាប់ខុមមិនឡមិនអាចយកមកអនុវត្តក្នុងប្រព័ន្ធច្បាប់ស៊ីវិលទេ ។

ដីកាស្តីពីសិទ្ធិបកប្រែមិនផ្អែកលើសាលដីការបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាដែលមានមូលដ្ឋានលើច្បាប់ខុមមិនឡទេ ប៉ុន្តែដីកានេះក៏យោងទៅលើតុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្សដែលពិនិត្យមើលការអនុវត្តលើការបកប្រែឯកសាររបស់តុលាការដែលប្រើប្រាស់ច្បាប់ស៊ីវិលអឺរ៉ុប ។ តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្សនិយាយថាភាពត្រឹមត្រូវនិងយុត្តិធម៌មិនតម្រូវឲ្យមានការបកប្រែនូវរាល់ឯកសារភស្តុតាងទាំងអស់នៅក្នុងសំណុំរឿងក្តីរបស់ចុងចោទឡើយ ។ លើសពីនេះទៀត ដីកានេះយោងទៅលើតុលាការឧក្រិដ្ឋកម្មអន្តរជាតិដែលចែងថា ការពិពណ៌នាលម្អិតនូវឧក្រិដ្ឋកម្មនិងបញ្ជីឯកសារភស្តុតាងគឺតម្រូវឲ្យបកប្រែក្នុងដំណាក់អង្គបុរេជំនុំជម្រះ ។ នីតិវិធីរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ រួមមានធាតុផ្សំច្បាប់ស៊ីវិលដែលធ្វើឲ្យតុលាការនេះស្របគ្នានឹងអង្គជំនុំជម្រះវិសាមញ្ញនៅត្រង់ថាការអនុវត្តលើការបកប្រែពាក់ព័ន្ធគ្នា ។

អ្វីដែលមេធាវី វែរហ្សេស កំពុងស្នើសុំក្លាយទៅជាអ្វីដែលមិនធ្លាប់កើតមានពីមុនក្នុងចំណោមតុលាការអន្តរជាតិនានា ។ ការបកប្រែឯកសាររាប់ពាន់ទំព័រតម្រូវឲ្យតុលាការមានធនធានក្រាស់ក្រែល ហើយបន្ថយល្បឿនដំណើរការជំនុំជម្រះ ។ ទោះបីយ៉ាងនេះក៏ដោយ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចាំបាច់ធានាឲ្យបានថា ដំណើរការរបស់ខ្លួនមានភាពត្រឹមត្រូវនិងយុត្តិធម៌ដែលស្របតាមស្តង់ដារអន្តរជាតិ ។ ដូច្នេះសាលដីកាទៅលើបណ្តឹងឧទ្ធរណ៍របស់អង្គបុរេជំនុំជម្រះមានសារសំខាន់ដើម្បីការពារសិទ្ធិរបស់ចុងចោទ ដោយមិនចំណាយធនធានរបស់តុលាការដើម្បីផ្តល់ឲ្យនូវការបកប្រែលើសពីកម្រិតនៃភាពត្រឹមត្រូវនិងយុត្តិធម៌ដែលទាមទារឲ្យមាន ។

**សេង ប្លែនឆាង**

# នៅតែស្តាយ

ទាងខ្ញុំកើតនៅឆ្នាំ១៩៨៦ ក្នុងគ្រួសារមួយដែលមានជីវភាពមធ្យម និងទទួលបានការសិក្សាអប់រំយ៉ាងល្អ ។ ថ្វីត្បិតតែខ្ញុំកើតមិនទាន់របបខ្មែរក្រហមក៏ដោយ ប៉ុន្តែខ្ញុំបានដឹងរឿងរ៉ាវច្រើនអំពីជីវិតនិងអតីតកាលរបស់ឪពុកម្តាយខ្ញុំនៅក្នុងសម័យនោះ តាមរយៈការរៀបរាប់របស់គាត់ ការអានសៀវភៅ ការសិក្សាស្រាវជ្រាវ និងភស្តុតាងដែលបានបន្សល់ទុកដូចជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងនិងវាលពិឃាតជើងឯកជាដើម ។ ពេលនោះ ប្រជាពលរដ្ឋខ្មែរប្រមាណជាង១លាននាក់ត្រូវបានខ្មែរក្រហមសម្លាប់និងធ្វើទារុណកម្មយ៉ាងសាហាវព្រៃផ្សៃបំផុតព្រោះបងប្អូនខាងឪពុកម្តាយខ្ញុំត្រូវខ្មែរក្រហមសម្លាប់ស្ទើរតែទាំងអស់ ។

នៅឆ្នាំ១៩៧៥ ប្រជាជនជាច្រើនលាននាក់ត្រូវខ្មែរក្រហមជម្លៀសឲ្យទៅរស់នៅតំបន់ឆ្ងាយៗ បន្ទាប់មកបង្ខំឲ្យធ្វើការជាទម្ងន់ ហើយផ្តល់អាហារឲ្យហូបមិនគ្រប់គ្រាន់ ។ ឪពុកខ្ញុំត្រូវជម្លៀសឲ្យទៅរស់នៅខេត្តកំពង់ស្ពឺឆ្ងាយពីជីតារបស់ខ្ញុំ ដែលពេលនោះគាត់ទើបតែមានអាយុ១៦ឆ្នាំប៉ុណ្ណោះ ។ ឪពុកខ្ញុំត្រូវខ្មែរក្រហមបង្ខំឲ្យគាត់ធ្វើការចាប់តាំងពីព្រឹកព្រលឹមរហូតដល់យប់ជ្រៅដោយទទួលបានបបរពីរចាននិងអំបិលពីរ-បីគ្រាប់ ។ ដោយសារហូបអាហារនិងសម្រាកមិនបានគ្រប់គ្រាន់ ឪពុករបស់ខ្ញុំក៏ធ្លាក់ខ្លួនឈឺ ។ មួយសប្តាហ៍ក្រោយមក ជំងឺគាត់មានសភាពកាន់តែដុនដាបទៅៗ រហូតធ្វើឲ្យគាត់គ្មានកម្លាំងទៅធ្វើការបន្តទៀត ។ ទោះបីឈឺយ៉ាងណាក៏ដោយ ក៏គាត់មិនហ៊ានឈប់សម្រាកដែរ ព្រោះខ្លាចខ្មែរក្រហមយកទៅអប់រំឬយកទៅសម្លាប់ចោល ។ ឪពុកខ្ញុំគិតក្នុងចិត្តថា គាត់នឹងត្រូវខ្មែរក្រហមយកទៅសម្លាប់នៅថ្ងៃណាមួយជាមិនខាន ។ ប៉ុន្តែជាសំណាងល្អឪពុកខ្ញុំត្រូវបានមិត្តភក្តិម្នាក់ឈ្មោះ ឃឹន ជួយព្យាបាលរហូតបានជាសះស្បើយ ។ ពេលនោះហើយដែលឪពុកខ្ញុំឃើញមនុស្សជាច្រើនត្រូវខ្មែរក្រហមបណ្តើរយកទៅសម្លាប់ស្ទើរតែរៀងរាល់ថ្ងៃ ។

នៅឆ្នាំ១៩៧៧ ឪពុកខ្ញុំត្រូវខ្មែរក្រហមបង្ខំឲ្យរៀបការជា

មួយម្ដាយខ្ញុំឈ្មោះរឿន ។ ចំណែកម្ដាយរបស់ខ្ញុំបានតាំងចិត្តថា គាត់នឹងមិនរៀបការជាមួយឪពុកខ្ញុំទេ ព្រោះគាត់មិនដែលបានស្គាល់ឪពុកខ្ញុំពីមុនមក ។ ប៉ុន្តែ ម្ដាយរបស់ខ្ញុំមិនដឹងជាយកលេសអ្វីមកបដិសេធ ព្រោះបើមិនព្រម គាត់នឹងត្រូវខ្មែរក្រហមយកទៅសម្លាប់ ឬធ្វើទារុណកម្ម ។ ការរៀបការរបស់គាត់ និងអ្នកផ្សេងទៀត សុទ្ធតែត្រូវខ្មែរក្រហមចាប់បង្ខំដូចជារូបគាត់ដែរ ។ នៅយប់នោះ ឪពុកម្ដាយខ្ញុំសម្រាកនៅក្នុងផ្ទះជាមួយគ្នា និងជជែកគ្នាលេងដើម្បីស្វែងយល់ពីគ្នាទៅវិញទៅមក ។ ព្រឹកឡើង ឪពុកនិងម្ដាយរបស់ខ្ញុំត្រូវចេញទៅធ្វើការរៀងៗខ្លួនតាមការចាត់តាំងរបស់ខ្មែរក្រហម ។ ថ្វីត្បិតតែគាត់ទើបតែរៀបការ ប៉ុន្តែគាត់បានជួបគ្នាតែពេលហូបបាយ និងពេលឈប់សម្រាកយប់ប៉ុណ្ណោះ ។ នៅខណៈនោះដោយសារតែឪពុកខ្ញុំយកចិត្តទុកដាក់និងមើលថែទាំម្ដាយខ្ញុំ ម្ដាយខ្ញុំក៏ដាក់ចិត្តក្រោយមកថា នឹងស្រឡាញ់គាត់រហូតដល់សព្វថ្ងៃនេះ ។

នៅឆ្នាំ១៩៧៩ ដោយសារសង្គ្រាមត្រូវបញ្ចប់ហើយប្រទេសមានសន្តិភាព ឪពុកម្ដាយខ្ញុំក៏បានវិលត្រឡប់មកស្រុកកំណើតជួបជុំជាមួយញាតិមិត្ត និងបងប្អូនវិញ ។ ប៉ុន្តែ សំណាងអាក្រក់លោកយាយលោកតារបស់ខ្ញុំទាំងខាងឪពុកទាំងខាងម្ដាយត្រូវខ្មែរក្រហមយកទៅសម្លាប់ចោលទាំងអស់នៅសល់តែបងប្អូនបង្កើតមួយចំនួនប៉ុណ្ណោះដែលនៅរស់ ។ ដោយសារតែអាពាហ៍ពិពាហ៍របស់ឪពុកម្ដាយខ្ញុំនៅជំនាន់នោះត្រូវខ្មែរក្រហមជាអ្នករៀបចំ ហើយមិនមានបងប្អូនដឹងឮ គាត់ទាំងពីរក៏សម្រេចចិត្តរៀបការជាមួយគ្នាម្ដងទៀត ដោយមានការចូលរួមអបអរសាទរពីសំណាក់បងប្អូនរបស់គាត់ទាំងសងខាង ។ ប៉ុន្មានខែក្រោយមក ឪពុកម្ដាយខ្ញុំក៏សម្រេចចិត្តទៅរស់នៅភូមិខត្តុង ឃុំវាំងចាស់ ស្រុកខត្តុង ខេត្តកំពង់ស្ពឺ រហូតមកដល់សព្វថ្ងៃនេះ ។

នៅឆ្នាំ១៩៨០ ម្ដាយខ្ញុំកើតបានបងស្រីខ្ញុំម្នាក់ឈ្មោះ ដាលី ដែលសព្វថ្ងៃគាត់រស់នៅទីក្រុងភ្នំពេញ ។ កាលពីនៅវ័យកុមារ ដោយសារតែសម្ភារៈជាច្រើនត្រូវបានបំផ្លាញដោយសង្គ្រាម ហើយដោយក្រុមគ្រួសារខ្ញុំមិនសូវមានជីវភាពធូរធារ បងស្រីខ្ញុំមិនបានទទួលការសិក្សាអប់រំនៅសាលារៀនដូចជាក្មេងដទៃទៀតទេ ។

បច្ចុប្បន្ននេះ ទោះបីជាប្រទេសកម្ពុជាមានសន្តិភាព និងមានឯករាជ្យពេញបរិបូរណ៍ក៏ដោយ ក៏ផលវិបាកនៃសង្គ្រាមនៅតែជះឥទ្ធិពលអាក្រក់មកលើក្មេងៗជំនាន់ក្រោយដែរ ។ សង្គ្រាមបានបន្សល់ទុកកុមារកំព្រា ជនពិការ ស្ត្រីមេម៉ាយ និងមនុស្សចាស់ជរាយ៉ាងច្រើន ។ សង្គ្រាមធ្វើឲ្យប្រជាពលរដ្ឋកម្ពុជាភាគច្រើនភៀសខ្លួនទៅរស់នៅបរទេសជាហេតុធ្វើឲ្យប្រវត្តិសាស្ត្រខ្មែរត្រូវបាត់បង់ខ្លះ ហើយហេដ្ឋារចនាសម្ព័ន្ធផ្សេងៗត្រូវបានបំផ្លាញ ។

ចុងបញ្ចប់ ទោះបីជាប្រទេសកម្ពុជាមានសន្តិភាពហើយក៏ដោយ ក៏ការឈឺចាប់ និងទុក្ខវេទនាទាំងឡាយនៅតែដក់ជាប់ក្នុងអារម្មណ៍ប្រជាជនដដែល ។ ដូច្នេះខ្ញុំសំណូមពរឲ្យមានការកាត់ក្ដីមេដឹកនាំខ្មែរក្រហម ដើម្បីស្វែងរកយុត្តិធម៌ជូនប្រជាជនកម្ពុជាទាំងឡាយដែលបានបាត់បង់បងប្អូន និងពលីជីវិតដោយសារសង្គ្រាម ។ ខ្ញុំសូមបួងសួងឲ្យប្រទេសកម្ពុជាជួបតែសន្តិភាពជារៀងរហូត និងក្លាយទៅជាប្រទេសមួយដែលមានការរីកចម្រើនដូចជាបណ្ដាប្រទេសផ្សេងៗទៀតដែរ ។


ក្រុមគ្រួសាររបស់ ទេស ម៉ារ៉ែម ក្នុងឆ្នាំ២០០០

**ទេស ម៉ារ៉ែម**



ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ុីតដែន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ព.ម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.

A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 106, October 2008 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.